# របាយការណ៍បូកសរុបសកម្មភាព
# និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទរយៈពេល១០ខែ ឆ្នាំ២០១៧

(គិតចាប់ពីថ្ងៃទី ០១ ខែ មករា ដល់ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០១៧)

## I. ស្ថានភាពទូទៅ

ក្នុងរយៈពេល១០ខែ ឆ្នាំ២០១៧នេះ ស្ថានភាពបទល្មើសជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានរកឃើញ និងបង្ក្រាបជាបន្តបន្ទាប់ គួរឲ្យកត់សម្គាល់។ មិនតែប៉ុណ្ណោះ ក៏មានលេចចេញនូវបទល្មើសជួញដូរសរីរាង្គ និងបទអន្តរការីនៃអំពើពពោះជំនួស ដើម្បីនាំយកទារកចេញទៅក្រៅប្រទេស ដែលជាសញ្ញាណថ្មីពាក់ព័ន្ធនឹងបទល្មើសរត់ពន្ធ ឬជួញដូរទារកឆ្លងដែន។ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ ដោះស្រាយ និងបង្ការទប់ស្កាត់ជាបន្ទាន់ ហើយចាប់ផ្តើមកសាងច្បាប់ ដើម្បីគ្រប់គ្រងសកម្មភាពពពោះជំនួសឲ្យបានឆាប់។

ដោយឡែកការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍ ក៏មានស្ថានភាពមិនប្រក្រតី ដោយមានប្រជាពលរដ្ឋចាកចេញទៅធ្វើការនៅប្រទេសថៃរហូតដល់ជាងមួយលាននាក់ ទាំងស្របច្បាប់ ទាំងមិនមានឯកសារច្បាប់ ។ ថ្មីៗនេះ រាជរដ្ឋាភិបាលថៃ បានចេញគោលការណ៍រឹតបន្តឹងពលករទេសសន្តប្រវេសន៍ ដែលរស់នៅ និងធ្វើការខុសច្បាប់ក្នុងប្រទេសថៃ ។ ដើម្បី ជាដំណោះស្រាយ រដ្ឋាភិបាលថៃបានទុករយៈពេល៦ខែ ពីខែមិថុនា ដល់ចុងខែធ្នូ ឆ្នាំ២០១៧ ដើម្បីឲ្យពលកររៀបចំបំពេញបែបបទឯកសារស្របច្បាប់ ជាពិសេសលិខិតឆ្លងដែន ឲ្យទាន់ពេលវេលា ពុំនោះទេពលករទាំងនោះនឹងត្រូវបញ្ជូនត្រឡប់មកប្រទេសដើមវិញ។ រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជូនក្រុមការងារផ្តល់ភាពស្របច្បាប់ ជូនពលករ ជិតបួនរយនាក់ ដើម្បីផ្តល់លិខិតឆ្លងដែន និងសម្រួលការបំពេញបែបបទស្របច្បាប់ នៅទីក្រុងបាងកក ខេត្តរ៉េយ៉ង ឆាកធឹងសាវ និងប៉ាធុមថានី ដើម្បីពន្លឿនការទទួលបានភាពស្របច្បាប់ដល់ពលករកម្ពុជា ។ ទោះបីជាយ៉ាងនេះក្តី ក៏ នៅមានពលករប្រមាណជាជាង៣០ម៉ឺននាក់ទៀត នៅមិនទាន់មានឯកសារស្របច្បាប់នៅឡើយក្នុងប្រទេសថៃ និយាយដោយឡែក និងជារួម នៅតាមបណ្តាប្រទេសមួយចំនួនទៀត ។

លទ្ធផលនៃការវាយតម្លៃពាក់កណ្តាលអណត្តិទី១នៃការអនុវត្តផែនការសកម្មភាពជាតិ ២០១៤-២០១៨ ដែលបានធ្វើឡើងក្នុងឆ្នាំ២០១៦ បានរកឲ្យឃើញចំណុចខ្លាំង ចំណុចប្រឈម និងខ្វះខាតជាច្រើន ដែលចាំបាច់ត្រូវកែលម្អ ។ គណៈកម្មាធិការជាតិ (គ.ជ.ប.ជ) បានដាក់ចេញផែនការសកម្មភាពក្នុងដំណាក់កាលទី២ (២០១៧-២០១៨) ដោយបានឆ្លើយតបទៅនឹងចំណុចខ្វះខាតទាំងឡាយដែលបានរកឃើញ ក្នុងរបាយការណ៍វាយតម្លៃ ពាក់កណ្តាលអណត្តិនៃផែនការ ។

ជាលទ្ធផល ដែលសម្រេចបានក្នុងរយៈពេល១០ខែ ដើមឆ្នាំ២០១៧នេះ មានដូចខាងក្រោម៖

## ការអនុវត្តតាមផែនការយុទ្ធសាស្រ្តសកម្មភាពជាតិ (២០១៤-២០១៨)

### ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

ក.១-ការងារច្បាប់ និងគោលនយោបាយជាតិ

ក.១.១-កិច្ចការច្បាប់

- ❖ **ច្បាប់ និងលិខិតបទដ្ឋាន ដែលបានដាក់ឲ្យប្រើប្រាស់**
  - សន្ធិសញ្ញា ស្តីពី "**បត្យាប័ន**" រវាងព្រះរាជាណាចក្រកម្ពុជា និងប្រទេសរុស្ស៊ី ចុះហត្ថលេខា ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ (ក្រសួងយុត្តិធម៌)។
  - កិច្ចព្រមព្រៀងសហប្រតិបត្តិការ រវៀងសមាគមននារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ និង សហព័ន្ធនារីវៀតណាម ដំណាក់កាលទី២ (២០១៧-២០២២) ចុះហត្ថលេខាថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០១៧ (ក្រសួងកិច្ចការនារី)។
- ❖ **លិខិតបទដ្ឋានដែលកំពុងរៀបចំ**
  - សេចក្តីព្រាងច្បាប់ ស្តីពី "**ការគ្រប់គ្រងការពពោះជំនួស**" (ក្រសួងកិច្ចការនារី)។
  - សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "**សម្រាប់អនុវត្តល័ក្ខខ័ណ្ឌការងារកម្មករការងារផ្ទះ**" (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)។
  - សេចក្តីព្រាងគោលនយោបាយ ស្តីពី "**កិច្ចការការពារកុមារតាមសាលារៀន**" (ក្រសួងអប់រំ យុវជន និងកីឡា)។
  - **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងសន្ធិសញ្ញា និងកំពង់ពិភាក្សារួមមានៈ
    - o សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
      រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ
      រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលបារាំង
      រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលរុស្ស៊ី ។
    - o សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"**បត្យាប័ន**"
      រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលឥណ្ឌា។
    - o សេចក្តីព្រាង កិច្ចព្រមព្រៀង ស្តីពី "**បញ្ជូនទណ្ឌិត**"
      រវាងព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលអង់គ្លេស
      រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលប៉េរូ
      រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ
      រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលរុស្ស៊ី និង
    - o សេចក្តីព្រាងច្បាប់ ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

ក.១.២-**លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ**

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានចេញៈ
  - o សេចក្តីសម្រេចកែសម្រួលសមាសភាពក្រុមការងារកិច្ចការយុត្តិធម៌ លេខ០៣៧/១៧ស.ស.រ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការតែងតាំងលោក **ពេញ វិបុល** អគ្គនាយករង

នៃអគ្គនាយកដ្ឋានកិច្ចការអេយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ ជាសមាជិកបន្ថែមក្រុមការងារកិច្ចការយុត្តិធម៌របស់ គ.ជ.ប.ជ។

- o សេចក្តីសម្រេចកែសម្រួលសមាសភាពក្រុមការងារការពារជនរងគ្រោះលេខ០៣៦/១៧ ស.ស.រ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការតែតាំង លោកស្រី **ព្រុំ សុខន** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាសមាជិកបន្ថែមក្រុមការងារការពារជនរងគ្រោះ។ និងគណៈកម្មាធិការ **គ.រ.ប.ជ និង គ.ខ.ប.ជ** បានកែសម្រួលសមាសភាពមន្ត្រីស្រុក និងមន្ត្រីឃុំ សង្កាត់ ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រួមមាន៖ រាជធានីភ្នំពេញ កណ្តាល ស្វាយរៀង សៀមរាប កំពង់ធំ ព្រះសីហនុ មណ្ឌលគិរី ឧត្តរមានជ័យ ព្រះសីហនុ និងខេត្តព្រះវិហារ។
- o សេចក្តីសម្រេច លេខ ០៧៧/១៧ សសរ ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការប្រគល់ភារកិច្ច ជូនលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីដឹកនាំការងារគ្រប់គ្រងលំហូរពលករទេសន្តប្រវេសន៍មិនប្រក្រតីតាមព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។
- o សេចក្តីសម្រេច លេខ១៦៨/១៧ សសរ ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១៧ ស្តីពីការបង្កើតក្រុមការងារ ទទួលពលករ ពលការិនី ខុសច្បាប់មកពីប្រទេសថៃ។

- **ក្រសួងយុត្តិធម៌**បានអនុម័ត បញ្ចូលឯកសារបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់អាស៊ានសម្រាប់ព្រះរាជអាជ្ញា និងតុលាការ ដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ។

### ក.១.៣-អនុស្សរណៈ

❖ **អនុស្សរណៈដែលបានចុះហត្ថលេខា**

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង**០២**គឺ
  - o អនុស្សរណៈនៃការយោគយល់គ្នា ស្តីពី"**កិច្ចសហប្រតិបត្តិការលើវិស័យការងារ (ជ្រើសរើស និងគ្រប់គ្រងពលករ)**" រវាងអគ្គនាយកដ្ឋាន នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា និងសមាគមអភិវឌ្ឍន៍ធនធានមនុស្ស នៅតំបន់រដ្ឋបាលពិសេសហុងកុង (ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧)។
  - o អនុស្សរណៈនៃការយោគយល់គ្នា ស្តីពី"**កិច្ចសហប្រតិបត្តិការលើវិស័យការងារ**" រវាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការងារជនពិការ និងសង្គមកិច្ច នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម (ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៧)។
- **ក្រសួងយុត្តិធម៌** បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង**០២**គឺ
  - o ផែនការការងារសហប្រតិបត្តិការ ឆ្នាំ២០១៧-២០១៨ រវាងក្រសួងយុត្តិធម៌កម្ពុជា និងក្រសួងយុត្តិធម៌វៀតណាម (ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧)។
  - o អនុស្សរណៈ នៃការយោគយល់គ្នា រវៀងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការកម្ពុជា និងបណ្ឌិតសភាតុលាការវៀតណាម (ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៧)។

❖ អនុស្សរណៈកំពុងរៀបចំ

- **គណៈកម្មាធិការជាតិ គ.ជ.ប.ជ** ត្រៀមចុះហត្ថលេខា ៖
  - o លើអនុស្សរណៈនៃការយោគយល់គ្នាជាមួយ ប្រទេសឥណ្ឌា ស្តីពី "**កិច្ចសហប្រតិបត្តិការបង្ការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស**" ។
  - o ជាមួយអង្គការអន្តរជាតិ GVC ស្តីពីការគាំទ្រ និងការតស៊ូមតិលើសិទ្ធពលករទេសន្តរប្រវេសន៍កម្ពុជាក្នុងប្រទេសថៃ ដើម្បីទប់ស្កាត់ការរំលោភបំពានអំពើជួញដូរមនុស្ស។
- **ក្រសួងទេសចរណ៍** ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។

## ខ.ការបង្ការទប់ស្កាត់

អាស្រ័យដោយមានការប្រែប្រួលគោលនយោបាយក្នុងប្រទេសថៃ ក្នុងការរឹតបន្តឹងច្បាប់អន្តោប្រវេសន៍ និងច្បាប់ការងារថៃ ពលករកម្ពុជា ដែលមួយចំនួនធំ បានឆ្លងដែនចូលទៅធ្វើការដោយខុសច្បាប់ គ្មានឯកសារត្រឹមត្រូវ បានប្រឈមនឹងការបញ្ជូនត្រឡប់ ជាបន្តបន្ទាប់ ។

- ក្រុមការងារនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដឹកនាំដោយលោកជំទាវ ជូប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានចុះសិក្សា ពិនិត្យស្ថានភាពតាមច្រកព្រំដែល ក្នុងខេត្តបាត់ដំបង ប៉ៃលិន និងបន្ទាយមានជ័យ អំពីលំហូរមិនប្រក្រតីឆ្លងកាត់ព្រំដែន ដែលនាំឲ្យមានកំណើនពលករខុសច្បាប់នៅក្នុងប្រទេសថៃ និងពិនិត្យលទ្ធភាព ក្នុងការរៀបចំសាងសង់មណ្ឌលសំចតបណ្តោះអាសន្ន សម្រាប់ទទួលពលករ ដែលត្រូវបានបញ្ជូនត្រឡប់ ឬវិលត្រឡប់ពីប្រទេសថៃ ។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើកិច្ចការជាច្រើន ដែលជាការងារទប់ស្កាត់ដោយប្រយោលនៃលំហូរពលកម្មចេញទៅក្រៅប្រទេស តាមរយៈការលើកកម្ពស់លក្ខខណ្ឌនៅកន្លែងធ្វើការងារឱ្យបានកាន់តែល្អប្រសើរដោយបានតម្លើងប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០១៧ ពីចំនួន១៥៣ដុល្លាអាមេរិក ទៅ១៧០ដុល្លាអាមេរិក ក្នុងឆ្នាំ២០១៨ ពិសេសសម្រាប់កម្មករផ្នែកវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើង ដោយមិនគិតបញ្ចូលពីប្រាក់កម្រៃផ្សេងៗទៀត។ ការអនុវត្តន៍របបសន្តិសុខសង្គម ដែលបច្ចុប្បន្នកំពុងអនុវត្តរបបគ្រោះថ្នាក់ការងារ របបថែទាំសុខភាព និងកំពុងរៀបចំដំណើរការរបបសោធននិវត្តន៍សម្រាប់កម្មករ វិស័យឯកជន។ បានចូលរួមយ៉ាងសកម្មក្នុងការអប់រំណែនាំដល់កម្មករនិយោជិតអំពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ ដើម្បីអប់រំពលរដ្ឋ និងកម្មករនិយោជិតឱ្យងាកមកមើលឃើញអំពីគុណប្រយោជន៍ជាចម្បងៗនាពេលបច្ចុប្បន្ន និងទៅអនាគត នៃការងារនៅក្នុងប្រទេស។ និង
  - ➢ បានអនុញ្ញាតឱ្យក្រុមហ៊ុនឯកជនចំនួន**៨៥** ធ្វើការជ្រើសរើសបញ្ជូនពលករទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេស ដែលមានពលករសរុបចំនួន**៣០,៤៨១**នាក់ (ស្រី **១២,៥៣២**នាក់) ។

### ខ.១-ការគ្រប់គ្រងភ្នាក់ងារឯកជនជ្រើសរើសពលករ ៖

❖ ក្នុងចំណោមក្រុមហ៊ុនឯកជនចំនួន**៨៥**ក្រុមហ៊ុន បានធ្វើការជ្រើសរើស និងបញ្ជូនពលករទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេស សរុបចំនួន**២៥.៤៨៧**នាក់(ស្រីចំនួន**១០.៩៤៦**នាក់) និងបានបញ្ជូនទៅប្រទេស៖

- o ទៅប្រទេសថៃឡង់ដ៍ ចំនួន**២៣.៧៥០**នាក់ (ស្រី**៩.៩៨៨**នាក់)
- o ទៅប្រទេសជប៉ុន ចំនួន**១.៦៧៤**នាក់ (ស្រី**៨៩៥**នាក់)

o ប្រទេសសិង្ហបុរី ចំនួន៦៣នាក់(ស្រី)

❖ និងបានបញ្ជូនពលករទៅធ្វើការនៅប្រទេសកូរ៉េតាមប្រព័ន្ធអនុគ្រោះមុខរបរ (EPS) បានចំនួន **៤,៩៩៤** នាក់(ស្រី **១,៥៨៦**នាក់) (គិតត្រឹមថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧)។

**ខ.២-ការគ្រប់គ្រងក្រុមហ៊ុនឯកជន ដែលមានពលករបរទេសបម្រើការងារ ៖**

**យោងតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ការគ្រប់គ្រងជនបរទេសតាមសហគ្រាស និងគ្រឹះស្ថាននានាតាមបណ្តា រាជធានី/ខេត្ត** ក្នុងវិស័យវិនិយោគឯកជននៅតាមក្រុមហ៊ុននានា បានវិនិយោគលើវិស័យធំៗ ចំនួន០៤ គឺមានវិស័យៈ (រោងចក្រ សហគ្រាសចំនួន**១.៦៧០** ក្រុមហ៊ុន ,វិស័យកសិកម្មចំនួន**១៩៣**ក្រុមហ៊ុនវិស័យទេសចរណ៍ចំនួន**១៥៨**ក្រុមហ៊ុន និងវិស័យហេដ្ឋារចនាសម្ព័ន្ធចំនួន**១៣១**ក្រុមហ៊ុន ដែលមានសរុប ចំនួន**២.១៥២**ក្រុមហ៊ុន ក្នុងនោះពលករបរទេសសរុបចំនួន**២៥.៦៥២**នាក់ មាន៥៤សញ្ជាតិ (**របាយការណ៍ក្រុមការងារនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍**)។

**ខ.៣-កាត់បន្ថយគ្រោះថ្នាក់ដល់ជនមុខសញ្ញារងគ្រោះ៖**

ប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន០៥ គឺប៉ុស្តិ៍ ច្រកប៉ោយប៉ែត ច្រកដូង ច្រកព្រំ ច្រកអូរស្មាច់ និងច្រកជាំ បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ចំនួន**១៧៧.៣៦៤**ក្បាល ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន (**របាយការណ៍ក្រុមការងារនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍**)។ ក្រៅពីនោះយើងមានសកម្មភាព៖

- **ខេត្តបាត់ដំបង ក្រុមការងារលេខាធិការដ្ឋាន គ.ជ.ប.ជ** បានសហការជាមួយអង្គការសាម៉ារីតាន់ភឺស ផ្តល់សៀវភៅព័ត៌មាន ស្តីពីការធ្វើចំណាកស្រុក សម្រាប់ដោះស្រាយបញ្ហាមុនពេល និងកំពុងធ្វើចំណាកស្រុក។
- **ខេត្តកំពង់ចាម ស្នងការដ្ឋាននគរបាល** បានចលនាដល់បណ្តាញភ្នាក់ងាររ៉ឺម៉កកង់បីនិងម៉ូតូឌុបបិទស្លាក ដើម្បីសុវត្ថិភាពកុមារ បានចំនួន**៤៤កន្លែង** ព្រមទាំងបានបំពេញទម្រង់ពិនិត្យភ្នាក់ងារសុវត្ថិភាពកុមារ បានចំនួន០៩នាក់។
- **ខេត្តព្រៃវែង មន្ទីរសង្គមកិច្ច** សហការជាមួយអធិការដ្ឋាននគរបាលស្រុក និងប៉ុស្តិ៍នគរបាល បានធ្វើការចែកប័ណ្ណដែលមានលេខទូរស័ព្ទរបស់សមត្ថកិច្ច ជូនដល់ប្រជាពលរដ្ឋ ងាយស្រួលពួកគាត់ធ្វើការទំនាក់ទំនងមកសមត្ថកិច្ច ក្នុងការជួយសង្គ្រោះពួកគាត់ទាន់ពេល នៅពេលពួកគាត់ជួបបញ្ហាអសកម្ម ឬអំពើរំលោភបំពានផ្លូវភេទ និងអំពើជួញដូរមនុស្សជាដើម។

**ខ.៣-ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ:**

នៅក្នុងរយៈពេល១០ខែ ឆ្នាំ២០១៧នេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំកម្មវិធីវេទិកាអន្តរសាសនាថ្នាក់ជាតិនៅកម្ពុជា ពិធីសូត្រធម៌ អធិដ្ឋាន និងបញ្ជូនសារ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងបញ្ចប់ទាសភាពសម័យទំនើប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគ.ជ.ប.ជ** នៅមជ្ឈមណ្ឌលពិព័រណ៍កោះពេជ្រ ដែលមានអ្នកចូលរួមប្រមាណ**១.២០០អង្គ/នាក់** ។

ដោយឡែកស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាក ស្រុកដោយ

សុវត្ថិភាព និងវេទិកាសាធារណៈនៃការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំមានសុវត្ថិភាព**" ដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ បានចំនួន**៣៦.៦០៩**លើក មានអ្នកចូលរួមសរុបចំនួន**៣.៨៧៥.៨៨៧**នាក់ (ធៀបនឹងរយៈពេល១០ខែ ឆ្នាំ២០១៦ មានចំនួនត្រឹមតែ**២.៦៣៦.៩១៣**នាក់) កើនឡើងចំនួន**៨៣៩.២៩៤**នាក់ ស្មើនឹង **៣១,៨២%** ក្នុងនោះស្ត្រីមានចំនួន**១.៦៤៤.០៣៥**នាក់។ (**ឧបសម្ព័ន្ធទី១**)

### ខ.៤-សកម្មភាពអប់រំតាមសាលារៀន

លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ និងក្រសួងអប់រំ យុវជន និងកីឡា បានសហការរៀបចំការផ្សព្វផ្សាយការយល់ដឹង ស្តីពីការលើកកម្ពស់បរិស្ថានសិក្សា សមភាពយេនឌ័រ និងការប្រឆាំងអំពើជួញដូរមនុស្ស តាមសាលារៀន វិទ្យាល័យ អនុវិទ្យាល័យ សាលាគរុកោសល្យ មានលោកគ្រូ អ្នកគ្រូ និងទាំងសិស្សចូលរួមចំនួន៨៩៤នាក់ ក្នុងខេត្តចំនួន០៦គឺ ខេត្តកំពង់ឆ្នាំង កំពង់ចាម តាកែវ កណ្តាល បាត់ដំបង និងខេត្តព្រៃវែង។

### ខ.៥-ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន

- **ក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ** បានធ្វើលិខិតលេខ ១១១៣ កប/មហ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ជូនក្រសួងព័ត៌មាន ស្តីពីសំណើសុំជួយទប់ស្កាត់ការផ្សព្វផ្សាយព័ត៌មានបំភ្លើស ស្តីពីការជ្រើសរើសពលករខ្មែរទៅធ្វើការនៅបរទេស ដើម្បីទប់ស្កាត់ការយល់ខុសរបស់ប្រជាពលរដ្ឋ និងចាញ់បោកមេខ្យល់ ឬក្រុមហ៊ុនមិនស្របច្បាប់។
- **ក្រសួងកិច្ចការនារី** បានចូលរួមជាវាគ្មិន ក្នុងកិច្ចសន្ទនា តាមទូរទស្សន៍ជាតិកម្ពុជា ស្តីពីការលើកកម្ពស់ ការទទួលបានសិទ្ធិ និងកិច្ចគាំពារកុមារបម្លាស់ទី (រៀបចំដោយអង្គការ CAMBODIE ACTs )។
- **ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**
    - o សហការជាមួយចាងហ្វាងផលិតកម្មភាពយន្ត និងក្រុមហ៊ុននាំចេញ នាំចូលខ្សែភាពយន្តឯកជន ឲ្យដំឡើងសារអប់រំស្តីពីផលប៉ះពាល់នៃការជួញដូរមនុស្ស ការកេងប្រវ័ញ្ចលើកម្លាំងពលកម្មកុមារ និងការជួញដូរផ្លូវភេទក្នុងផលិតផលខ្សែភាពយន្ត ចម្រៀងកាយវិការ និងចម្រៀងខារ៉ាអូខេ។
    - o ផលិតស្នាដៃល្ខោននិយាយខ្លីជាវីឌីអូស្តីពីគ្រោះថ្នាក់នៃការជួញដូរមនុស្ស ការកេងប្រវ័ញ្ចលើកម្លាំងពលកម្មកុមារ ចំនួនពីរចំណងជើងជូនគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (១.វិលវិញ និង២.ខ្ញុំខុសរហូត)។
- **ក្រុមជំនួយកិច្ចការយុត្តិធម៌** ឯកឧត្តមអគ្គលេខាធិការរង គ.ជ.ប.ជ បានចូលរួមក្នុងកម្មវិធីការងារ និងជីវិត ជាវាគ្មិនវិទ្យុ VOD ផ្សាយផ្ទាល់ពិភាក្សា ប្រធានបទ "**ស្ត្រីបម្រើសេវាកម្សាន្តស្នើឲ្យមានច្បាប់ការពារ**" នៅស្ទូឌីយោវិទ្យុសារិកា FM106.5MHz។
- **លេខាធិការដ្ឋានគ.ខ.ប.ជខេត្ត** បានផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមប៉ុស្តិ៍វិទ្យុចំនួន**១៥៥**លើក (ខេត្តកោះកុង**១១៩**លើក, សៀមរាប**២៤**លើក, កំពង់ចាម**០៣**លើក បាត់ដំបង **០៥**លើក ក្រចេះ**០២**លើក និងកំពត**០១**លើក។
- **ខេត្តប៉ៃលិន** ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាល បានបិទផ្សព្វផ្សាយខ្លឹមសារច្បាប់ និងសេចក្តីណែនាំលេខ០៤៥ ស.ណ.ន ស្តីពីការបង្ការទប់ស្កាត់

អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ដល់គោលដៅដែលងាយរងគ្រោះដូចជា៖សណ្ឋាគារ ភោជនីយដ្ឋាន ផ្ទះសំណាក់ ហាងម៉ាស្សា កោសជប់ ហាងកាហ្វេ និងខារ៉ាអូខេទាំងអស់៨៩កន្លែង។

- **ខេត្តកំពត** ក្រុមការងារលេខាធិការដ្ឋានគ.ខ.ប.ជ បានសហការជាមួយមន្ត្រីជំនាញក្រុង/ស្រុក ឃុំ/សង្កាត់ បានធ្វើការផ្សព្វផ្សាយ ស្តីពីផលប៉ះពាល់នៃការធ្វើចំណាកស្រុក តាមរយៈការចាក់ផ្សាយឌីស "**ជើងមេឃនៅឯណា**"។

- **ខេត្តកំពង់ស្ពឺ** បានផលិតបដា ពាក្យស្លោក មួយចំនួនពាក់ព័ន្ធនឹងខ្លឹមសារនៃវិធានការច្បាប់ប្រយុទ្ធប្រឆាំងនិងអំពើជួញដូរមនុស្ស និងធ្វើការចងបដា ពាក្យស្លោកទាំងនោះ នៅខាងមុខមន្ទីរ អង្គភាព ស្ថាប័នពាក់ព័ន្ធ និងនៅតាមវិទ្យាល័យនានាទូទាំងខេត្ត ។

### ខ.៦-ទប់ស្កាត់ រារាំងតម្រូវការសេវាកម្ម ដែលទំនោរទៅរកការជួញដូរមនុស្ស

#### ខ.៦.១.-<u>វិធានការទប់ស្កាត់តាមជំនាញរបស់អគ្គស្នងការនគរបាលជាតិ</u>

កងកម្លាំងនគរបាល វរៈការពារព្រំដែនគោក និងនគរបាលប៉ុស្តិ៍ តាមបណ្តាច្រករបៀងនៅខេត្តជាប់ព្រំដែនកម្ពុជា-ថៃ បានធ្វើការទប់ស្កាត់ប្រជាពលរដ្ឋខ្មែរបម្រុងធ្វើចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសថៃ ដោយមិនស្របច្បាប់ ឬតាមរយៈមេខ្យល់។ ក្រោយពីពេលធ្វើការសាកសួរ អប់រំ ណែនាំ និងបានធ្វើកិច្ចសន្យារួច ហើយ កម្លាំងជំនាញបានណែនាំឲ្យពួកគាត់វិលទៅរកលំនៅដ្ឋានវិញ មានដូចតារាងខាងក្រោម ៖

**តារាងសកម្មភាពបង្ការ និងទប់ស្កាត់**

| ល.រ | ឈ្មោះអង្គភាព និង លេខាធិការដ្ឋាន គ.ខ.ប.ជ | សកម្មភាពទប់ស្កាត់ | ចំនួនលើក | ចំនួនរួម | ស្រី | អនីតិជន |
|---|---|---|---|---|---|---|
| ១ | អគ្គបញ្ជាការដ្ឋាន ទីចាត់ការព្រំដែន | - បានធ្វើការបង្ការ ទប់ស្កាត់សកម្មភាពពលករខ្មែរ ដែលធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ។ | ០២ | ២១ | | |
| ២ | ខេត្តបន្ទាយមានជ័យ | - កម្លាំងនគរបាលប៉ុស្តិ៍គោករមៀត ប៉ុស្តិ៍អូរជ្រៅជាន់ និង វរៈនគរបាលការពារព្រំដែនគោកលេខ (៩១១ និង៨០៧) បានទប់ស្កាត់ពលករខ្មែរដែលធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ។ | ២១ | ៦៨៧ | ២៥៣ | ៤៩ |
| ៣ | ខេត្តបាត់ដំបង | - វរៈនគរបាលការពារព្រំដែនគោកលេខ(៨១៧, ៨១៩, ៨២៣ និង៣១០) បានទប់ស្កាត់ពលករខ្មែរ ដែលធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ។ | ០៤ | ៣៥ | ០៩ | |
| ៤ | ខេត្តប៉ៃលិន | - បានទប់ស្កាត់ប្រជាពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ នៅចំណុចផ្សារព្រំជាប់ព្រំដែន។ | ០១ | ៥៨ | ២៦ | ០៥ |
| ៥ | ខេត្តព្រះវិហារ | - ស្នងការដ្ឋាននគរបាលខេត្ត បានធ្វើការបង្ការ ទប់ស្កាត់ពលករខ្មែរដែលធ្វើ ចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ។ | ០១ | ២៨ | | |
| សរុប | | | ២៩ | ៨២៩ | ២៨៨ | ៥៤ |

#### ខ.៦.២-<u>វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ៖</u>

ក្នុងរយៈពេល១០ខែ ឆ្នាំ២០១៧នេះ អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍ពីក្រុមការងារអនុវត្តច្បាប់) និងស្នងការរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- ស្រង់ស្ថិតិ ទិន្នន័យ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញារកម្ម និងផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងស្ត្រី-បុរសធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន**៤៩៦**គោលដៅ មានមនុស្សចំនួន**១.៩៧៨**នាក់ (ស្រី**១.៦៦៨**នាក់) **កម្លាំងជំនាញអនុវត្ត នៃស្នងការដ្ឋាននគរបាលខេត្ត មាន៖** (តាកែវ ព្រះវិហារ កណ្តាល កែប កំពត មណ្ឌលគិរី ស្ទឹងត្រែង រតនគិរី កោះកុង និងក្រចេះ)។
- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្សចំនួន**០៩**គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន**៦៦**គោលដៅ សរុបចំនួន**៧៥**គោលដៅ ទូទាំងរាជធានី-ខេត្ត។
- ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន**១៥៨**លើក ខេត្តអនុវត្តន៍មាន ខេត្តសៀមរាប ស្វាយរៀង ពោធិ៍សាត់ កំពង់ធំ និងខេត្តកំពង់ស្ពឺ។
- **ខេត្តព្រះសីហនុ** ស្នងការដ្ឋាននគរបាល និងអង្គការម្លប់តាប៉ាង បានចុះចលនាដាក់បណ្តាញភ្នាក់ងារចំនួន**៦៣៣**នាក់ ដើម្បីធ្វើការពាក់ព័ន្ធសុវត្ថិភាពកុមារ លើក្រុមម៉ូតូឌុប ក្រុមម៉ូតូកង់បី បណ្តាញសហគមន៍ បណ្តាញអ្នកលក់តាមឆ្នេរសមុទ្រ បុគ្គលិកតាមផ្ទះសំណាក់ និងសណ្ឋាគារ។

**ខ.៧-គោលនយោបាយប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់ និងគ្រោះថ្នាក់**

ខ.៧.១-<u>វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក</u>

- *បច្ចុប្បន្នភាពស្ថិតិចំណាកស្រុក*

បច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស ប្រចាំខែនីមួយៗ បានពិនិត្យឃើញថា នៅតែបន្តកើតមានឡើង ជាក់ស្តែងក្នុងរយៈពេល១០ខែ ឆ្នាំ២០១៧នេះ តួលេខមានដូចក្នុងតារាងខាងក្រោម៖

***តារាងតាមដានបច្ចុប្បន្នភាពទិន្នន័យពលករខ្មែរចំណាកស្រុក ប្រចាំខែនីមួយៗ ក្នុងរយៈពេល១០ខែ ឆ្នាំ២០១៧***

| ប្រចាំខែ | សរុបរួម | | | | ស្របច្បាប់ | | | | មិនស្របច្បាប់ | | | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | |
| | | | សរុប | ស្រី | | | សរុប | ស្រី | | | សរុប | ស្រី | |
| មករា | ៣២០.៤៣៧ | ១៤៤.៩៣៩ | ៨.៤៦៩ | ៣.៣០៤ | ១៧៩.៥៧២ | ៨៧.៥១៩ | ៦៨៨ | ២៧៧ | ១៤០.៨៦៥ | ៥៧.៤២០ | ៧.៧៨១ | ៣.០២៧ | កើន ១.៩០៤ |
| កុម្ភៈ | ៣១៩.២៤៧ | ១៤០.២០១ | ៧.៩៦៥ | ៣.០៥៤ | ១៧៩.៨៣១ | ៨៣.៦៥៥ | ៥៨៩ | ២៤៤ | ១៣៩.៤១៦ | ៥៦.៥៤៦ | ៧.៣៧៦ | ២.៨១០ | ថយចុះ ១.១៩០ |
| មីនា | ៣២១.១៥៩ | ១៤០.៥០៧ | ៧.៨៩៤ | ៣.០១៤ | ១៨០.៧១២ | ៨៣.៨១៦ | ៥៨៩ | ២៤៤ | ១៤០.៤៤៧ | ៥៦.៦៩១ | ៧.៣០៥ | ២.៧៧០ | កើន ១.៩១២ |
| មេសា | ៣២៣.៨១៨ | ១៤០.០០២ | ៨.៦៤៤ | ៣.៤៤៤ | ១៨៣.៩០៤ | ៨៣.៨៣៩ | ១.៣០៨ | ៥៧៧ | ១៣៩.៩១៤ | ៥៦.១៦៣ | ៧.៣៣៦ | ២.៨៦៧ | កើន ២.៦៥៩ |
| ឧសភា | ៣២៣.៦២៨ | ១៣៩.៩៤៧ | ៨.៧២៤ | ៣.៤៨១ | ១៨៤.៣៣៧ | ៨៤.២៥០ | ១.៣០១ | ៥៧៧ | ១៣៩.២៩១ | ៥៥.៦៩៧ | ៧.៤២៣ | ២.៩០៤ | ថយចុះ ១៩០ |
| មិថុនា | ៣៣០.២៦៧ | ១៧០.៥៨៦ | ៨.៧៣៤ | ៣.២២៩ | ១៨៦.០៩០ | ៨៥.០៤៩ | ៥៩៧ | ២៤៧ | ១៤៤.១៧៧ | ៨៥.៥៣៧ | ៨.១៣៧ | ២.៩៨២ | កើន ៦.៦៣៩ |
| កក្កដា | ៣២៦.៧៩៩ | ១៤១.០៦៧ | ៩.១០២ | ៣.៤៣២ | ១៨៦.២៧៨ | ៨៤.៣៦០ | ១.២០៧ | ៥៥៣ | ១៤០.៥២១ | ៥៦.៧០៧ | ៧.៨៩៥ | ២.៨៧៩ | ថយចុះ ៣.៤៦៨ |
| សីហា | ៣២៧.៦៣៨ | ១៤១.៧៩៤ | ៩.១០២ | ៣.៣៩៨ | ១៨៦.៨២៨ | ៨៤.៩៨១ | ១.២២៣ | ៥៦០ | ១៤០.៨១០ | ៥៦.៨១៣ | ៧.៨៧៩ | ២.៨៣៨ | កើនឡើង ៨៣៩ |
| កញ្ញា | ៣១៧.១៨២ | ១៤២.២៥៤ | ៩.០៧៤ | ៣.៤២១ | ១៧៥.៤៩៧ | ៨៥.៣៣២ | ១.១៨១ | ៥៥០ | ១៤១.៦៨៥ | ៥៦.៩២២ | ៧.៨៩៣ | ២.៨៦៧ | ថយចុះ ១០.៤៥៦ |
| តុលា | ៣១៥.៥៦១ | ១៤១.៣១៨ | ៩.០៧១ | ៣.៤២៨ | ១៧៤.៧៦៨ | ៨៤.៨៤២ | ១.១៩១ | ៥៥៩ | ១៤០.៧៩៣ | ៥៦៤៧៦ | ៧.៨៨០ | ២.៨៦៩ | ថយចុះ ១.៦២១ |

### ប្រៀបធៀបពលករចំណាកស្រុក ក្នុងរយៈពេល១០ខែ ឆ្នាំ២០១៦ និងឆ្នាំ២០១៧

| ប្រចាំខែ | ១០ខែ ឆ្នាំ២០១៦ | | | | ១០ខែ ឆ្នាំ២០១៧ | | | |
|---|---|---|---|---|---|---|---|---|
| | ចំនួនរួម | ស្រី | អនីតិជន | | ចំនួនរួម | ស្រី | អនីតិជន | |
| | | | សរុប | សរុប | | | សរុប | ស្រី |
| មករា | ៤៩០.៤០៧ | ២១៧.០៣១ | ១២.០០៣ | ៤.៥៨០ | ៣២០.៤៣៧ | ១៤៤.៩៣៩ | ៨.៤៦៩ | ៣.៣០៤ |
| កុម្ភៈ | មិនមានរបាយការណ៍ | | | | ៣១៩.២៤៧ | ១៤០.២០១ | ៧.៩៦៥ | ៣.០៥៤ |
| មីនា | ២៩៧.៤៩៦ | ១៣០.១៤០ | ៣.៣៦៦ | ២.០៣២ | ៣២១.១៥៩ | ១៤០.៥០៧ | ៧.៨៩៤ | ៣.០១៤ |
| មេសា | ២៩១.០៨៤ | ៦១.៩០៩ | ៦.០៧០ | ២.៣៩១ | ៣២៣.៨១៨ | ១៤០.០០២ | ៨.៦៤៤ | ៣.៤៤៤ |
| ឧសភា | ២៩០.៧២៤ | ១២៨,៩៦៧ | ៥,៦៦៤ | ២.២៤០ | ៣២៣.៦២៨ | ១៣៩.៩៤៧ | ៨.៧២៤ | ៣.៤៨១ |
| មិថុនា | ២៩៩.២៥៤ | ១៣០.២០២ | ៥.៨១៧ | ២.២៦២ | ៣៣០.២៦៧ | ១៧០.៥៨៦ | ៨.៧៣៤ | ៣.២២៩ |
| កក្កដា | ៣០១.៨០៦ | ១៣៧.៥០០ | ៥.៧៥១ | ២.២២៥ | ៣២៦.៧៩៩ | ១៤១.០៦៧ | ៩.១០២ | ៣.៤៣២ |
| សីហា | ៣០២.២៩៥ | ១៣៦.៧៦២ | ៥.៨១៣ | ២.២៤៧ | ៣២៧.៦៣៨ | ១៤១.៧៩៤ | ៩.១០២ | ៣.៣៩៨ |
| កញ្ញា | ៣០៩.០៥៦ | ១៤១.៦២១ | ៥.៧៣៥ | ២.២៣០ | ៣១៧.១៨២ | ១៤២.២៥៤ | ៩.០៣៤ | ៣.៤២១ |
| តុលា | ៣១៣.២៨៥ | ១៤១.៦៩៥ | ៦.២០៨ | ២.៣៦៩ | ៣១៥.៥៦១ | ១៤១.៣១៨ | ៩.០៧១ | ៣.៤២៨ |

### ខ.៧.២-ការតាមដានស្ថិតិពលករ ដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេសតាមច្រកព្រំដែន

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានទទួលពលរដ្ឋខ្មែរដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកវិញមានចំនួន**២.២០៥**លើក មនុស្សចំនួន**១១៦.០០៥**នាក់ (ស្រី**៥២.៣៤០**នាក់ និងកុមារ**៦.៧៣១**នាក់) ក្នុងនោះតាមច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិចំនួន**២៩៦**លើក មនុស្សចំនួន**៧៦៣**នាក់ ស្រី**៣៥៥**នាក់ តាមច្រកទ្វារព្រំដែនកម្ពុជា-ថៃចំនួន**១.៨៧៦**លើក មនុស្សចំនួន**១១៤.៩៥៨នាក់** (ស្រី**៥១.៩២៨**នាក់ កុមារ**៦.៧៣១**នាក់) ប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិបាវិត ចំនួន**០៥**លើក មនុស្សចំនួន**២៣**នាក់ ស្រី**១៧**នាក់ និងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិព្រៃវ៉ែ្លចំនួន**០២**លើក មនុស្សចំនួន**២០**នាក់ ស្រី**១៤**នាក់ ។

  *ស្ថានភាព ៖*

  - ក្រុមអនុវត្តច្បាប់បានរាយការណ៍ថា មានពលរដ្ឋខ្មែរចំនួន**៥.៣០៦**នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ និងឃាត់ខ្លួនលើសពីរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ។
  - **ទីចាត់ការការងារព្រំដែន នៃអគ្គបញ្ជាការដ្ឋានក្រសួងការពារជាតិ** បានទទួលសពពលរដ្ឋខ្មែរពីអាជ្ញាធរថៃចំនួន**១៥៨**លើក សរុបចំនួន**១៦២**សព (ស្រី**២៩**សព)។
  - **ខេត្តបន្ទាយមានជ័យ** អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោមរូបភាព «**និរទេស**» តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុបមានចំនួន**១.៤៧៨**ជើង/រថយន្ត មានមនុស្សចំនួន**៦៥.៨២៥**នាក់ (ស្រី**២៣.១៥១**នាក់) ក្នុងនោះកុមារ**៦.៤៤១**នាក់ (កុមារី**២.៧៧០**នាក់) បើប្រៀបធៀបនឹងរយៈពេល១០ខែ ឆ្នាំ២០១៦ ពលរដ្ឋខ្មែរមានចំនួនតែ**៣៥.៨២៣**នាក់ (កើនឡើង**៣០.០០២**នាក់ ស្មើនឹង**៨៣.៧៥%**)។
    - ចេញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតមានចំនួន**២៦.០៨២**នាក់ តាមច្រករបៀងមាន**៣៩.៧៤៣**នាក់ ក្នុងនោះចេញដោយខ្លួនឯងមាន**២៩.៤៨៦**នាក់ និងតាមគេនាំមាន**៣៦.៣៣៩**នាក់។

- តាមការសម្ភាសន៍៖ កុមារ៧៣៩នាក់ (កុមារី២៨០នាក់) ទៅតាមឪពុកម្តាយ៤៧៣នាក់ និង២៦៦នាក់ ទៅតាមបងប្អូន។

- **ដោយឡែក យោងតាមរបាយការណ៍អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានរកឃើញជនបរទេសដែលមកធ្វើនៅក្នុងប្រទេសកម្ពុជាដោយខុសច្បាប់ និងត្រូវបណ្តេញចេញៈ

- **លួចឆ្លងដែនស្នាក់នៅធ្វើការខុសច្បាប់ និងគ្មានលិខិតឆ្លងដែនៈ** ចំនួន១០៧២នាក់ (ស្រី២១៥នាក់) មាន២៦សញ្ជាតិ ក្នុងនោះ៖(វៀតណាម៨៦៩នាក់ ស្រី២១៥នាក់ កុមារ០៨នាក់, ចិនដីគោក៩១នាក់ នីហ្សេរីយ៉ា៤៧នាក់, កូរ៉េខាងត្បូង០៨នាក់, ឥណ្ឌា០៨នាក់, អង់គ្លេស០៧នាក់, អាមេរិក០៧នាក់ ហ្វីលីពីន០៤នាក់, កូឡុំប៊ី០២នាក់, កាណាដា០៣នាក់, រុស្ស៊ី០២នាក់, បារាំង០២នាក់, ជប៉ុន០១នាក់ សាំងហ្គាពួ០១នាក់, ថៃ០១នាក់, ហ្គាណា០១នាក់, អាហ្វ្រិកខាងត្បូង០១នាក់, អាឡឺម៉ង់០១នាក់ ប៊ូតាន០១នាក់, អ៊ុយបេគីស្ថាន០១នាក់, ហ្វាំងឡង់០១នាក់, អ៊ុយក្រែន០២នាក់, កាម៉េរ៉ូន០១នាក់ កូឌីវ័រ០១នាក់ ម៉ុងតាញ៉ា០៧នាក់ និងបេឡារ៉ុស០២នាក់) ក្នុងករណីខាងលើ មុននឹងបញ្ជូនចេញទៅប្រទេសដើមវិញ ត្រូវបានបោះត្រាហាមចូលប្រទេសកម្ពុជាលើលិខិតឆ្លងដែន។
- **យោងតាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ការគ្រប់គ្រងជនបរទេសតាមសហគ្រាស និងគ្រឹះស្ថាននានាតាមបណ្តារាជធានី/ខេត្ត** ក្នុងវិស័យវិនិយោគឯកជន ដែលមានក្រុមហ៊ុនចំនួន២១៥២ក្រុមហ៊ុន មានពលករបរទេសសរុបចំនួន២៥.៦៥២នាក់ មាន៥៤សញ្ជាតិ **៖ មានប័ណ្ណការងារៈ** ចំនួន២៤.៥៩៤នាក់ និង**គ្មានប័ណ្ណការងារៈ** ចំនួន១.០៥៨នាក់ ដោយមានការផាកពិន័យជាប្រាក់ទៅតាមច្បាប់អន្តោប្រវេសន៍នៃព្រះរាជាណាចក្រកម្ពុជា។
- **ករណីឆបោក ជួញដូរមនុស្សឆ្លងដែន និងក្លែងឯកសារសាធារណៈ (ដោយ**ជនជាតិនីហ្សេរីយ៉ា០៧នាក់) និងជួញដូរមនុស្ស (ជនជាតិវៀតណាម០៣នាក់)។
- **បង្ខាំងមនុស្សខុសច្បាប់សរុបចំនួន០៩នាក់** (សញ្ជាតិវៀតណាម០៨នាក់ និងសញ្ជាតិអាមេរិក០១នាក់)
- **រៀបអាពាហ៍ពិពាហ៍ខុសច្បាប់សរុបចំនួន០៤នាក់** មានសញ្ជាតិចិន០១នាក់ អាមេរិក ០១នាក់ នេបាល់ ០១នាក់ និងសញ្ជាតិអូស្ត្រាលី០១នាក់។

### ខ.៨-ការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជានៅក្រៅប្រទេស

យោងតាមរបាយការណ៍ របស់ប្រធានគណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា លេខ ០១៤/១៧ គ.ផ.ថ ចុះថ្ងៃទី ០៤ ខែឧសភា ឆ្នាំ២០១៧ បានឲ្យដឹងថា៖

- តាមរយៈជំរឿនលើកទី១ កាលពីខែតុលាឆ្នាំ២០១៤ និងជំរឿនកាលពីខែកញ្ញាឆ្នាំ២០១៦ រកឃើញពលករខ្មែរដែលកំពុងស្នាក់នៅ និងធ្វើការក្នុងប្រទេសថៃ សរុបចំនួនប្រមាណ**១.០៤៤.១១៥នាក់** (ក្នុងនោះមានអ្នកនៅក្នុងបន្ទុកចំនួន៤១,៣៥៨នាក់)។ ភាគីថៃបានផ្តល់បណ្ណ័ស៊ីជម្ពូដល់ពលករកម្ពុជា និងពលករកម្ពុជាផ្នែកនេសាទចំនួនប្រមាណជា៤៧,០០០នាក់ ដែលនឹងផុតសុពលភាពប័ណ្ណពណ៌ស៊ីជម្ពូ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ខាងមុខនេះ ហើយត្រូវធ្វើប័ណ្ណស៊ីជម្ពូជាថ្មី និងត្រូវបង់ថ្លៃ៣៥០០បាត។ ថៃទុកពេលមួយខែ សម្រាប់អ្នកចុះបញ្ជីថ្មី និងអ្នកដែលសុំផ្លាស់ប្តូរកន្លែងការងារ ឬប្តូរថៅកែ ត្រូវបង់បន្ថែមប្រមាណពី១០០០បាត ទៅ២០០០បាតទៀត។

- គិតត្រឹមខែមេសាឆ្នាំ២០១៧ ពលករកម្ពុជាដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ទាំងអ្នកស្របច្បាប់ អ្នកស្របច្បាប់បណ្តោះអាសន្ន និងអ្នកខុសច្បាប់ ដែលទើបឆ្លងទៅប្រទេសថៃក្រោយការធ្វើជំរឿនរបស់ភាគីថៃ មានចំនួនសរុបប្រមាណ**១.០៥៦.៣៥៨នាក់** (ស្រីប្រមាណ**៤២០.០០០**នាក់ និងអ្នកខុសច្បាប់មានប្រមាណ **៣១០.០០០**នាក់)។
- គិតចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤ ដល់សប្តាហ៍ទីមួយខែឧសភា ឆ្នាំ២០១៧នេះ គណៈកម្មការផ្តល់ភាពស្របច្បាប់ បានបើកផ្តល់សំណុំលិខិតផ្តល់ភាពស្របច្បាប់ ដល់ពលករបានចំនួន**៦១.២១៣**នាក់ ក្នុងនោះមានលិខិតឆ្លងដែន/លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (TD) និងប័ណ្ណពលករកម្ពុជាធ្វើការនៅបរទេស (OCWC)។ សូមបញ្ជាក់ថា កន្លងមកមូលហេតុយឺតយ៉ាវដោយសារដំណាក់កាលទី១ ភាគីថៃ បើកដំណើរការផ្តល់សំណុំលិខិតតាមច្រកចេញចូលតែមួយ នៅទូទាំងប្រទេសថៃតែមួយកន្លែងគត់(ក្នុងខេត្តសាមុតប្រាកាន)។ តែបច្ចុប្បន្នភាគីថៃ បើកដំណើរការផ្តល់សំណុំលិខិតតាមខេត្តចំនួន**០៣**ទៀត ហើយអាចបំពេញសំណុំលិខិតផ្តល់ភាពស្របច្បាប់នេះតាមប្រព័ន្ធអនឡាញក៏បាន និងអាចមកស្ថានទូតខ្មែរប្រចាំទីក្រុងបាងកកក៏បាន។

### ខ.៩-ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរនិងជនបរទេស

ក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ជាពិសេស នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានធ្វើការសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសចំនួន**១.១៩៨**គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ ដើម្បីតាមដានស្ថានភាពដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

### ខ.១០-ការចុះអធិការកិច្ចដើម្បីការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះធ្វើអធិការកិច្ចការងារលើ សហគ្រាស គ្រឹះស្ថាន ដើម្បីពិនិត្យលក្ខខណ្ឌការងារ របស់កម្មករវ័យក្មេង ទប់ស្កាត់ពលកម្មកុមារ ចាត់វិធានការចំពោះសហគ្រាស គ្រឹះស្ថានដែលប្រព្រឹត្តល្មើសច្បាប់ និងបានដកហូតកុមារពីទម្រង់ធ្ងន់ធ្ងរ បានចំនួន**២៤០**នាក់ កុមារី**៩៩**នាក់ ។
- **ខេត្តសៀមរាប មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានចុះអធិការកិច្ចពលកម្មកុមារនៅតាមឡឥដ្ឋចំនួន**២០**ឡឥដ្ឋ នៅស្រុកចំនួន**០៣** គឺស្រុកក្រឡាញ់ ស្រុកអង្គរធំ និងស្រុកបន្ទាយស្រី (**០២**កន្លែងត្រូវបានបិទ) សរុបរកឃើញមនុស្សចំនួន**៥១៧**នាក់ មានស្រី**២៥៧**នាក់ និងមានកុមារចំនួន**២៣៥**នាក់ មានកុមារី**១១០**នាក់។ ការស្រង់ស្ថិតិឡឥដ្ឋផ្សេងទៀត បាន**៤៦**កន្លែង (កំពុងដំណើរការតែ**៣៧**កន្លែង បិទដំណើរការ**០៣**កន្លែង និងផ្អាក**០៥**កន្លែង រកឃើញកម្មករសរុប**៧៨៧**នាក់ មានស្រី**៣៨០**នាក់)។

## គ.ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១-ការងារអនុវត្តច្បាប់

គ.១.១-ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ១៦ មានៈ រាជធានីភ្នំពេញ បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កណ្ដាល ក្រចេះ មណ្ឌលគិរី ព្រះវិហារ ពោធិ៍សាត់ រតនគិរី សៀមរាប ព្រះសីហនុ ស្វាយរៀង ឧត្ដរមានជ័យ និងខេត្តតាកែវ បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន **១៣៩**/**៧០**ករណី (បើប្រៀបធៀបនឹងរយៈពេល១០ខែ ឆ្នាំ២០១៦ មានការកើនឡើងចំនួន**៦៩**ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូង បានចំនួន**១៨១**/**៨៩**នាក់ (កើនឡើងចំនួន**៩២**នាក់) ស្រី**៥៥**នាក់ (ជនសង្ស័យជាអនីតិជន**១២**នាក់) និងជនបរទេសចំនួន**១២**នាក់ មានជប៉ុន**០១**នាក់, វៀតណាម**០២**នាក់, ហូឡង់**០២**នាក់, ចិន**០៤**នាក់, អាមេរិក**០១**នាក់, រុស្ស៊ី**០១**នាក់ និងអង់គ្លេស**០១**នាក់។ សង្គ្រោះជនរងគ្រោះសរុបបានចំនួន**២៧៧**/**១៨៩**នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំ**១១៣**នាក់ អាយុពី១៥-១៧ឆ្នាំ**៣២**នាក់ និងអាយុ១៨ឆ្នាំឡើង**១៣២**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន**៩៦**នាក់ អង្គការចំនួន**០៥**នាក់ និងគ្រួសារវិញចំនួន**១៧៦**នាក់)។

**១.ករណីអំពើជួញដូរមនុស្ស៖**

បង្ក្រាបបាន**៤៣**/**២២ករណី** (កើន**២១**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន**៦៤**នាក់ (ស្រី**៣៤**នាក់) ក្នុងនោះជនបរទេសចំនួន**០៩**នាក់ សញ្ជាតិ៖ (ចិន**០៤**នាក់, ជប៉ុន**០១**នាក់, វៀតណាម**០១**នាក់, អាមេរិក**០១**នាក់, រុស្ស៊ី**០១**នាក់ និងអង់គ្លេស**០១**នាក់) សង្គ្រោះជនរងគ្រោះបានចំនួន**៨៩**នាក់ អាយុក្រោម១៥ឆ្នាំ**២៤**នាក់ (២៧%) អាយុពី១៥-១៧ឆ្នាំ**១៤**នាក់(១៧.៧៣%) និងអាយុ១៨ឆ្នាំឡើង**៥១**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច**១៣**នាក់ អង្គការ**០១**នាក់ និងគ្រួសារ**៧៥**នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

***តារាងស្ថិតិបទល្មើសជួញដូរមនុស្ស***

| **បទល្មើស** | **ករណី** | **ជនសង្ស័យ** | **ជនបរទេស** |
|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ៧ | ៧ | |
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ១៣ | ១៨ | វៀតណាម១ |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ៩ | ១៣ | ចិន៤ |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ៤ | ៧ | ជប៉ុន១ រុស្ស៊ី១ |
| -អំពើលក់ដូរមនុស្សដោយមានគោលដៅ | ៣ | ៦ | |
| -អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ២ | ៦ | |
| -អំពើនាំឆ្លងដែន | ១ | ១ | |
| -ការទិញពេស្យាចារកុមារ | ៤ | ៦ | អាមេរិក១ អង់គ្លេស១ |
| ***សរុប*** | ***៤៣ ករណី*** | ***៦៤ នាក់*** | ***៩ នាក់*** |

**២.អំពើធ្វើអាជីវកម្មផ្លូវភេទ៖**

បង្ក្រាបបាន**៩៦**/**៤៨ករណី** (កើន**៤៨**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន**១១៦**នាក់ (ស្រី**២១**នាក់) ក្នុងនោះជនបរទេស**០៣**នាក់ សញ្ជាតិ៖ (ហូឡង់**០២**នាក់ និងវៀតណាម**០១**នាក់) និងសង្គ្រោះជនរងគ្រោះចំនួន **១៨៨**នាក់ អាយុក្រោម១៥ឆ្នាំ**៨៩**នាក់(៤៧.៣៤%) អាយុ១៥-១៧ឆ្នាំ**១៨**នាក់ (៩.៥៧%) និងអាយុ១៨ឆ្នាំឡើង**៨១**នាក់ (ដោយប្រគល់ឲ្យមន្ទីរសង្គមកិច្ច**៨៣**នាក់ អង្គការ**០៤**នាក់ និងប្រគល់ឲ្យគ្រួសារ**១០១**នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

***តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ***

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ២ | ២ | |
| -ស្ថានទម្ងន់ទោស (ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង) | ១ | ៧ | |
| -សញ្ជារកម្ម | ៨ | ១៤ | |
| -សញ្ជារកម្មមានអនីតិជន | ២ | ៣ | |
| -ស្ថានទម្ងន់ទោសនៃសញ្ជារកម្ម | ៣ | ៦ | |
| -សញ្ជារកម្ម (ទាក់ទងនឹងពេស្យាចារកុមារ) | ៥ | ៧ | វៀតណាម១ |
| -រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ២ | ២ | ហូឡង់១ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៥១ | ៥៣ | |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ២២ | ២២ | ហូឡង់១ |
| *សរុប* | *៩៧ ករណី* | *១១៦ នាក់* | *៣ នាក់* |

*តារាងបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ១០ខែ ឆ្នាំ២០១៧ ប្រៀបធៀបនឹង១០ខែ ឆ្នាំ២០១៦*

| ល.រ | អនុវត្ត | ករណី | ជនសង្ស័យ | ជនរងគ្រោះ |
|---|---|---|---|---|
| ១ | រយៈពេល១០ខែ ឆ្នាំ២០១៦ | ៧០ | ៨៩ | ២២៣ |
| ២ | រយៈពេល១០ខែ ឆ្នាំ២០១៧ | ១៣៩ | ១៨១ | ២៧៩ |
| សម្គាល់ | | ៦៩ | ៩២ | ៥៦ |




### គ.១.២-ការបង្ក្រាបករណីអន្តរការីនៃការពពោះជំនួស

ការបង្ក្រាបអំពើអន្តរការីនៃការពពោះជំនួស០១ករណី កាលពីខែវិច្ឆិកា ឆ្នាំ២០១៦ ដោយស្នងការដ្ឋានរាជធានីភ្នំពេញ ដែលមានជនសង្ស័យ ០៣នាក់ (មានជនបរទេសម្នាក់) ត្រូវបានបន្តនីតិវិធីផ្តន្ទាទោស នៅក្នុងឆ្នាំ២០១៧នេះ។

ចំណែកករណីសង្ស័យថា ជួញដូរសរីរាង្គ ក៏បានបង្ក្រាប ០១ករណី តែតុលាការមិនបានរកឃើញ ភស្តុតាងដល់ការដកហូត ឬជួញដូរសរីរាង្គនៅឡើយ ដូច្នេះការចោទប្រកាន់ គឺក្នុងបទល្មើសជួញដូរមនុស្ស។

## គ.២-កិច្ចការយុត្តិធម៌

### គ.២.១-លទ្ធផលចំណាត់ការផ្តន្ទាទោស

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ មាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

**គ.២.២-ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ៖**

ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត សរុបមានចំនួន**៦៣**ករណី ជនរងគ្រោះចំនួន**៦៤**នាក់ (អនីតិជន**៤២**នាក់) ជនត្រូវចោទមានចំនួន**៦៩**នាក់ ក្នុងនោះមានអនីតិជន**១២**នាក់ ហើយបានចំណាត់ការដោយបានបញ្ជូនទៅស៊ើបសួរចំនួន**៣៧**ករណី, តម្កល់ទុកឥតចាត់ការគ្មាន និងកំពុងចាត់ការចំនួន**២៦**ករណី ដូចមានតារាងរាយលម្អិតខាងក្រោម៖

***តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត៖***

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនល្មើស | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | បញ្ជូនទៅស៊ើបសួរ | តម្កល់ទុកឥតចាត់ការ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | |
| សរុប ៦៣ | ២ | ២០ | ៣ | ៣៩ | ៤២ | ១៥ | ១០ | ២ | ៣៧ | គ្មាន | ២៦ |
| | ២២នាក់ | | ៤២នាក់ | | ៥៧នាក់ | | ១២នាក់ | | ៦៣ករណី | | |

**គ.២.៣-ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត ៖**

ចំណាត់ការរបស់ចៅក្រមស៊ើបសួរ រាជធានី-ខេត្ត សរុបមានចំនួន**៦៤**ករណី ជនរងគ្រោះ**៩៥**នាក់ (អនីតិជន**៥០**នាក់) ជនត្រូវចោទមានចំនួន៨៤នាក់ (អនីតិជន**១១**នាក់) នៅក្នុងឃុំចំនួន**៣៥**នាក់ ក្រៅឃុំ៤៨នាក់ និងបានចំណាត់ការបញ្ជូនទៅជម្រះចំនួន**០៧**ករណី លើកលែងចោទចំនួន**០១**ករណី និងកំពុងចាត់ការចំនួន**៥៦**ករណី ដូចមានតារាងរាយលម្អិតខាងក្រោម៖

***តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមស៊ើបសួរ៖***

| ចំនួនករណី | ចំនួនជនរងគ្រោះ | | | | ចំនួនជនត្រូវចោទ | | | | នៅក្នុងឃុំ | | | | នៅក្រៅឃុំ | | | | ប្រភេទចំណាត់ការ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | នីតិជន | | អនីតិជន | | | | |
| | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ប | ស | ជូន | លើក | កំ |
| ៦៤ | ១៤ | ៣១ | ១២ | ៣៨ | ៥០ | ២៣ | ១០ | ១ | ៣១ | ៤ | គ្មាន | | ២០ | ១៩ | ៨ | ១ | ៧ | ១ | ៥៦ |
| | ៤៥នាក់ | | ៥០នាក់ | | ៧៣នាក់ | | ១១នាក់ | | ៣៥នាក់ | | | | ៤៨នាក់ | | | | ៦៤ករណី | | |

**គ.២.៤-ចំណាត់ការរបស់ចៅក្រមជំនុំជម្រះ រាជធានី-ខេត្ត ៖**

ចំណាត់ការរបស់ចៅក្រមជំនុំជម្រះរាជធានី-ខេត្ត សរុបមានចំនួន**៤៧**ករណី ជនរងគ្រោះចំនួន**៤៥**នាក់ (អនីតិជន**១៥**នាក់) ជនជាប់ចោទសរុប**៥៨**នាក់ នៅក្នុងឃុំ**០២**ករណី នៅក្រៅឃុំ**០១**ករណី និងប្រាក់ពិន័យចំនួន១០លានរៀល ចាត់ការរួចចំនួន**០៣**ករណី រួចពីបទចោទ**០១**ករណី និងកំពុងចាត់ការចំនួន**៤៣**ករណី ដូចមានរាយលម្អិតខាងក្រោម៖

***តារាងចំណាត់ការរឿងក្តីជួញដូរមនុស្សរបស់ចៅក្រមជំនុំជម្រះ៖***

| ចំនួន | ចំនួនជនរងគ្រោះ | ចំនួនជន | | ប្រភេទចំណាត់ការ |
|---|---|---|---|---|

| ករណី | នីតិជន | | អនីតិជន | | ជាប់ចោទ | | ទោសព្យួរ | ពិន័យជាប្រាក់ | រួចផុតពីបទចោទ | រំលត់បណ្តឹងអាជ្ញា | ចាត់ការរួច | ផ្តន្ទាទោសពន្ធនាគារ | | កំពុងចាត់ការ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | | ក្នុងឃុំ | ក្រៅឃុំ | |
| សរុប ៤៧ | ៦ នាក់ | ២៤ នាក់ | ២ នាក់ | ១៣ នាក់ | ៣៧ នាក់ | ២១ នាក់ | | | ១ ករណី | | ៣ ករណី | ២ ករណី | ១ ករណី | ៤៣ ករណី |

*ក្រាហ្វិកចំណាត់ការរបស់ចៅក្រមជំនុំជម្រះ ឆមាសទី១ ឆ្នាំ២០១៧ ប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០១៦*




## ឃ.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

ឃ.១-ការសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញារងគ្រោះ និងជនសង្ស័យ

- យោងស្ថិតិ **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** បានបញ្ជូនពលរដ្ឋខ្មែរតាមរយៈស្ថានទូត ស្ថានតំណាងនៅបរទេស ដែលសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស មានចំនួន ៥៣៥នាក់ (ស្រី១៨០នាក់) មកពី ៖

- ប្រទេសឥណ្ឌូនេស៊ី ចំនួន ១៨នាក់ (ស្រី០១នាក់)
- ប្រទេសម៉ាឡេស៊ី ចំនួន២៦៩នាក់ (ស្រី៨៩នាក់)
- ប្រទេសវៀតណាម ចំនួន ១០នាក់ (ស្រី០៥នាក់)
- ប្រទេសចិន ចំនួន ៣៦នាក់ (ស្រី៣៦នាក់)
- ប្រទេសថៃ ចំនួន ១៥១នាក់ (ស្រី៣៩នាក់)
- ប្រទេសឡាវ ចំនួន ២៦នាក់ (ស្រី០៣នាក់)
- ប្រទេសជប៉ុន ចំនួន ០៥នាក់ (ស្រី០៥នាក់)
- ប្រទេសសឹង្ហបូរី ចំនួន ០១នាក់ (ស្រី០១នាក់)
- ប្រទេសសូម៉ាលី ចំនួន ១៨នាក់
- ប្រទេសអារ៉ាប៊ីសាអូឌី ចំនួន ០១នាក់ (ស្រី០១នាក់)

*ស្ថាប័ន-អង្គភាពអនុវត្តមាន ៖*

- **តាមរយៈអង្គការ IOM** បានទទួលពលករងគ្រោះចំនួន**១១៥**នាក់ (ស្រី**៥៥**នាក់) ក្នុងនោះមានមកពីប្រទេសថៃ**៤៥**នាក់ ម៉ាឡេស៊ី**៤០**នាក់ ឥណ្ឌូនេស៊ី**២០**នាក់ **ជប៉ុន០៦**នាក់ ចិន**០៣**នាក់ និងប្រទេសសិង្ហបុរី**០១**នាក់ ពលរដ្ឋខ្មែរទាំងនោះធ្វើការដូចជាតាមផ្នែកកសិកម្ម សំណង់ មេផ្ទះ រោងចក្រ នេសាទ ពេស្យាចារ លក់ដូរ និងករណីចាញ់បោកមិត្តភក្តិ រៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស និងផ្សេងៗទៀត។
- **អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍តាមក្រុមការងារអនុវត្តច្បាប់)** បានធ្វើសម្ភាសន៍ពលករងគ្រោះចំនួន**១៧៦**នាក់(ស្រី**៥០**នាក់) ក្នុងនោះមកពីប្រទេសម៉ាឡេស៊ី**៩១**នាក់ (ស្រី**១៥**នាក់), ចិន**៤១**នាក់(ស្រី**៣០**នាក់), សូម៉ាលី**១៨**នាក់, ឥណ្ឌូនេស៊ី**១១**នាក់ ថៃ**០៨**នាក់ ឡាវ**០៤**នាក់ (ស្រី**០២**នាក់) និងប្រទេសវៀតណាម**០៣**នាក់(ស្រី) តាមការសម្ភាសន៍មានទៅតាមមេខ្យល់**៩៤**នាក់, ទៅដោយខ្លួនឯង**៤៤**នាក់ និងទៅតាមក្រុមហ៊ុន**៣៨**នាក់។

### ឃ.២-ការទទួលជនសង្ស័យរងគ្រោះ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) ដោយមានកិច្ចសហការជាមួយអង្គការ IOM អង្គការចាប់ដៃ និងអង្គការរតនៈអ៊ិនជើនេសិនណាល បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលត្រូវបានមាតុភូមិនិវត្ត និងនីរទេសពីប្រទេសនានា សរុបចំនួន**៤០០**នាក់ (ស្រី**១៥០**នាក់) កុមារ**១០០**នាក់(កុមារី**៥៨**នាក់) មានដូចជាៈ ប្រទេសម៉ាឡេស៊ី**១០៩**នាក់(ស្រី**៥៤**នាក់), ថៃ**១៦៨**នាក់ (ស្រី**៣៤**នាក់) កុមារ**៩៩**នាក់ (កុមារី**៥៧**នាក់), វៀតណាម**៨៥**នាក់(ស្រី**៤១**នាក់), សូម៉ាលី**១៨**នាក់, ចិន**១៦**នាក់(ស្រី), អារ៉ាប់ប៊ីសាអូឌីត**០១**នាក់ និងប្រទេសឥណ្ឌូនេស៊ី**០៣**នាក់។

- **ក្រុមការងារសម្ភាសន៍ និងទទួលពលករនៃការិយាល័យជំនាញក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានសហការជាមួយមន្ត្រីមណ្ឌលសំចតប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងមន្ត្រីសង្គមកិច្ចប្រទេសថៃ ធ្វើការប្រគល់ថវិកាដែលបានមកពីរឿងក្តីនៅតុលាការប្រទេសថៃ ករណីជួញដូរកម្លាំងពលកម្ម (ចុះទូកនេសាទ) ជូនពលករចំនួន**១៨**នាក់ ក្នុងម្នាក់ៗទទួលបានសំណងចំនួន**៦២.០០០**បាត។
- **អង្គការទទួលកុមាររងគ្រោះស្នាក់នៅ** បានទទួលថវិកាពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សរបស់ថៃ២១.០០០បាត សម្រាប់ចំនួន**០៧**នាក់ ក្នុងម្នាក់**៣.០០០**បាត (បីពាន់បាត) ដើម្បីផ្គត់ផ្គង់កុមារមុនពេលធ្វើសមាហរណកម្មទៅឲ្យគ្រួសារវិញ។
- **សំណងថ្លៃឈ្នួលពលកម្ម និងប្រាក់ឧបត្ថម្ភបន្ថែម៖**
  - ចំណាប់ខ្មាំងជាជនជាតិខ្មែរដែលជាអ្នកនេសាទសមុទ្រ ចំនួន**០៤**នាក់ ដែលរងគ្រោះដោយអំពើប្លន់តាមផ្លូវសមុទ្រ នៅប្រទេសសុម៉ាលី ត្រូវបានម្ចាស់កប៉ាល់ Nahamm 3 ផ្តល់សំណងថ្លៃឈ្នួលពលកម្ម ក្នុងម្នាក់ៗទទួលបាន **២.៧០០**ដុល្លារ និងប្រាក់សំណងជំងឺចិត្ត **១.០០០** ដុល្លារ តាមរយៈអង្គការ I SWAN និងសម្របសម្រួលដោយអង្គការ CARITAS ។

### ឃ.៤.៣-ការជួយជនរងគ្រោះ និងជនងាយរងគ្រោះ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- **សមាហរណកម្មជនរងគ្រោះ**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គការ IOM អង្គការចាប់ដៃ និងអង្គការរតនៈអ៊ិនជើនេសិន

ណាល បានសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរ ទៅតាមសហគមន៍វិញចំនួន**១៣៤**នាក់ (ស្រី**៦៣**នាក់) កុមារ**៣១**នាក់ (កុមារី**២២**នាក់) ហើយជនរងគ្រោះចំនួន**៣៣**នាក់ ផ្សេងទៀតបានវិលត្រឡប់ទៅស្រុកកំណើតវិញដោយខ្លួនឯង។

## II. ការលើកកម្ពស់សមត្ថភាព

### ១. ក្នុងប្រទេស

#### ១.១-ការបណ្តុះបណ្តាលក្នុងប្រទេស

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួងកិច្ចការនារី អគ្គស្នងការដ្ឋាននរបាលជាតិ និងរាជធានី-ខេត្ត ចំនួន១៣ មានខេត្តបាត់ដំបង សៀមរាប ព្រះសីហនុ កោះកុង ស្វាយរៀង ព្រះវិហារ ក្រចេះ កំពង់ធំ ត្បូងឃ្មុំ ស្ទឹងត្រែង ព្រៃវែង និងខេត្តឧត្តរមានជ័យ បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព និងអង្គការដៃគូ បើកវគ្គបណ្តុះបណ្តាលបានចំនួន**៦៦**វគ្គ មានសិក្ខាកាមចូលរួមចំនួន**១.៥៧៧**នាក់ ក្នុងនោះមានស្ត្រី**១.១០២**នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ សមាជិក គ.ខ.ប.ជ លោកគ្រូ អ្នកគ្រូ ប្រតិបត្តិករទេសចរណ៍នៅ តាមសណ្ឋាគារ និងប្រជាពលរដ្ឋ មានតារាងលម្អិតខាងក្រោម៖

*តារាងវគ្គបណ្តុះបណ្តាល*

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បើកវគ្គ បណ្តុះបណ្តាលគ្រូបង្គោលស្តីពី ការកាត់បន្ថយ និង លុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារតាមខេត្ត ។ | ១ | ៣៥ | ១៧ |
| ២ | **ក្រសួងកិច្ចការនារី** បើកវគ្គបណ្តុះបណ្តាគ្រូបង្គោលថ្នាក់តំបន់ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ចំនួន៤ខេត្តគឺ (ឧត្តរមានជ័យ ព្រះវិហារ កោះកុង) និងស្វាយរៀង ។ | ០៤ | ១៨៦ | ១៥៧ |
| ៣ | **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖**<br>- បានសហការជាមួយអង្គការវិនរ៉ុកអន្តរជាតិ បើកវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវា សមស្រប ដល់មន្ត្រីសង្គមកិច្ចអភិបាលរងស្រុក លោកគ្រូ អ្នកគ្រូ មេឃុំ ក្រុមប្រឹក្សាឃុំ ប្រធានអនុប្រធានភូមិ។<br>- បានបើកវគ្គបណ្តុះបណ្តាល ស្តីពីបទដ្ឋានអប្បបរមា សម្រាប់ថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។ | ០៣ | ៥៥ | ២៦ |
| ៤ | **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** សហការជាមួយក្រសួងសង្គមកិច្ច និងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងអង្គការ Child Fund, IOM បានចុះបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប (ខេត្តក្រចេះ ស្វាយរៀង កំពង់ស្ពឺ តាកែវ និងខេត្តកំពង់ឆ្នាំង)។ | ០៥ | ៣៥៥ | ៨៦ |
| ៥ | **អគ្គស្នងការដ្ឋាននរបាលជាតិ** (ក្រុមការងារអនុវត្តច្បាប់) បើកវគ្គបណ្តុះបណ្តាល៖<br>- សហការជាមួយគម្រោង (AAPTIP) និងស្ថានទូតអាមេរិក (FBI) បើកវគ្គបណ្តុះបណ្តាល០២វគ្គ ស្តីពីជំនាញស៊ើបអង្កេតអំពើជួញដូរ មនុស្ស និងស្តីពីបទល្មើសពាក់ព័ន្ធការសម្អាតប្រាក់ ការកោសល្យវិច្ឆ័យ ការស៊ើបអង្កេតទេសចរណ៍ផ្លូវភេទ និងការទំនាក់ទំនងតាមអ៊ិនធើណេត (នៅសណ្ឋាគារភ្នំពេញ និងសណ្ឋាគាររ៉ាល្វល)។ | ០៣ | ១១៨ | ២៨ |

| | | | | |
|---|---|---|---|---|
| | - សហការជាមួយអង្គការ UNODC បើកវគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេតបទល្មើសតាមប្រព័ន្ធបច្ចេកវិជ្ជា (នៅសណ្ឋាគារ Green Palace រាជធានីភ្នំពេញ)។ | | | |
| ៦ | **មន្ទីរការងារ និងបណ្តុះបណ្តាលខេត្តបាត់ដំបង** បើកវគ្គបណ្តុះបណ្តាលអំពីការពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ការងារ។ | ០១ | ១៦ | ២២ |
| ៧ | **មន្ទីរទេសចរណ៍ខេត្តសៀមរាប** បើកវគ្គបណ្តុះបណ្តាល ស្តីពីបដិសណ្ឋារកិច្ចល្អជូនដល់បុគ្គលិកបម្រើការងារក្នុងមណ្ឌលកម្សាន្តមនុស្សពេញវ័យ នៅមណ្ឌលកម្សាន្តនាងពួន និងមណ្ឌលកម្សាន្ត New Star។ | ០១ | ១២៥ | |
| ៨ | **លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តព្រះសីហនុ** សហការជាមួយមន្ទីរទេសចរណ៍ និងមន្ទីរសង្គមកិច្ចខេត្ត បើកវគ្គបណ្តុះបណ្តាលៈ<br>- ស្តីពីជំនាញបដិសណ្ឋារកិច្ច និងសេវាកម្មទេសចរណ៍ដោយបញ្ជ្រាបបញ្ហាយេនឌ័រ និងការធ្វើអាជីវកម្មទេសចរណ៍ផ្លូវភេទ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ចំនួន០២វគ្គ អ្នកចូលរួមចំនួន៧១នាក់ ស្រី២២នាក់។<br>- បទដ្ឋានអប្បបរមា សម្រាប់ថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល និងគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប អ្នកចូលរួម៨២នាក់ ស្រី៥៧នាក់។ | ០៣ | ១៥៣ | ៧៩ |
| ៩ | **ស្នងការដ្ឋាននគរបាលខេត្តកោះកុង** បើកវគ្គបណ្តុះបណ្តាលៈ<br>- ស្តីពីការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្សដល់មន្ត្រីនគរបាលថ្មី អ្នកចូលរួមចំនួន៥៦នាក់ ស្រី១១នាក់។<br>- ពីការងារបញ្ជ្រាបយេនឌ័រ ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដល់មន្ត្រីនគរបាលដែលទើបជ្រើសរើសចូលក្របខ័ណ្ឌថ្មី អ្នកចូលរួមចំនួន៥៦នាក់ ស្រី១២នាក់។<br>- ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ អ្នកចូលរួមចំនួន៤៥នាក់ ស្រី២៥នាក់។ | ០៣ | ១៥៧ | ៤៨ |
| ១០ | **លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តស្វាយរៀង** សហការជាមួយអង្គការសម្ព័ន្ធ មន្ទីរសង្គមកិច្ច នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បើកវគ្គបណ្តុះបណ្តាលស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស។ | ០១ | ៣០ | ០៧ |
| ១១ | **ស្នងការដ្ឋាននគរបាលខេត្តព្រះវិហារ** សហការអង្គការទស្សនៈពិភពលោក បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់បទល្មើស និងការបញ្ជូនកុមាររងគ្រោះដល់គ្រួបង្គោលក្នុងសហគមន៍ នៅស្រុកត្បែងមានជ័យ។ | ០៣ | ៩៦ | ៥៣ |
| ១២ | **មន្ទីរសង្គមកិច្ចខេត្តក្រចេះ** បើកវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារជនរងគ្រោះ ការទប់ស្កាត់ការជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការធ្វើអាជីវកម្មផ្លូវភេទ។ | ៣០ | ១.០៣២ | ៤៧៧ |
| ១៣ | **លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តកំពង់ធំ បើកវគ្គបណ្តុះបណ្តាល** ស្តីពីការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកខុសច្បាប់ដល់ក្រុមជួយខ្លួនឯង។ | ០១ | ៥០ | ២៦ |
| ១៤ | **មន្ទីរសង្គមកិច្ចខេត្តស្ទឹងត្រែង** សហការជាមួយអង្គការសុខមាលភាពសង្គម និងសាម៉ាក់តាន់ភិស បានបើកវគ្គបណ្តុះបណ្តាល ស្តីពីគន្លឹះទាំង៧ នៃការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់មន្ត្រីសង្គមកិច្ច អង្គការពាក់ព័ន្ធ និង | ០១ | ៥៩ | ៣៩ |

| | | | | |
|---|---|---|---|---|
| | សមាជិក គ.ក.ន.ក ថ្នាក់ឃុំ។ | | | |
| ១៥ | **ខេត្តត្បូងឃ្មុំ៖** ស្រុកតំបែរ និងស្រុកពញាក្រែក សហការជាមួយអង្គការការស៊ីស្វា បើកវគ្គបណ្តុះបណ្តាល ស្តីពីតួនាទីនគរបាលយុត្តិធម៌ និងសិទ្ធិកុមារពាក់ព័ន្ធទៅនឹងច្បាប់ជូនដល់ប៉ុស្តិ៍នគរបាល ក្រុមប្រឹក្សាឃុំ និងអ្នកទទួលបន្ទុកកិច្ចការនារី។ | ០២ | ៤៧ | ១២ |
| ១៦ | **ខេត្តព្រៃវែង បើកវគ្គបណ្តុះបណ្តាល៖**<br>- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្ត សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បើកវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន២៨នាក់ ស្រី០៥នាក់។<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការវីនរ៉ក់អន្តរជាតិ បើកវគ្គបណ្តុះបណ្តាល ដល់អាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវាកម្ម ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប និងបទដ្ឋានអប្បបរមាសម្រាប់ការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន៤៣នាក់។ | ០២ | ៧១ | ០៥ |
| ១៧ | **មន្ទីរកិច្ចការនារីខេត្តឧត្តរមានជ័យ** បើកវគ្គបណ្តាលបណ្តាល ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស។ | ០១ | ៤៥ | ៣៩ |
| ១៨ | **ខេត្តព្រៃវែង បើកវគ្គបណ្តុះបណ្តាល៖** បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្សលើការផ្តល់សេវាសមស្រប នៅថ្នាក់ខេត្ត។ | ០១ | ៣៨ | ១៨ |
| **សរុប** | | **៦៦វគ្គ** | **១.៥៧៧នាក់** | **១.១០២នាក់** |

**១.២-សិក្ខាសាលា**

ក្នុងរយៈពេល១០ខែ ឆ្នាំ២០១៧នេះ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រសួង ស្ថាប័នពាក់ព័ន ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិលេខាធិការដ្ឋានគ.ខ.ប.ជខេត្ត បានសហការជាមួយអង្គការដៃគូជាតិ និងអន្តរជាតិ ធ្វើសិក្ខាសាលាផ្តោតទៅលើប្រធានបទសំខាន់ៗ ដែលជាកិច្ចការអាទិភាពទាក់ទងនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សរុបបានចំនួន**១៥វគ្គ** មានអ្នកចូលរួមចំនួន**១.១០២**នាក់ មានស្រី**៣៧៩**នាក់ សកម្មភាពទាំងនោះរួមមាន៖

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំសិក្ខាសាលាចំនួន០៣វគ្គ មានអ្នកចូលរួមសរុបចំនួន៤៣៣នាក់ (ស្រី១៦៦នាក់) គឺ

(១).សិក្ខាសាលាផ្សព្វផ្សាយឯកសារគោល នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៧-២០១៨ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ ដែលមានសមាសភាពចូលរួមមានឯកឧត្តម លោកជំទាវ ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុប្រធាន សមាជិកគ.ជ.ប.ជ ប្រធាន និងសមាជិកក្រុមការងារទាំង៦ តំណាងស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ ជាតិ អន្តរជាតិ អភិបាល អភិបាលរងរាជធានី ខេត្ត សរុបចំនួន១៩០នាក់ (ស្រី៨៩នាក់)។

(២).សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការលើកកម្ពស់ការយល់ដឹងអំពីអនុសញ្ញាអាស៊ាន និងផែនការសកម្មភាពអាស៊ានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ (ACTIP & APA) ក្រោមអធិបតីភាព**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** នៅសណ្ឋាគារ៉ាហ្វ៊លឡឺរ៉ូ

យ៉ាល់ ដែលមានសមាសភាពចូលរួមជាតំណាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តំណាងក្រុមជំនាញអន្តរក្រសួង ស្ថាប័នទាំង០៦ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិដើម្បីកុមារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ស្ថានទូតសហរដ្ឋអាមេរិក ASEAN.US Progress, IOM, USAID, IJM និង WI សរុបចំនួន**៦៩**នាក់ (ស្រី**១៧**នាក់)។

(៣) សិក្ខាសាលាថ្នាក់ជាតិ ស្តីពី ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព របៀបរយ និងស្របច្បាប់ គាំទ្រដោយ អង្គការទេសន្តរប្រវេសន៍អន្តរជាតិ IOM មានអ្នកចូលរួម**១៧៤**នាក់ ស្រី**៦០**នាក់។

- **ក្រសួងកិច្ចការនារី** បានរៀបចំ សិក្ខាសាលាបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៧ និងលើកទិសដៅ ដែលមានសិក្ខាកាមចូលរួម ប្រធាន អនុប្រធានមន្ទីរកិច្ចការនារីទាំង២៥រាជធានី/ខេត្ត សរុបមានចំនួន៦០នាក់ ស្រី៥៦នាក់ ។
- **ក្រសួងទេសចរណ៍** បានរៀបចំសិក្ខាសាលាចំនួន០៤វគ្គ ស្តីពី"**សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍**" ដល់ផ្នែកឯកជននៃវិស័យទេសចរណ៍ ដែលមានសិក្ខាកាមចូលរួមចំនួន**២៥១**នាក់ ស្រី**១២០**នាក់។
  - ធ្វើនៅខេត្តកំពង់ធំ មានសិក្ខាកាមចូលរួមចំនួន**៦២**នាក់ ស្រី**៣២**នាក់
  - ធ្វើនៅខេត្តតាកែវ មានសិក្ខាកាមចូលរួមចំនួន**៦១**នាក់ ស្រី**២៩**នាក់
  - ធ្វើនៅខេត្តព្រៃវែង មានសិក្ខាកាមចូលរួមចំនួន**៦២**នាក់ ស្រី**២៨**នាក់
  - ធ្វើនៅខេត្តព្រះវិហារ មានសិក្ខាកាមចូលរួមចំនួន**៦៦**នាក់ ស្រី**៣១**នាក់។
- **ក្រសួងអប់រំ យុវជន និងកីឡា** បានរៀបចំសិក្ខាសាលាចំនួន០២វគ្គ ស្តីពីការពង្រឹងក្របខណ្ឌច្បាប់ និងយន្តការនៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសិក្ខាកាមចូលរួមចំនួន**១៥៨**នាក់ ស្រី**៣២**នាក់។
  - ធ្វើនៅខេត្តត្បូងឃ្មុំ មានសិក្ខាកាមចូលរួមចំនួន**៨៥**នាក់ ស្រី**២៣**នាក់
  - ធ្វើនៅខេត្តកោះកុង មានសិក្ខាកាមចូលរួមចំនួន**៧៣**នាក់ ស្រី**០៩**នាក់។
- **ខេត្តព្រៃវែង ៖ គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត** បានសហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IGM) រៀបចំសិក្ខាសាលា ស្តីពីកិច្ចសហការ ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុសស្ស ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ** នៅសាលប្រជុំ សាខាកាកបាទក្រហមខេត្ត មានអ្នកចូលរួមចំនួន**១១០**នាក់។
- **លេខាធិការដ្ឋានកោះកុងខេត្ត** សហការជាមួយអង្គការវីនរ៉ក (WINROCK) បានបើកវគ្គសិក្ខាសាលា ស្តីពីការបណ្តុះបណ្តាលមន្ត្រីជួរមុខនៃគណៈកម្មាធិការខេត្ត និងលេខាធិការដ្ឋាន គ.ខ.ប.ជ ដែលមានអ្នកចូលរួមសរុប៤៥នាក់ ស្រី**១៦**នាក់ ក្រោមអធិបតីភាពលោកស្រី **ឈុន វ៉ារុំង** អភិបាលរងខេត្ត។
- **ខេត្តបាត់ដំបង បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាល ៖**
  - ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន ដែលមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំអភិបាលស្រុក អធិការនគរបាលស្រុក ការិយាល័យពាក់ព័ន្ធ មេឃុំ គ.ក.ន.ក ឃុំ និងទីភ្នាក់ងារជ្រើសរើសឯកជន ក្នុងស្រុកគោលដៅទាំងប្រាំ។
  - ស្តីពីការពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ នឹងពលករទេសន្តរប្រវេសន៍ការងារ នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានការអញ្ជើញចូលរួមពីមន្ទីរពាក់ព័ន្ធជុំវិញខេត្ត តំណាងស្នងការ នគរបាលខេត្ត អង្គការជាតិ-អន្តរជាតិ ស្ថានីយ៍វិទ្យុ និងតំណាងស្រុកគោលដៅ។

- ស្ដីពីនីតិវិធីបំពេញបែបបទស្នើសុំប័ណ្ណ និងសៀវភៅការងារជនបរទេស និងការបំពេញបែបបទស្នើសុំកូតាប្រើប្រាស់ពលកម្មបរទេសតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម នៅវិទ្យាស្ថានបច្ចេកវិទ្យាខេត្តបាត់ដំបង (BIT)។

-**ខេត្តសៀមរាប** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការបេសកកម្មអន្តរជាតិ (IJM) និងអង្គការទស្សនពិភពលោក ក្នុងការរៀបចំសិក្ខាសាលាពង្រឹងសមត្ថភាព ដល់សមាជិកលេខាធិការដ្ឋាន គ.ខ.ប.ជ ថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលមានចំនួនចូលរួមសរុប**១០៥**នាក់ ស្រី**៤៥**នាក់។

**១.៣-សន្និសីទ**

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានរៀបចំសន្និសីទអាស៊ី-អ៊ឺរ៉ុបលើកទី១៤ ស្ដីពីការគ្រប់គ្រងលំហូរទេសន្តប្រវេសន៍ ក្រោមអធិបតីភាព **សម្ដេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** នៅខេត្តសៀមរាប មានសមាជិកចូលរួមចំនួន**៦៤**នាក់ មកពី**២៥**ប្រទេស ។

**១.៣-ការងារដឹកនាំសម្របសម្រួល កិច្ចប្រជុំ ៖**

សរុបការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ**៣២៧**លើក មានអ្នកចូលរួមសរុប**៦.១៣២**នាក់ មានស្រី**១,៦០៥**នាក់ ក្នុងនោះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ បានរៀបចំប្រជុំចំនួន**១០៦**លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន**២៦**លើក ក្រសួងកិច្ចការនារី ចំនួន**១០**លើក ក្រសួងអប់រំ យុវជន និងកីឡាចំនួន**០៧**លើក ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានរៀបចំសន្និបាតចំនួន**០១**លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត បានរៀបចំប្រជុំចំនួន**១៧៧**លើក ។ (**ឧបសម្ព័ន្ធទី២**)

## ២. ក្រៅប្រទេស

### ២.១-វគ្គបណ្ដុះបណ្ដាល

- **អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ** បានបញ្ជូនមន្ត្រីជាន់ខ្ពស់ថ្នាក់ប្រធាននាយកដ្ឋាន០១រូប ទៅចូលរួមវគ្គបណ្ដុះបណ្ដាល ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរត់ពន្ធមនុស្ស និងបទល្មើសដែលមានអង្គការចាត់តាំង នៅទីក្រុងហូជីមិញ សាធារណៈរដ្ឋសង្គមនិយមវៀតណាម។
- **អគ្គអន្តោប្រវេសន៍** បានបញ្ជូននាយនគរបាលជាន់ខ្ពស់៖
  - ចំនួន**០២**រូប ទៅចូលរួមវគ្គបណ្ដុះបណ្ដាល ស្ដីពីការគ្រប់គ្រងអន្តោប្រវេសន៍ និងការប្រើប្រាស់ប័ណ្ណអន្តោប្រវេសន៍ នៅទីក្រុង Lang Fang ខេត្ត Habei នៅសាធារណរដ្ឋប្រជាមានិតចិន។
  - ចំនួន**១៥**រូប ទៅចូលរួមវគ្គបណ្ដុះបណ្ដាលសម្រាប់មន្ត្រីអន្តោប្រវេសន៍ ស្ដីពីការគ្រប់គ្រងអន្តោប្រវេសន៍ នៅសាធារណរដ្ឋប្រជាមានិតចិន។
- **ខេត្តកំពត** បានបញ្ជូននាយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន៖
  - ចំនួន**០២**រូប ទៅរៀនវគ្គ ILEA នៅទីក្រុងបាងកក ប្រទេសថៃ។
  - ចំនួន**០១**រូប ទៅរៀនវគ្គបំប៉នជំនាញ នៅប្រទេសវៀតណាម។

## ២.២-សិក្ខាសាលា

– **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ៖**

- លោកជំទាវឧត្តមសេនីយ៍ឯក **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការរង គ.ជ.ប.ជ និងតំណាងក្រសួងកិច្ចការនារី ដើម្បីចូលរួមសិក្ខាសាលាវេទិកាតំបន់អាស៊ាន ស្តីពីការជួញដូរមនុស្ស(នៅប្រទេសឥណ្ឌូនេស៊ី)។
- ចាត់បញ្ជូន លោកឧត្តមសេនីយ៍ត្រី **សុខ រស្មី** ប្រធានក្រុមជំនួយកិច្ចសហប្រតិបត្តិការអន្តរជាតិ ចូលរួមសិក្ខាសាលាអាស៊ានសម្រាប់អ្នកប្រតិបត្តិផ្ទាល់ ស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ លើវិស័យ ច្បាប់ នៅក្នុងរឿងក្តីជួញដូរមនុស្ស (នៅទីក្រុងបាងកកប្រទេសថៃ)។

– **ក្រសួងកិច្ចការនារី ៖**

- លោកជំទាវ **សាន្ត អរុណ រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី** បានដឹកនាំគណៈប្រតិភូកម្ពុជាពី (គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គស្នងការដ្ឋាននគរបាលជាតិ) ដើម្បីចូលរួមសិក្ខាសាលាថ្នាក់តំបន់មេគង្គ លើកទី៧ ស្តីពីការកំណត់អត្តសញ្ញាណ និងផ្តល់សេវាជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការចែករំលែកបទពិសោធន៍ ក្នុងការកសាងជីវិតថ្មី ក្នុងចំណោមប្រទេសនៃមហាអនុតំបន់មេគង្គ (រៀបចំដោយ JICA និងក្រសួងសន្តិសុខអភិវឌ្ឍ ប្រទេសថៃ)។
- 

## ២.៣-កិច្ចប្រជុំ

– **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ៖**

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានដឹកនាំគណៈប្រតិភូកម្ពុជាពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន**១០រូប** ដើម្បីចូលរួមកិច្ចប្រជុំលើកទី១ ឆ្នាំ២០១៧ ស្តីពីការអនុវត្តកិច្ចព្រមព្រៀង ស្តីពីការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស រវាងរដ្ឋាភិបាលចិន-កម្ពុជា ដែលប្រព្រឹត្តទៅនៅទីក្រុងហ្វូងសាន ខេត្តអានហួយ សាធារណរដ្ឋប្រជាមានិតចិន។
- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានចាត់បញ្ជូន លោកឧត្តមសេនីយ៍ត្រី ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ ដើម្បី៖
    - ចូលរួមក្នុងវេទិកាអាំងទែរប៉ូល ស្តីពីការរួមគ្នាដើម្បីសន្តិសុខ និងការទទួលខុសត្រូវសម្រាប់សន្តិភាពពិភពលោក នៅទីក្រុង Abu Dhabi ប្រទេសអារ៉ាប់រួម ។
    - ចូលរួមកិច្ចប្រជុំ ឧត្តមមន្ត្រីអាស៊ានលើកទី១៧ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (នៅក្រុងវៀងច័ន្ទ ប្រទេសឡាវ)។
- ចាត់បញ្ជូន មន្ត្រីជាន់ខ្ពស់ ថ្នាក់អនុប្រធានក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍០១រូប ចូលរួមសន្និសិទ្ធថ្នាក់តំបន់ ស្តីពីការបន្លាស់ទីរបស់កុមារ នៅក្នុងតំបន់អាស៊ី-អាគ្នេយ៍ (នៅទីក្រុងបាងកកប្រទេសថៃ)។

– **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ៖**

- ចូលរួមប្រជុំពិគ្រោះយោបល់ទ្វេភាគី រវាងរាជរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលថៃលើកទី១៤ ស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស (នៅខេត្តឈៀងម៉ៃ ប្រទេសថៃ)។
- ឯកឧត្តម **តូច ចាន់នី** អគ្គនាយកបច្ចេកទេស នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដឹកនាំគណៈប្រតិភូកម្ពុជាមកពីគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ និងអង្គការដៃគូចំនួន**១៩រូប** ដើម្បីចូលរួមកិច្ចប្រជុំ ស្តីពីការគ្រប់គ្រងករណី ដំណើរការមាតុភូមិនិវត្តន៍ និងសមាហរណកម្ម (នៅប្រទេសថៃ)។
- បានដឹកនាំប្រតិភូទៅចូលរួមកិច្ចប្រជុំជាមួយក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃ ស្តីពីការចាត់ចែងដោះស្រាយករណី នៅទីក្រុងបាងកក ប្រទេសថៃ។ លទ្ធផលនៃកិច្ចប្រជុំមានដូចខាងក្រោម៖
  - បង្កើតប្រព័ន្ធទំនាក់ទំនងរវាងភាគីទាំងពីរ ឲ្យមានការតែងតាំងជនបង្គោលដើម្បីទំនាក់ទំនងការងារ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវយន្តការផ្លាស់ប្តូរព័ត៌មានដ៏មានប្រសិទ្ធភាពក្នុងការធ្វើមាតុភូមិនិវត្តន៍ និងការធ្វើសមាហរណកម្មក្នុងការបង្ការទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយភាគីកម្ពុជាបានចាត់ លោកស្រី ព្រុំ សុខន ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ជាជនបង្គោល ក្នុងការសម្របសម្រួល និងភាគីថៃ បានចាត់លោកស្រី Suvaree Jaiharm ប្រធាននាយកដ្ឋាន ប្រឆាំងការជួញដូរមនុស្ស ជាជនបង្គោលក្នុងការសម្របសម្រួល។
  - រៀបចំសេចក្តីព្រាងនីតិវិធីប្រតិបត្តិពិសេស (SOP) រវាងភាគីទាំងពីរស្តីពីការទទួលខុសត្រូវក្នុងការទទួល និងការប្រគល់ជនរងគ្រោះ ។
  - ពិនិត្យ និងស្រាវជ្រាវអំពីនីតិវិធីដំណើការប្រព័ន្ធយុត្តិធម៌ រឿងក្តីឧក្រិដ្ឋកម្មនៃបទឧក្រិដ្ឋពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងការទទួលខុសត្រូវលើការទទួលយកសំណងប្បដិទាន និងសំណងមូលនិធិ។

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ស្តីពីការអនុវត្តអនុស្សរណៈ នៃ ការយោគយល់គ្នារវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី ស្តីពីការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ។
- **អគ្គអន្តោប្រវេសន៍** បានចូលរួមប្រជុំពិភាក្សា ស្តីពីការផ្លាស់ប្តូរការងារគ្រប់គ្រងការងារអន្តោប្រវេសន៍ ជាមួយ អគ្គអន្តោប្រវេសន៍ នៃព្រះរាជាណាចក្រថៃ នៅទីក្រុងបាងកក ប្រទេសថៃ ។
- **ខេត្តបន្ទាយមានជ័យ៖ ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត** បានចូលរួមប្រជុំជាមួយភាគីថៃ នៅ សណ្ឋាគារ ឥណ្ឌូចិន ខេត្តស្រះកែវ (ប្រទេសថៃ) ស្តីពីនីតិវិធីក្នុងការបញ្ជូនត្រឡប់ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងភាពប្រឈម ក្នុងនោះមានសមាសភាពចូលរួមខាងភាគី កម្ពុជាចំនួន**២០**នាក់ និងភាគីថៃចំនួន**៣៥**នាក់។
- **ខេត្តព្រះវិហារ៖ ថ្នាក់វរៈនៃវរៈការពារព្រំដែន**បានចូលរួមប្រជុំជាមួយប្រទេសឡាវ នៅច្រកព្រំដែនទាំង២ ស្តីពីកិច្ចសហប្រិតបត្តិការ ការពារសន្តិសុខ តាមបណ្តោយព្រំដែន និងបញ្ហាពលករធ្វើចំណាក ស្រុក

ដោយប្រថុយប្រថាន ដើម្បីស្វែងរកការងារធ្វើនៅក្រៅប្រទេស និងពាក់ព័ន្ធអំពើជួញដូរមនុស្សឆ្លងដែនខុសច្បាប់។

- **ខេត្តរតនគិរី៖ ថ្នាក់វរៈនិងវរៈការពារព្រំដែន**បានចូលរួមប្រជុំចំនួន០៤លើក ថ្នាក់ប៉ុស្តិ៍និងប៉ុស្តិ៍ចំនួន**៤៧**លើក ជាមួយភាគីឡាវ និងភាគីវៀតណាម នៅតាមតំបន់ព្រំដែន ស្តីពីកិច្ចសហប្រតិបត្តិការ រក្សាសន្តិសុខ សណ្តាប់ធ្នាប់តាមបណ្តោយព្រំដែន និងបញ្ហាប្រជាជនឆ្លងដែនខុសច្បាប់ បានចំនួន**១៣២**លើក។

### ២.៤-សន្និសីទ

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

- o បានអញ្ជើញចូលរួមសន្និសីទអាស៊ាន ស្តីពីសារៈសំខាន់នៃបញ្ហាផ្នែកច្បាប់ ក្នុងតំបន់នៅប្រទេសសឹង្ហបុរី។
- o ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីការរៀបចំ កតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលប្រារព្ធធ្វើនៅមជ្ឈមណ្ឌលសន្និសីទអង្គការសហប្រជាជាតិ នាទីក្រុងបាងកក ប្រទេសថៃ រៀបចំដោយ UN ESCAP និង IOM។

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិគ្រប់ថ្នាក់ បានធ្វើឲ្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទទួលបានលទ្ធផលជាច្រើនគួរឲ្យកត់សម្គាល់ ។ លទ្ធផលជាស្នាដៃទាំងនេះ អាស្រ័យដោយ ៖

- ការប្តេជ្ញាចិត្តជានយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកំណត់យកបញ្ហាជួញដូរមនុស្សជាអាទិភាពមួយ ដែលត្រូវយកចិត្តទុកដាក់ដោះស្រាយ មិនអាចព្រងើយកន្តើយបាន ព្រោះវាបានធ្វើឲ្យប៉ះពាល់ដល់អាយុជីវិត សិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្សដែលជាធនធានប្រកបដោយសក្តានុពលនៃសេដ្ឋកិច្ច សង្គម និងនយោបាយជាតិយ៉ាងធ្ងន់ធ្ងរ ។
- ការសម្រេចចិត្តជាយុទ្ធសាស្ត្ររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការដោះស្រាយបញ្ហាទេសន្តរប្រវេសន៍ បញ្ចៀសបញ្ហាប្រឈមដែលពលករខុសច្បាប់នៅក្រៅប្រទេសបាននឹងកំពុងតែព្រួយបារម្ភ និងបង្កើនការយកចិត្តទុកដាក់ជាគោលនយោបាយ លើការលើកកម្ពស់ជីវភាព និងស្ថានភាពរស់នៅរបស់កម្មករក្នុងស្រុកធ្វើឲ្យមានតុល្យភាពសម្រាប់ជម្រើស ក្នុងការរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាកាត់បន្ថយការសម្រេចចិត្ត ដោយប្រថុយប្រថាននឹងភាពរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពាន និងការកេងប្រវ័ញ្ចគ្រប់រូបភាព ។
- វិធានការ**ជាគន្លឹះ** ជាបន្តបន្ទាប់ របស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាប្រធាន** គ.ជ.ប.ជ **សម្រាប់ជម្រុញការអនុវត្ត**យន្តការសម្រាប់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ ។

- ការលើកកម្ពស់ការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើន គឺជាមូលដ្ឋានបង្អែករឹងមាំ សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- សន្ធិសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងឧបករណ៍ច្បាប់នានាដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខា ទទួលអនុវត្ត ជាពហុភាគី ទ្វេភាគី ជាមួយប្រទេសពាក់ព័ន្ធនានាក្នុងតំបន់ និងលើសកលលោក លើការពង្រឹងកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធនានា គឺជាប្រព័ន្ធច្បាប់ដ៏រឹង។
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដែលមានក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការសង្គមស៊ីវិល វិស័យឯកជន បានរួមគ្នាជាកម្លាំងស្នូល និងបានបង្កើនសមត្ថភាពបំពេញភារកិច្ចយ៉ាងសកម្ម ដើម្បីក្លាយទៅជាប្រព័ន្ធសុវត្ថិភាពដ៏រឹងមាំសម្រាប់ការពារសុវត្ថិភាពជនគ្រប់រូប ទាំងបុរស ស្ត្រី យុវវ័យ និងកុមារ ពីអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធ។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងនៅងចំណុចខ្លាំងដែលបានរៀបរាប់ខាងលើ ក៏នៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួន ៖

- ចំនួនពលករ ដែលជាមនុស្សពេញកម្លាំង ដែលចេញទៅធ្វើការនៅក្រៅប្រទេស មានចំនួនច្រើន (ជិត ១០% នៃចំនួនប្រជាជនសរុប) ជាពិសេស ពលករដែលកំពុងធ្វើការដោយខុសច្បាប់ក្រៅប្រទេស គឺត្រូវប្រឈមនឹងភាពរងគ្រោះ ដោយការឃោត់ខ្លួន ផាកពិន័យ ជួញដូរ កេងប្រវ័ញ្ច ហើយនឹងក្លាយជាបន្ទុកដោះស្រាយរបស់រាជរដ្ឋាភិបាល។
- វិធានការដោះស្រាយភាពស្របច្បាប់ មិនទាន់អាចបញ្ចប់ឲ្យជ្រះស្រឡះបាន ហើយនឹងមានសេសសល់ពលករដែលត្រូវប្រឈមនឹងវិធានការច្បាប់របស់ប្រទេសគោលដៅ។
- ការគ្រប់គ្រងលំហូរតាមច្រកព្រំដែន ទាំងផ្លូវការ និងមិនផ្លូវការ នៅមិនទាន់អាចទប់ស្កាត់លំហូរពលករមិនប្រក្រតីឲ្យមានប្រសិទ្ធភាពនៅឡើយ។
- ការរីកដុះដាលឡើងវិញនូវសេវាកំសាន្ត «**ភ្លើងព័ណ**» ដែលជាប្រភពនៃការជួញដូរផ្លូវភេទ ។
- ការទទួលខុសត្រូវ ក្នុងការតាមដានស្ថានភាព និងគាំទ្រដល់ជនរងគ្រោះ និងអ្នកវិលត្រឡប់ពីការធ្វើទេសន្តរប្រវេសន៍ មិនទាន់ក្លាយជាប្រព័ន្ធ ដែលមានការទទួលខុសត្រូវពីក្រសួង មន្ទីរ ស្ថាប័នអង្គភាពពាក់ព័ន្ធ នៅឡើយ។
- ផលប៉ះពាល់លើកុមារដែលនៅក្នុងគ្រួសារជនទេសន្តរប្រវេសន៍ នៅតែមានទំហំធំ ទោះបីជាកុមារទាំងនោះត្រូវបានឪពុកម្តាយដែលធ្វើទេសន្តរប្រវេសន៍ បោះបង់ឲ្យរស់នៅជាមួយអាណាព្យាបាលជាអ្នកជិតខាង សាច់ញាតិ ឬចាស់ទុំក្តី ឬទៅតាមឪពុកម្តាយនៅពេលធ្វើទេសន្តរប្រវេសន៍ក្តី ព្រោះ ក្មេងទាំងនោះ នឹងមិនមានឱកាសទទួលបានឱកាសរៀនសូត្រ ថែទាំសុខភាព និងសុវត្ថិភាព ដូចក្មេងដទៃឡើយ។
- ការសាងសង់មណ្ឌលសំចត នៅតាមបណ្តាច្រកព្រំដែនសំខាន់ៗ ដើម្បីទទួលពលករ និងត្រៀមដោះស្រាយបញ្ហាពលករ នៅយឺតយ៉ាវ មិនទាន់ដំណើរការ។

- រាជធានី-ខេត្ត អង្គភាពស្ថាប័នមួយចំនួន មិនទាន់ចាត់ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាអាទិភាព និងបានត្រៀមផែនការសកម្មភាព និងថវិកាច្បាស់លាស់នៅឡើយ។
- មន្ត្រីមួយចំនួន មិនទាន់យល់ និងខ្វះការយកចិត្តទុកដាក់ក្នុងការទទួលខុសត្រូវអនុវត្តការងារដែលជាជំនាញរបស់ខ្លួន ទៅក្នុងសកម្មភាពបង្ការទប់ស្កាត់ ការជួយដល់ជនរងគ្រោះ និងកិច្ចសហការក្នុងការផ្តល់ព័ត៌មាន ដើម្បីបង្ក្រាបជនល្មើស ឬសង្គ្រោះជនរងគ្រោះជាដើម ។
- ត្រូវការការបណ្តុះបណ្តាលឡើងវិញ ដល់មន្ត្រីទទួលបន្ទុកអនុវត្តនៅក្នុងរចនាសម្ព័ន្ធ គណៈកម្មាធិការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេស មន្ត្រីដែលមានការផ្លាស់ប្តូរភារកិច្ច។
- ក្រសួងជាសមាជិក និងខេត្តមួយចំនួន នៅមិនទាន់ចាប់អារម្មណ៍ក្នុងការផ្តល់របាយការណ៍ ដែលពាក់ព័ន្ធនឹងការរួមចំណែកក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មកគណៈកម្មាធិការជាតិ ដើម្បីអាចដាក់ចេញជាយុទ្ធសាស្ត្រឆ្លើយតបឲ្យបានត្រឹមត្រូវ ។

### ឃ. សន្និដ្ឋាន

អំពើជួញដូរមនុស្ស នៅតែបន្តកើតមាន ជាពិសេសក្នុងចំណោមប្រជាជនចល័ត ចំណាកស្រុក ជាពិសេស ជនទេសន្តរប្រវេសន៍ មិនប្រក្រតី ឬមិនតាមប្រព័ន្ធច្បាប់ ។ ដូច្នេះ ចាំបាច់ត្រូវពង្រីកការយល់ដឹង ពង្រឹងការគ្រប់គ្រង ពង្រឹងការអនុវត្តច្បាប់ និងពង្រឹងកិច្ចសហការរវាងអង្គភាព ស្ថាប័ន គ្រប់ថ្នាក់ ទាំងនៅក្នុងស្រុក តាមព្រំដែន និងជាមួយប្រទេសពាក់ព័ន្ធ ក្នុងការអនុវត្តវិធានការ បង្ការទប់ស្កាត់ អនុវត្តច្បាប់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឲ្យទទួលបានប្រសិទ្ធភាពខ្ពស់។

## V. ទិសដៅ១០ខែ ឆ្នាំ២០១៨

ដើម្បីធ្វើឲ្យសម្រេចគោលដៅនៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ឆ្នាំ២០១៨ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយ ដើម្បីធ្វើឲ្យសម្រេចគោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

៤. ត្រៀមចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-ឥណ្ឌា និងជាមួយប្រទេសពាក់ព័ន្ធដទៃទៀត។

៣. បន្តពង្រឹងការអនុវត្តច្បាប់ និងវិធានការនានា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ។

៣. ជម្រុញការអនុវត្ត ផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ពាក់កណ្តាល អាណត្តិទី២៖ ២០១៧-២០១៨) និងបន្តរៀបចំផែនការយុទ្ធសាស្ត្រប្រាំឆ្នាំប្រឆាំងការជួញដូរមនុស្ស២០១៩-២០២៣។

៥. រៀបចំកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៦. គាំទ្រ និងពង្រឹងចសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី/ខេត្ត។

៧. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

Comment [CBE1]:

៨. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៩. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

១០. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

១១. បន្តរៀបចំវិធានការ “**គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**” (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១២. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១៣. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

**ទិសដៅបន្ថែម ដែលជាអនុសាសន៍សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំឆមាសទី១ នេះ ដែលគប្បីជំរុញអនុវត្ត ឲ្យមានប្រសិទ្ធភាពសម្រាប់តំណាក់កាលដ៏ចាំបាច់៖**

១៤. ជំរុញអនុវត្តវិធានការ ដែលដាក់ចុះដោយក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស ក្នុងតំណាក់កាលនៃការជំរុញដោះស្រាយភាពស្របច្បាប់ដល់ពលករ ដែលនៅក្នុងប្រទេសថៃ និងការទទួលខុសត្រូវរបស់អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ ក្នុងការជួយដល់ពលករដែលត្រូវបានបញ្ជូនត្រឡប់។

១៥. បង្កើតក្រុមការងារ ពិសេសមួយក្រោមគណៈកម្មការផ្តល់ភាពស្របច្បាប់ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្រាវជ្រាវ អំពីពលករខ្មែរ ដែលមានវត្តមានក្នុងប្រទេសថៃ ស្ថានភាពស្របច្បាប់ ឬមិនស្របច្បាប់ ទីកន្លែងធ្វើការ អាស័យដ្ឋាននៅកម្ពុជា ដើម្បីងាយស្រួល ក្នុងការដោះស្រាយបញ្ហា និងទំនាក់ទំនងអប់រំ ផ្តល់សេវា និងបង្កើនភាពជឿជាក់ដល់រាជរដ្ឋាភិបាល។

១៦. រៀបចំបែងចែកក្រុមនេះ ដោយស្នើសុំបញ្ចូលជាក្រុមដែលមានបេសកកម្មពិសេស ជា **អនុព័ន្ធការងារ** ក្នុងរយៈពេលខ្លីមួយ ដែលនឹងត្រូវរំសាយវិញ ពេលចប់បេសកកម្ម។

១៧. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ ដែលនៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការ

ស្នាក់នៅបណ្តោះអាសន្ន មុនបានចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរ ដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពពលករជាដើម។

រាជធានីភ្នំពេញ ថ្ងៃទី………..ខែ…………..ឆ្នាំ២០១៧

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**បានឃើញ និងឯកភាព**

**ប្រធានគណៈកម្មាធិការ**

**សម្តេចក្រឡាហោម ស ខេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ  សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈ ក្នុងរយៈពេល១០ខែ ឆ្នាំ២០១៧

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នរៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រសួងកិច្ចការនារី | វេទិកាសាធារណៈ ស្តីពីការប្រឆាំងការទប់ស្កាត់អំពើជួញដូរមនុស្សដល់ប្រជាជនក្នុងឃុំចំនួន១២ឃុំ មាន ខេត្តឧត្តរមានជ័យ (ស្រុកអន្លង់វែង) ខេត្តព្រះវិហារ (ស្រុករវៀង) ខេត្តកោះកុង (ស្រុកស្រែអំបិល) និងស្រុកស្វាយរៀង។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរកិច្ចការនារីខេត្ត | 4 លើក | 644 នាក់ | 430 នាក់ |
| 2 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្តផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋលោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 5,340 លើក | 608,933 នាក់ | 213,208 នាក់ |
| 3 | ខេត្តកណ្តាល | វេទិកាសាធារណៈ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សនិងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព។ | ក្រុមការងារថ្នាក់ក្រុង/ស្រុក/ឃុំ/សង្កាត់ | 1,117 លើក | 94,134 នាក់ | 40,840 នាក់ |
| | | ផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋនិងបញ្ជ្រាបការយល់ដឹងអំពើជួញដូរមនុស្សតាមវិទ្យាល័យ អនុវិទ្យាល័យ សាលារៀនដល់លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរកិច្ចការនារី មន្ទីរអប់រំយុវជន និងកីឡាខេត្ត | 90 លើក | 12,638 នាក់ | 8,043 នាក់ |
| 4 | ពោធិ៍សាត់ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្សនៅតាមឃុំ សង្កាត់ ទូទាំងខេត្តដល់ប្រជាពលរដ្ឋនៅក្រុងពោធិ៍សាត់ ស្រុកក្រគរ និងស្រុកភ្នំក្រវាញ។ | ស្នងការដ្ឋាននគរបាលខេត្ត | 421 លើក | 32,147 នាក់ | 15,297 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំមានសុវត្ថិភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋនិងបញ្ជ្រាបការយល់ដឹងអំពើជួញដូរមនុស្សតាមវិទ្យាល័យ អនុវិទ្យាល័យ សាលារៀនដល់លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអប់រំយុវជន និងកីឡាខេត្ត | 2,632 លើក | 445,125 នាក់ | 243,431 នាក់ |
| 5 | ខេត្តបាត់ដំបង | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រីនិងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ | ស្នងការដ្ឋាននគរបាលខេត្ត | 1,661 លើក | 75,077 នាក់ | 40,033 នាក់ |
| | | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរកិច្ចការនារីខេត្ត | 4,898 លើក | 455,002 នាក់ | 209,937 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 6 | ខេត្តសៀមរាប | វេទិកាសាធារណៈ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងបង្ការបទល្មើសគ្រប់ប្រភេទ ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរកិច្ចការនារីខេត្ត ស្នងការដ្ឋាននគរបាលខេត្ត និងក្រុមការងារថ្នាក់ស្រុក កាកបាទក្រហមកម្ពុជា | 45 លើក | 14,161 នាក់ | 6,246 នាក់ |
| | | ផ្សព្វផ្សាយស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ នីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងអ្នកស្ម័គ្រចិត្តយុវជនកាកបាទក្រហម។ | | 3,032 លើក | 195,928 នាក់ | 111,969 នាក់ |
| 7 | កំពង់ឆ្នាំង | វេទិកាសាធារណៈ ផ្សព្វផ្សាយ ដល់ប្រជាពលរដ្ឋស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ស្នងការដ្ឋាននគរបាលខេត្ត | 7,528 លើក | 460,566 នាក់ | 252,941 នាក់ |
| | | ផ្សព្វផ្សាយលក្ខណៈ សម្បត្តិ៥យ៉ាង អំពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្សដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត ក្រុមការងារថ្នាក់ភូមិ ស្រុក | 4,633 លើក | 511,328 នាក់ | 226,164 នាក់ |
| 8 | ខេត្តកំពត | វេទិកាសាធារណៈ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព។ | ស្នងការដ្ឋាននគរបាលខេត្ត | 17 លើក | 4,287 នាក់ | 1,789 នាក់ |
| | | ផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ប្រជាពលរដ្ឋ និងបញ្ជ្រាបការយល់ដឹងអំពើជួញដូរមនុស្សតាមវិទ្យាល័យ អនុវិទ្យាល័យ សាលារៀន ដល់លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអប់រំយុវជន និងកីឡា ខេត្ត | 205 លើក | 40,036 នាក់ | 21,644 នាក់ |
| 9 | ខេត្តព្រះសីហនុ | វេទិកាសាធារណៈ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនូវច្បាប់ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | ស្នងការដ្ឋាននគរបាលខេត្ត | 20 លើក | 2,254 នាក់ | 1,270 នាក់ |
| | | ផ្សព្វផ្សាយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និង មន្ទីរកិច្ចការនារីខេត្ត | 89 លើក | 6,716 នាក់ | 5,130 នាក់ |
| 10 | ខេត្តតាកែវ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស និងការទប់ស្កាត់ការជួញដូរកម្លាំងពលកម្មកុមារ ដល់ប្រជាពលរដ្ឋនៅតាមភូមិ/ឃុំ សង្កាត់ ក្រុង/ស្រុក ។ | ស្នងការដ្ឋាននគរបាលខេត្ត | 264 លើក | 5,826 នាក់ | 2,245 នាក់ |
| | | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរកិច្ចការនារីខេត្ត | 222 លើក | 16,797 នាក់ | 6,301 នាក់ |
| 11 | ខេត្តរតនគិរី | វេទិកាសាធារណៈ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្សក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ។ | ស្នងការដ្ឋាននគរបាលខេត្ត | 88 លើក | 10,512 នាក់ | 3,819 នាក់ |
| | | ផ្សព្វផ្សាយទៅដល់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន សិប្បកម្មនានា ក្នុងខេត្តស្តីពីច្បាប់ការងារ និងការប្រឆាំងទប់ស្កាត់រាល់ទម្រង់ពលកម្មលើកុមារ។ | មន្ទីរការងារ និងបណ្តុះបណ្តាលខេត្ត | 20 លើក | 558 នាក់ | |

| | | | | | | |
|---|---|---|---|---|---|---|
| 12 | ខេត្តកំពង់ចាម | វេទិកាសាធារណៈ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្សនិងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ | ស្នងការដ្ឋាននគរបាលខេត្ត | 312 លើក | 12,498 នាក់ | 2,690 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្សនិងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងស្នងការដ្ឋាននគរបាលខេត្ត | 518 លើក | 32,547 នាក់ | 15,873 នាក់ |
| 13 | ខេត្តព្រៃវែង | វេទិកាសាធារណៈ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនូវច្បាប់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុក ដោយសុវត្ថិភាព។ | ស្នងការដ្ឋាននគរបាលខេត្ត | 4 លើក | 454 នាក់ | 285 នាក់ |
| | | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 3 លើក | 300 នាក់ | 214 នាក់ |
| 14 | ត្បូងឃ្មុំ | វេទិកាសាធារណៈ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋស្តីពីភូមិ-ឃុំមានសុវត្ថិភាព ការងារបទល្មើសគ្រប់ប្រភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្ស។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 75 លើក | 5,050 នាក់ | 2,458 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ ការជួញដូរកម្លាំងពលកម្មការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់សិស្សានុសិស្សលោកគ្រូ អ្នកគ្រូ និងក្រុមប្រឹក្សា យុវជន។ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត | 3 លើក | 10,489 នាក់ | 6,998 នាក់ |
| 15 | ខេត្តស្វាយរៀង | វេទិកាសាធារណៈ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 2,421 លើក | 105,019 នាក់ | 59,751 នាក់ |
| 16 | ខេត្តកោះកុង | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ | ស្នងការដ្ឋាននគរបាលខេត្ត | 174 លើក | 10,054 នាក់ | 1,753 នាក់ |
| 17 | ខេត្តព្រះវិហារ | ផ្សព្វផ្សាយ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនិងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋលោកគ្រូ អ្នកគ្រូ និង សិស្សានុសិស្ស | លេខាធិការដ្ឋាន គ.ខ.ប.ជ និងស្នងការដ្ឋាននគរបាលខេត្ត | 14 លើក | 2,953 នាក់ | 1,645 នាក់ |
| 18 | ខេត្តប៉ៃលិន | ផ្សព្វផ្សាយ បញ្ជ្រាបការយល់ដឹងអំពីវិធានការទប់ស្កាត់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនិងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 30 | 838 នាក់ | 340 នាក់ |
| 19 | ខេត្តឧត្តរមានជ័យ | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនិងសិស្សានុសិស្សស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ កិច្ចការពារជនរងគ្រោះដោយសារទេសន្តរប្រវេសន៍ ការកេងប្រវ័ញ្ចនានា និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 41 លើក | 6,604 នាក់ | 3,135 នាក់ |
| 20 | បន្ទាយមានជ័យ | វេទិកាសាធារណៈ ស្តីពីអំពើជួញដូរមនុស្សការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុក ដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋនៅឃុំតាប៉ែន ឃុំតាផូ ឃុំទ្រាស ឃុំផ្គាំ ស្រុកស្វាយចេក។ | ស្នងការដ្ឋាននគរបាលខេត្ត | 4 លើក | 998 នាក់ | 759 នាក់ |

| | | | | | | |
|---|---|---|---|---|---|---|
| 21 | ខេត្តកែប | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋស្តីពីការទប់ស្កាត់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនិងការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងស្នងការដ្ឋាននគរបាលខេត្ត | 278 លើក | 53,489 នាក់ | 26,537 នាក់ |
| 22 | ខេត្តកំពង់ធំ | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ និងកិច្ចការពារជនរងគ្រោះនិងបញ្ជ្រាបការយល់ដឹងអំពើជួញដូរមនុស្សតាមវិទ្យាល័យ អនុវិទ្យាល័យសាលារៀនដល់លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអប់រំយុវជន និងកីឡា ខេត្ត | 54 លើក | 33,620 នាក់ | 16,909 នាក់ |
| 23 | ខេត្តកំពង់ស្ពឺ | ផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋសិស្សានុសិស្សនៅតាមសាលារៀនទូទាំងខេត្តស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើហិង្សាក្នុងគ្រួសារ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរ មន្ទីរអប់រំយុវជន និងកីឡា និង កម្លាំងអធិការដ្ឋាននគរបាលខេត្តក្រុង/ស្រុក | 307 លើក | 191,056 នាក់ | 85,263 នាក់ |
| | | វេទិកាសាធារណៈស្តីពីអំពើជួញដូរមនុស្សការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើហិង្សាក្នុងគ្រួសារ ដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ ស្រុកបសេដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត | 1 លើក | 75 នាក់ | 50 នាក់ |
| 24 | ខេត្តស្ទឹងត្រែង | ផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សការធ្វើអាជីវកម្មផ្លូវភេទការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរកិច្ចការនារីខេត្ត | 2 លើក | 374 នាក់ | 251 នាក់ |
| 25 | ខេត្តមណ្ឌលគិរី | ផ្សព្វផ្សាយស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សការធ្វើអាជីវកម្មផ្លូវភេទ និងកិច្ចការពារជនរងគ្រោះតាមវិទ្យាល័យ អនុវិទ្យាល័យសាលារៀនដល់លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស។ | មន្ទីរអប់រំយុវជន និងកីឡា ខេត្ត | 16 លើក | 15,399 នាក់ | 7,779 នាក់ |
| 26 | ខេត្តក្រចេះ | ផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់ការជួញដូរស្ត្រីនិងកុមារ កិច្ចការពារជនរងគ្រោះការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរកិច្ចការនារីខេត្ត | 26 លើក | 1,001 នាក់ | 608 នាក់ |

សកម្មភាពសរុបចំនួន: 36,609 លើក

មនុស្សសរុបចំនួន: 3,475,487 នាក់

ស្ត្រីសរុបចំនួន : 1,644,035 នាក់

**ឧបសម្ព័ន្ធទី២**

**តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន៣២៧លើក) មនុស្សចំនួន៦,១៣២នាក់ (ស្រី១,៦០៥នាក់)**

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | សម្របសម្រួលចំនួន១០៦លើក អ្នកចូលរួមសរុបចំនួន១.៨៨៩នាក់ (ស្រី១២៣នាក់)<br>- ប្រជុំអន្តរក្រសួង ស្តីពីដំណោះស្រាយបញ្ហាពពោះជំនួស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** ជំនួបពិភាក្សា ជាមួយលោកជំទាវ **Donica Pottie** ឯកអគ្គរដ្ឋទូតកាណាដា ដែលទើបតែងតាំងថ្មី នៅទីស្តីការក្រសួងមហាផ្ទៃ និងបន្តកិច្ចសហប្រតិបត្តិការ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- រៀបចំសន្និបាតបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៦ និងលើកទិសដៅការងារ ឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ស្តីពីលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ប្រចាំឆមាសទី១ ឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ មានសមាសភាពចូលរួមចំនួន៥៩នាក់ ស្រី១៩នាក់។<br>- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីសម្រាប់ការស្នើសុំទារក ករណីពពោះជំនួសដើម្បីយកទៅចិញ្ចឹមនៅក្រៅប្រទេស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ** នៅទីស្តីការក្រសួងមហាផ្ទៃ ដោយមានការចូលរួមពីតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ និងស្ថានទូតបរទេសប្រចាំព្រះរាជាណាចក្រកម្ពុជា សរុបចំនួន៦១នាក់ ស្រី២២នាក់។<br>- ជួបពិភាក្សាការងារជាមួយលោក Jesse Lynch មន្ត្រីស្ថានទូតសហរដ្ឋអាមេរិក នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ដឹកនាំកិច្ចប្រជុំ ស្តីពីការពិគ្រោះយោបល់អំពីអំពើពេស្យាចារ និងអំពើពេស្យាកុមារ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ដឹកនាំកិច្ចប្រជុំជាមួយអង្គការដៃគូដូចជា WINROCK IOM, IJM និង Samaritan's Purse ស្តីពីគម្រោងបង្កើតទិន្នន័យស្នាមក្រយៅដៃជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនទេសន្តប្រវេសន៍ដែលឆ្លងកាត់ព្រំដែន តាមរយៈកិច្ចសហប្រតិបត្តិការជាមួយអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- អញ្ជើញជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង។ |

| | |
|---|---|
| | - អញ្ជើញជាអធិបតី និងជាគ្រូឧទ្ទេសក្នុងសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស នៅសាលាគរុកោសល្យវិក្រឹត្យការ ខេត្តកំពង់ចាម ដែលមានសិក្ខាកាមជាគ្រូឧទ្ទេស និងគរុសិស្សប្រមាណ១៦០។<br>- អញ្ជើញជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់រដ្ឋបាលខេត្តកំពង់ធំ។<br>- អញ្ជើញជាអធិបតីបើកសិក្ខាសាលា ស្តីពីការពង្រឹងប្រសិទ្ធភាពបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលើកកម្ពស់វប្បធម៌ បរិស្ថានល្អ និងអនាម័យល្អនៅតាមគ្រឹះស្ថានសិក្សា សាលាបណ្តុះបណ្តាលគរុកោសល្យ និងវិក្រឹត្យការ រាជធានីភ្នំពេញ។<br>- ដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផល និងសកម្មភាពការងាររបស់អង្គការដៃគូពាក់ព័ន្ធ ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៦ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សាពិនិត្យសម្រេចលើសេចក្តីព្រាងរបាយការណ៍ ជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៦ ជាមួយក្រុមការងារអន្តរក្រសួងទាំង៦ របស់គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ដឹកនាំកិច្ចប្រជុំអគ្គលេខាធិការដ្ឋាន បែងចែកភារកិច្ចធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៦ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- អញ្ជើញចូលរួមប្រជុំពិភាក្សា ស្តីពីការប្រឆាំងគ្រឿងញៀន បទឧក្រិដ្ឋឆ្លងដែន និងការជួញដូរមនុស្សនៅតំបន់ទន្លេមេគង្គ និងអាស៊ាន នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- អញ្ជើញចូលរួមប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧ របស់ក្រុមការងារអនុវត្តន៍ច្បាប់ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ។<br>- ប្រជុំកែសម្រួលរបាយការណ៍បូកសរុបសកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៦ និងលើកទិសដៅឆ្នាំ២០១៧ នៅគ.ជ.ប.ជ (**០៧លើក**)។<br>- ចូលរួមធ្វើសម្ភាសន៍ពលករិនី ចំនួន១៥រូប ដែលត្រូវនគរបាលម៉ាឡេស៊ីចាប់ខ្លួន ហើយត្រឡប់មកដល់កម្ពុជាវិញ។<br>- ចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការផ្សព្វផ្សាយរបកគំហើញនៃការសិក្សាស្រាវជ្រាវទីផ្សារការងារសម្រាប់យុវជនកម្ពុជា នៅសណ្ឋាគារកាំបូឌីយ៉ាណា។<br>- ដឹកនាំមន្ត្រីលេខាធិការដ្ឋានប្រជុំពិភាក្សារៀបចំកម្រងសំណួរលក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការវាយតម្លៃឆ្នាំ២០១៦ និងបែងចែកភារកិច្ចក្នុងការបញ្ជូនឯកសារ និងទំនាក់ទំនងទៅតាមបណ្តារាជធានី-ខេត្ត (**០៤លើក**)។<br>- ប្រជុំក្នុងក្រុមការងារ ស្តីពីរបាយការណ៍សកម្មភាពការងារបង្ការទប់ស្កាត់ឆ្នាំ២០១៦ របស់ក្រសួង-ស្ថាប័ន និងរាជធានី-ខេត្ត។<br>- ពិភាក្សាធ្វើរបាយការណ៍ពាក់កណ្តាលអាណត្តិ របស់ក្រុមការងារការពារជនរងគ្រោះ ជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>- ចូលរួមកិច្ចប្រជុំ ស្តីពីការធ្វើសេចក្តីព្រាងច្បាប់ការគ្រប់គ្រងការពពោះជំនួស នៅទីស្តីការក្រសួងកិច្ចការនារី។ |

| | |
|---|---|
| | - ជួបប្រជុំជាមួយតំណាងអង្គការ Cambodia Acts ស្តីពីការងាររៀបចំសិក្ខាសាលាផ្សព្វផ្សាយថ្នាក់ជាតិ ស្តីពីបេកគំហើញនៃការសិក្សាទីផ្សារការងារសម្រាប់យុវជន។<br>- ដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីដំណោះស្រាយបញ្ហាពពោះជំនួស នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- អញ្ជើញចូលរួមសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ។<br>- អញ្ជើញជាគណៈអធិបតីក្នុងកិច្ចប្រជុំលើកទី៨ របស់ក្រុមការងារ បច្ចេកទេសកម្ពុជា នៃកម្មវិធីអូស្ត្រាលី-អាស៊ី ដើម្បីប្រឆាំងការជួញដូរមនុស្ស ហៅកាត់ថា (AAPTIP) នៅសាលប្រជុំក្រសួងយុត្តិធម៌។<br>- អញ្ជើញចូលរួមប្រជុំក្រុមប្រឹក្សាកុមារ នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>- អញ្ជើញចូលរួមសិក្ខាសាលាពិភាក្សាអំពីផែនទីបង្ហាញផ្លូវ និងមធ្យោបាយឆ្ពោះទៅរកការបង្កើតប្រព័ន្ធការពារកុមារថ្នាក់ជាតិ ជាមួយអង្គការកុមារឥតព្រំដែន នៅភោជនីយដ្ឋានអ័រគីដេប៉ាស្ទ័រ។<br>- អញ្ជើញចូលរួមប្រជុំបូកសរុប ដំណើរការចំណុចខ្ពស់វាយលុកបង្ក្រាបបទល្មើសជួញដូរមនុស្សឆ្លងដែនរវាងកម្ពុជា-វៀតណាម ក្រោមអធិបតីភាព **ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន** អគ្គស្នងការនគរបាលជាតិ នៅសណ្ឋាគារភ្នំពេញ។<br>- អញ្ជើញចូលរួមប្រជុំឆ្លងសេចក្តីព្រាងរបាយការណ៍សន្និបាតបូកសរុប ការងារសម្រាប់ឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ និងឯកសារពាក់ព័ន្ធបម្រើការងារសន្និបាត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ជួបប្រជុំពិភាក្សាជាមួយអង្គការ VCAO លើការងារជួយសេវាដល់ ជនរងគ្រោះដែលធ្វើចំណាកស្រុកច្រើន ដើម្បីធ្វើយ៉ាងណាឲ្យពួកគាត់អាចរស់បានដោយពុំចាំបាច់ធ្វើចំណាកស្រុកសម្រាប់ឆ្នាំ២០១៨។<br>- អញ្ជើញចូលរួមប្រជុំបច្ចេកទេសលើលទ្ធផលការសិក្សាស្រាវជ្រាវ ស្តីពីផលប៉ះពាល់នៃការធ្វើចំណាកស្រុកមកលើកុមារកម្ពុជា នៅសណ្ឋាគារសាន់វ៉េ រៀបចំដោយក្រុមប្រឹក្សាជាតិដើម្បីកុមារ។<br>- ជួបពិភាក្សាជាមួយលោកស្រី Vimala នាយិការអង្គការកុមារឥតព្រំដែន ស្តីពីការបង្កើតផែនទីបង្ហាញផ្លូវឆ្ពោះទៅការបង្កើតប្រព័ន្ធការពារកុមារកម្ពុជា។<br>- ដឹកនាំកិច្ចប្រជុំដកពិសោធន៍លើការងារសន្និបាតបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ២០១៦ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- អញ្ជើញជាអធិបតីក្នុងមិទ្ទិញអបអរសាទរខួបលើកទី១០៦ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០១៧ នៅខេត្តបន្ទាយមានជ័យ។<br>- អញ្ជើញចូលរួមក្នុងមិទ្ទិញអបអរសាទរខួបលើកទី១០៦ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០១៧ "**ស្ត្រីដើម្បីសន្តិភាព និងវឌ្ឍនភាព**" ក្រោមអធិបតីភាពដ៏ខ្ពស់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅទីស្តីការក្រសួងមហាផ្ទៃ អ្នកចូលរួមចំនួន១.៣០០នាក់។<br>- ដឹកនាំប្រជុំពិភាក្សាកំណត់សមាសភាពគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំលើកទី១ ឆ្នាំ២០១៧ ស្តីពីការទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស រវាងរដ្ឋាភិបាល |

| | |
|---|---|
| | ចិន- កម្ពុជា ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងហូងសាន ខេត្តអានហួយ សាធារណរដ្ឋប្រជាមានិតចិន ពីថ្ងៃទី២១-២៣ ខែមីនា ឆ្នាំ២០១៧ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ដឹកនាំប្រជុំពិភាក្សាផ្ទៃក្នុង ស្តីពីលទ្ធផលការងាររបស់ក្រុមការងារទេសន្តប្រវេសន៍នៅច្រកទ្វារអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ និងធ្វើផែនការចុះសហការធ្វើការងារនេះបន្តទៀតជាមួយអង្គភាពពាក់ព័ន្ធនៅតាមព្រំដែន នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- អញ្ជើញជាអធិបតីបើកសិក្ខាសាលា ស្តីពីកិច្ចសហការដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម ដែលរៀបចំ និងសម្របសម្រួលដោយអង្គការ IJM នៅសាលប្រជុំសាខា កាកបាទក្រហមខេត្តព្រៃវែង មានសិក្ខាកាមចូលរួមប្រមាណ៧០នាក់។<br>- ដឹកនាំប្រជុំតាមដាន ត្រួតពិនិត្យ និងកែសម្រួលរបាយការណ៍ប្រចាំ ខែមករា ឆ្នាំ២០១៧ របស់គ.ជ.ប.ជ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ដឹកនាំប្រជុំតាមដាន និងត្រួតពិនិត្យការងារក្នុងលេខាធិការដ្ឋាននៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- អញ្ជើញចូលរួមប្រជុំក្នុងពិធីប្រកាសផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រជាតិ ស្តីពីអត្តសញ្ញាណកម្ម ឆ្នាំ២០១៧-២០២៦ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- អញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសគណៈកម្មការការពារកុមារថ្នាក់ជាតិ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ស្តីពីគំនិតផ្តួចផ្តើមនៃប្រព័ន្ធកិច្ចការពារកុមារ និងការកំណត់នូវចក្ខុវិស័យ ផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៧ នៅភោជនីយ៍ដ្ឋានអ័រគីដេប៉ាស្ទ័រ។<br>- ចុះបេសកកម្មទៅកាន់គោលដៅច្រកអន្តរជាតិដូង (ឡែម) ក្នុងខេត្តបាត់ដំបង ដើម្បីស្វែងរកមូលហេតុដែលថៃបង្វែរទិសដៅបញ្ជូនពលករពីច្រកប៉ោយប៉ែត មកតាមច្រកដូងវិញ ជាលទ្ធផលទទួលបានព័ត៌មានថានៅទីនោះមិនមានមណ្ឌលសំចតទេ មន្ទីរសង្គមកិច្ចមិនបានចុះទៅធ្វើការទេ និងមិនមានអង្គការណាជួយដល់ពលករដែលបញ្ជូមមក។<br>- អញ្ជើញចុះបេសកកម្មតាមដានលើការអនុវត្តអនុសញ្ញា CEDAW នៅខេត្តពោធិ៍សាត់។<br>- អញ្ជើញចូលរួមពិធីបិទវគ្គបណ្តុះបណ្តាលកម្រិតបឋមវិជ្ជាជីវៈនគរបាល និងប្រកាសតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិ ក្រោមអធិបតីភាព**សម្តេច ក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសាលាបណ្ឌិត្យសភានគរបាលជាតិកម្ពុជា។<br>- ដឹកនាំប្រជុំប្រកាសបញ្ចូលក្របខ័ណ្ឌមន្ត្រីនគរបាលជាតិថ្មី និងត្រួតពិនិត្យតួនាទីភារកិច្ចនៅក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មន្ត្រីនគរបាលជាតិក្របខ័ណ្ឌថ្មីដែលត្រូវបញ្ចូលក្នុងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានចំនួន១៥នាក់ (ស្រី០៥នាក់)។<br>- អញ្ជើញជួបប្រជុំពិភាក្សាជាមួយអង្គការ Cambodia ACTs ស្តីពីការបង្ហាញគម្រោង Child rights in the global compacts Cambodia នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ដឹកនាំប្រជុំពិភាក្សា ស្តីពីសេចក្តីរាយការណ៍ជំហានដំបូងអំពីលទ្ធផលនៃការចុះធ្វើការសិក្សាស្រាវជ្រាវ លំហូរពលករនៅច្រកទ្វារអន្តរជាតិដូង នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ |

- ដឹកនាំកិច្ចប្រជុំអន្តរក្រសួង ស្តីពីកិច្ចប្រជុំជំនាញពាក់ព័ន្ធនឹងការរៀបចំបែបបទនីតិវិធីអនុវត្តលិខិតលេខ២៥៣សជណ ស្តីពីគោលការណ៍ដោះស្រាយករណីទារកដែល កើតដោយការជួលស្ត្រីខ្មែរឲ្យពពោះជំនួស ដើម្បីយកទារកចេញទៅចិញ្ចឹមនៅក្រៅប្រទេស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- អញ្ជើញចុះត្រួតពិនិត្យលើការសម្ភាសពលករដែលបញ្ជូនត្រឡប់មកពីប្រទេសថៃ នៅច្រកទ្វារអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបង។
- អញ្ជើញជួបពិភាក្សាការងារជាមួយអង្គការ CHILD Frontiers ដើម្បីផ្តល់អនុសាសន៍ពាក់ព័ន្ធនឹងប្រព័ន្ធការពារកុមារ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- ដឹកនាំក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ និងក្រុមជំនួយកិច្ចការការពារជនរងគ្រោះ ចុះបេសកកម្មសហការជាមួយអង្គភាពពាក់ព័ន្ធ នៅច្រកទ្វារអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបង ដើម្បីត្រួតពិនិត្យ និងសម្ភាសពលករដែលបញ្ជូនត្រឡប់មកពីប្រទេសថៃ។
- ចូលរួមប្រជុំពាក់ព័ន្ធអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កម្ពុជា-ឥណ្ឌា នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។
- ធ្វើបទបង្ហាញអំពីលទ្ធផលជំហានដំបូង ស្តីពីការចុះធ្វើការសិក្សាស្រាវជ្រាវ និងធ្វើបទសម្ភាសន៍ផ្ទាល់ជាមួយពលករកម្ពុជា ដែលបញ្ជូនត្រឡប់មកវិញតាមច្រកទ្វារអន្តរជាតិដូង ស្រុកកំរៀង ខេត្តបាត់ដំបង។
- សហការជាមួយអង្គភាពពាក់ព័ន្ធ ចុះត្រួតពិនិត្យនៅច្រកទ្វារអន្តរជាតិដូង ស្តីពីការងារពាក់ព័ន្ធនឹងលំហូរទេសន្តរប្រវេសន៍ និងជនរងគ្រោះ។
- ដឹកនាំកិច្ចប្រជុំអន្តរក្រសួងផ្សព្វផ្សាយបង្ហាញលទ្ធផល ស្តីពីការវាយតម្លៃពាក់កណ្តាលអាណត្តិ នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល០៥ឆ្នាំ ២០១៤-២០១៨ នៅទីស្តីការក្រសួងមហាផ្ទៃ។
- អញ្ជើញចូលរួមកិច្ចប្រជុំស្តាប់របាយការណ៍ ស្តីពីការផ្តល់ឯកសារស្របច្បាប់ជូនពលករកម្ពុជាធ្វើការនៅប្រទេសថៃ នៅទីស្តីការក្រសួងមហាផ្ទៃ។
- ដឹកនាំប្រជុំត្រៀមរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការលើកកម្ពស់ការទទួលបានសិទ្ធិ និងកិច្ចគាំពារកុមារនម្លាស់ទី នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
- អញ្ជើញចុះតាមដាន និងត្រួតពិនិត្យគោលនយោបាយភូមិឃុំមានសុវត្ថិភាព នៅខេត្តកំពង់ឆ្នាំង។
- ដឹកនាំកិច្ចប្រជុំអន្តរក្រសួង ស្តីពីការរៀបចំនីតិវិធីអនុវត្តសេចក្តីជូនដំណឹងលេខ២៥៣សជណ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីសុំគោលការណ៍ដោះស្រាយករណីទារកដែលកើតដោយការជួលស្ត្រីខ្មែរឲ្យពពោះជំនួស ដើម្បីយកទារកចេញទៅចិញ្ចឹមនៅក្រៅប្រទេស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- អញ្ជើញជាគណៈអធិបតីក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការលើកកម្ពស់ការទទួលបានសិទ្ធិ និងកិច្ចគាំពារកុមារនម្លាស់ទី ដែលសហការរៀបចំ និងសម្របសម្រួលដោយ Cambodia ACTs, Terre des Homes, NGOCRC, PLAN, OAK Foundation, ក្រុមប្រឹក្សាជាតិដើម្បីកុមារ និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅភោជនីយដ្ឋានទន្លេបាសាក់២។

| | |
|---|---|
| | - ដឹកនាំកិច្ចប្រជុំអន្តរក្រសួង ស្តីពីការរៀបចំនីតិវិធីអនុវត្តសេចក្តីជូនដំណឹងលេខ២៥៣សជណ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីសុំគោលការណ៍ដោះស្រាយករណីទារកដែលកើតដោយការជួលស្ត្រីខ្មែរឲ្យពពោះជំនួស ដើម្បីយកទារកចេញទៅចិញ្ចឹមនៅក្រៅប្រទេស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- អញ្ជើញចូលរួមពិធីបើកសិក្ខាសាលា ស្តីពីការចែករំលែកចំណេះ ដឹងអំពីការអនុវត្តជោគជ័យនៅក្នុងផ្នែកអធិការកិច្ចការងារ និងលុបបំបាត់ពលកម្មកុមារនៃវិស័យសេដ្ឋ កិច្ចមិនរៀបរយរបស់ប្រជាជាតិអាស៊ីអាគ្នេយ៍ នៅខេត្តសៀមរាប។<br>- អញ្ជើញចុះតាមដាន និងត្រួតពិនិត្យគោលនយោបាយភូមិឃុំមានសុវត្ថិភាព នៅខេត្តកំពង់ឆ្នាំង។<br>- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់របស់ក្រុមការងារបច្ចេកទេស លើសេចក្តីព្រាងឯកសាររៀបចំក្របខណ្ឌការងារ ស្តីពីប្រព័ន្ធកិច្ចការពារកុមារនៅកម្ពុជា ដែលមានអ្នកចូលរួម៣០នាក់ (ស្រី១៨នាក់) ធ្វើឡើងនៅខេត្តសៀមរាប រៀបចំក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។<br>- អញ្ជើញចូលរួមក្នុងពិធីសំណេះសំណាល និងប្រគល់ថវិកាជូនជនរងគ្រោះចំនួន០៤នាក់ រួមនិងគ្រួសារដោយអំពើប្លន់តាមសមុទ្រនៅប្រទេសសូម៉ាលី ដែលរៀបចំឡើងដោយអង្គការការីតាសកម្ពុជា។<br>- សហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ចូលរួមធ្វើសម្ភាសន៍ជាមួយពលការនីខ្មែរ ចំនួន៨រូប ដែលបញ្ជូនត្រឡប់មកពីប្រទេសម៉ាឡេស៊ី ដោយមានជំនួយពីស្ថានទូត និងអង្គការ IOM។<br>- រៀបចំមេរៀន និងកម្មវិធីសម្រាប់វគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាសមស្រប នៅតាមបណ្តាខេត្តចំនួន១០ រួមមាន ស្វាយរៀង ព្រៃវែង ក្រចេះ រតនគិរី កំពង់ស្ពឺ កំពង់ឆ្នាំង បាត់ដំបង ពោធិសាត់ ត្បូងឃ្មុំ និងមណ្ឌលគិរី ។<br>- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់របស់សង្គមស៊ីវិល ស្តីពីគោលនយោបាយទេសន្តរប្រវេសន៍កម្ពុជា-ថៃ "**ការអនុវត្តល្អៗ បញ្ហាប្រឈម និងភាពឡានុវត្តភាព**" រៀបចំ ដោយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រីកម្ពុជា នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ។<br>- បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការរៀបចំចុះតាមដានការអនុវត្តវិធានការ និងដំណោះស្រាយរបស់អាជ្ញាធរក្នុងការគ្រប់គ្រងលំហូរពលករចេញ-ចូលតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ តាមសេចក្តីជូនដំណឹងលេខ១០២៥ ស.ជ.ណ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ។<br>- បានដឹកនាំកិច្ចប្រជុំជាមួយតំណាងអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងអង្គការIJM ស្តីពីបញ្ហានៃការបញ្ជូនពលករខ្មែរខុសច្បាប់ត្រឡប់មកពីប្រទេសថៃវិញយ៉ាង នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានអញ្ជើញជាវាគ្មិនកិត្តិយស ធ្វើបទបង្ហាញអំពីបទពិសោធន៍នៃការដឹកនាំស្ថាប័នរដ្ឋ នៅក្នុងសិក្ខាសាលាស្តីពីការពង្រឹងតួនាទីស្ត្រីក្នុងវិស័យនយោបាយ ក្រោមប្រធានបទ ស្ត្រី និងការដឹកនាំ នៅទីស្តីការក្រសួងបរិស្ថាន។<br>- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង និងថ្នាក់ក្រោមជាតិ ស្តីពីផែនការសកម្ម ភាពជាតិ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់អនុវត្ត |

| | |
|---|---|
| | បន្តឆ្នាំ២០១៧-២០១៨ នៅទីស្តីការក្រសួងមហាផ្ទៃ អ្នកចូលរួមចូលរួមចំនួន៨៧នាក់ ស្រី៤៩នាក់។<br>- បានដឹកនាំគណៈប្រតិភូបំពេញបេសកកម្មការងារអន្តរក្រសួងទៅខេត្តជាប់ព្រំដែនកម្ពុជា-ថៃចំនួន០៣ ប៉ៃលិន បាត់ដំបង និងបន្ទាយមានជ័យ ដើម្បីសិក្សាអំពីស្ថានភាពនៃការបញ្ជូនពលករត្រឡប់មកពីប្រទេសថៃ និងការស្វែងរកដំណោះស្រាយសមស្របសម្រាប់ ពលករឆ្លងកាត់ព្រំដែន ក្រោមការសម្របសម្រួលពីអាជ្ញាធរ និងសមត្ថកិច្ចខេត្តជាប់ព្រំដែន ដែលមានសមាសភាពគណៈប្រតិភូចំនួន១០នាក់ ស្រី០៥នាក់។<br>- បានអញ្ជើញជាគណៈអធិបតី ក្នុងសិក្ខាសាលាស្តីពីកិច្ចសហការដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម នៅខេត្តកោះកុង។<br>- បានអញ្ជើញជាអធិបតី និងជាវាគ្មិន ក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តកំពង់ស្ពឺ មានសិក្ខាកាមចូលរួមចំនួន៦២នាក់ ស្រី១៣នាក់។<br>- បានអញ្ជើញជួបប្រជុំពិភាក្សាជាមួយតំណាងអង្គការការីតាស់កម្ពុជា ស្តីពីទិវាជាតិអន្តរសាសនានៅកម្ពុជា នៅសាលាប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អ្នកចូលរួមចូលរួមចំនួន០៨នាក់ ស្រី០២នាក់។<br>- បានអញ្ជើញជួបពិភាក្សាជាមួយតំណាងតុលាការរាជធានីភ្នំពេញ អំពីនីតិវិធីនៃការសុំយកកូនចេញទៅក្រៅប្រទេស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានអញ្ជើញចូលរួមប្រជុំផ្ទៃក្នុង ពិនិត្យរៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ ឆ្នាំ២០១៧-២០១៨ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានសមាសភាពចូលរួមចំនួន**១២**នាក់ ស្រី០២នាក់។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការរៀបចំចុះតាមដានការអនុ វត្តវិធានការ និងដំណោះស្រាយរបស់អាជ្ញាធរក្នុងការគ្រប់គ្រងលំហូរពលករចេញ-ចូល តាមខ្សែបន្ទាត់ ព្រំដែនកម្ពុជា-ថៃ។<br>- បានអញ្ជើញជាប្រតិភូចុះបំពេញបេសកកម្មការងារអន្តរក្រសួងទៅខេត្តជាប់ព្រំដែនកម្ពុជា-ថៃចំនួន០៣ ប៉ៃលិន បាត់ដំបង និងបន្ទាយមានជ័យ ដើម្បីសិក្សាអំពីស្ថានភាពនៃការបញ្ជូនពលករត្រឡប់មកពីប្រទេសថៃ និងការស្វែងរកដំណោះស្រាយសមស្របសម្រាប់ ពលករឆ្លងកាត់ព្រំដែន ក្រោមការសម្របសម្រួលពីអាជ្ញាធរ និងសមត្ថកិច្ចខេត្តជាប់ព្រំដែន។<br>- បានដឹកនាំកិច្ចប្រជុំលេខាធិការដ្ឋាន ដើម្បីប្រកាសសេចក្តីសម្រេចអំពីតួនាទីភារកិច្ចរបស់ប្រធាន-អនុប្រធានលេខាធិការដ្ឋាន រដ្ឋបាលសរុប និងពង្រឹងការងារតាមការិយាល័យ។<br>- បានដឹកនាំក្រុមជំនួយកិច្ចការយុត្តិធម៌ ចុះបំពេញបេសកកម្មនៅច្រកទ្វារព្រំដែនអន្តរជាតិប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដើម្បីតាមដានការអនុវត្តវិធានការគ្រប់គ្រងលំហូរពលករចេញ-ចូល និងប្រមូលព័ត៌មានពីពលករដែលអាជ្ញាធរថៃចាប់បញ្ជូនមក។<br>- បានអញ្ជើញជួបពិភាក្សាការងារជាមួយលោកស្រី Meloney Lindberg ប្រធានមូលនិធីអាស៊ីប្រចាំកម្ពុជាដែលទើបតែងតាំងថ្មី នៅអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាជាមួយតំណាងអង្គការ IOM កែសម្រួលកម្មវិធី "អំពីកតិកាសញ្ញាជាសាកល ស្តីពីទេសន្តរប្រវេសន៍ដោយសុវត្ថិភាព ស្របច្បាប់ និងប្រក្រតីភាព របស់អង្គការសហប្រជាជាតិ" នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាភាពចូលរួមចំនួន១៣នាក់ ស្រី០២នាក់។ |

| | |
|---|---|
| | - បានដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង "ស្តីពីការរៀបចំកិច្ចប្រជុំពិភាក្សា (Policy Dialogue) ក្រុមប្រទេសបញ្ជូន (កម្ពុជា ភូមា ឡាវ) ដើម្បីស្វែងរកបញ្ហា និងដំណោះស្រាយរួម នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ អ្នកចូលរួមចំនួន៣០នាក់ ស្រី០៦នាក់។<br>- បានអញ្ជើញក្នុងពិធីជួបសំណេះសំណាលសួរសុខទុក្ខបងប្អូននារីខ្មែរ ដែលបានរៀបអាពាហ៍ពិពាហ៍ជាមួយបុរសកូរ៉េ រៀបចំដោយមូលនិធិស្ត្រីកូរ៉េ នៅសណ្ឋាគារសុខាភ្នំពេញ។<br>- បានដឹកនាំប្រជុំផ្ទៃក្នុងអគ្គលេខាធិការដ្ឋាន "អំពីកិច្ចការងារចាំបាច់មួយចំនួនរបស់ គ.ជ.ប.ជ" នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន។<br>- បានអញ្ជើញចូលរួមក្នុង "សន្និសីទអាស៊ីអឺរ៉ុបលើកទី១៤ ស្តីពីការគ្រប់គ្រងអន្តោប្រវេសន៍ និងលំហូរទេសន្តរប្រវេសន៍" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសណ្ឋាគារសុខាអង្គរ ខេត្តសៀមរាប។<br>- បានអញ្ជើញជាគណៈអធិបតី ក្នុងពិធីសម្ពោធសៀវភៅ កញ្ចប់ឧបករណ៍ C4D របស់ IOMX ស្តីពីការប្រាស្រ័យទាក់ទងដើម្បីការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា រៀបចំដោយអង្គការ IOM នៅភោជនីយ៍ដ្ឋានទន្លេបាសាក់២។<br>- ដឹកនាំត្រួតពិនិត្យវត្តមាន វិន័យ និងសណ្តាប់ធ្នាប់របស់មន្ត្រីនគរបាល និងមន្ត្រីស៊ីវិល នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ រៀងរាល់ថ្ងៃច័ន្ទនសសប្តាហ៍និមួយៗ។<br>- បានចូលរួមកិច្ចប្រជុំក្រុមបច្ចេកទេស គម្រោង AAPTIP កម្ពុជាលើកទី៩ នៅទីស្តីការក្រសួងយុត្តិធម៌។<br>- បានអញ្ជើញចូលរួមប្រជុំក្រុមការងារទេសន្តប្រវេសន៍អន្តរក្រសួង ដើម្បីពិនិត្យ និងពិភាក្សាលើការរៀបចំផែនការសកម្មភាពលម្អិត ដែលឆ្លើយតបនឹងផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់អនុវត្តឆ្នាំ២០១៧-២០១៨ នៅទៅស្តីការក្រសួងការងារ និងណ្តុះបណ្តាលវិជ្ជាជីវៈ។ |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | **សម្របសម្រួលចំនួន២៦លើក**<br>- ប្រជុំ ស្តីពីការពង្រឹងកិច្ចសហការជាមួយអង្គការដៃគូមិនមែនរដ្ឋាភិបាល និងការងារពាក់ព័ន្ធប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការរំលោភបំពានផ្លូវភេទ ។<br>- ចូលរួមប្រជុំក្នុងការឆ្លើយតបការស្នើសុំព័ត៌មាន នីតិវិធី និងបទបញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងការសុំកូនអន្តរប្រទេស។<br>- ចូលរួមប្រជុំក្រុមការងារអន្តរក្រសួង ដើម្បីពិនិត្យទៅលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា ។<br>- ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារដោះស្រាយបញ្ហាជនអនាថា ប្រចាំឆ្នាំឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិដោះស្រាយបញ្ហាជនអនាថា។<br>- ចូលរួមប្រជុំក្រុមការងារបច្ចេកទេសអនុវត្តកម្មវិធីអាបទីប AAPTIP លើកទី០៨ នៅក្រសួងយុត្តិធម៌។<br>- ចូលរួមកិច្ចប្រជុំពិនិត្យ-ពិភាក្សា និងសម្រេចចុងក្រោយ លើផែនការសកម្មភាពឧមមីត និងផែនការក្រុមការងារសហប្រតិបត្តិការអន្តរជាតិសម្រាប់ឆ្នាំ២០១៧។<br>- ចូលរួមកិច្ចប្រជុំ បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆ្នាំឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៧ របស់ក្រុមការងារអនុវត្តន៍ច្បាប់។<br>- ចូលរួមកិច្ចប្រជុំជាមួយលោកស្រី រ៉ូប៊ីន ស្តីពីការចុះស្រាវជ្រាវ វាយតម្លៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- ចូលរួមពិភាក្សា និងផ្តល់ព័ត៌មាន លើសូចនាករ ក្នុងផែនការសកម្មភាពប្រឆាំងអំពើជួញដូរមនុស្ស នៅអនុតំបន់មេគង្គលើកទី០៤ ឆ្នាំ២០១៥-២០១៨ នៅ |

| | |
|---|---|
| | ក្រសួងកិច្ចការនារី។<br>- ចូលរួមជាវាគ្មិន នៅក្នុងសិក្ខាសាលាថ្នាក់ខេត្ត ស្តីពីកិច្ចសហប្រតិបត្តិការដើម្បីរកដំណោះស្រាយការជួញដូរមនុស្ស និងពលករធ្វើចំណាកស្រុក នៅសណ្ឋាគារ ៧មករា ខេត្តកំពង់ចាម។<br>- ចូលរួមសិក្ខាសាលា ដើម្បីពិភាក្សា និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការបង្ក្រាបអំពើរត់ពន្ធមនុស្ស នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ។<br>- ចូលរួមសន្និបាត បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆ្នាំឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្តឆ្នាំ២០១៧ របស់ គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។<br>- ចូលរួមក្នុងពិធីប្រគល់-ទទួលឯកសារផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការរយៈពេល០៣ឆ្នាំ សម្រាប់ការងារអនុវត្តច្បាប់ ស្តីពីយុត្តិធម៌អនីតិជន ។<br>- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីយន្តការបណ្តឹងសម្រាប់ពលករទេសន្តរប្រវេសន៍ចំនួន០២ថ្ងៃ នៅសណ្ឋាគារ លី ហេងឆាយ ក្រុងប៉ោយប៉ែត ដែលរៀបចំដោយអង្គការ MOI ។<br>- ចូលរួមប្រជុំឆ្លងផែនការសកម្មភាពជាតិរបស់ គ.ជ.ប.ជ សម្រាបអនុវត្តបន្ត ឆ្នាំ២០១៧-២០១៨ នៅក្រសួងមហាផ្ទៃ។<br>- ចូលរួមប្រជុំត្រួតពិនិត្យ ពិភាក្សា សម្អាតចុងក្រោយ លើសេចក្តីព្រាងរបាយការណ៍សន្និសញ្ញាជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (០២លើក)។<br>- ចូលរួមប្រជុំប្រចាំខែលើកទី៩២ ឆ្នាំ២០១៧ របស់ក្រុមការងារថ្នាក់ជាតិពហុវិស័យ ស្តីពីកុមារកំព្រា និងកុមារងាយរងគ្រោះ។<br>- ចូលរួមប្រជុំរៀបចំអនុក្រឹត្យ ស្តីពីការគ្រប់គ្រងមជ្ឈមណ្ឌលថែទាំមនុស្សចាស់។<br>- ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពី "គោលការណែនាំ ស្តីពីបែបបទ និងនីតិវិធីសម្រាប់ការស្នើសុំទារក ករណីពពោះជំនួស ដើម្បីយកទៅចិញ្ចឹមនៅក្រៅប្រទេស"។<br>- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍ នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ។<br>- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងនីតិវិធីស៊ើបអង្កេតរឿងក្តីជួញដូរមនុស្សរបស់អង្គការចាប់ដៃ អ្នកចូលរួមសរុប៣៥នាក់ ស្រី១០នាក់ នៅខេត្តក្រចេះ។<br>ពិធីប្រកាសផ្សព្វផ្សាយជាផ្លូវការដាក់ឲ្យអនុវត្តអនុក្រឹត្យស្តីពី ការប្រគល់មុខងារគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋបាលរាជធានី-ខេត្ត ការគ្រប់គ្រងមុខងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល ទៅឲ្យរដ្ឋបាលរាជធានី ក្រុង ស្រុក និងការគ្រប់គ្រងមុខងារគ្រប់គ្រងសេវាថែទាំកុមាររងគ្រោះ និងងាយរងគ្រោះនៅក្នុងសហគមន៍ ទៅឲ្យរដ្ឋបាលរាជធានី រដ្ឋបាលក្រុង និងរដ្ឋបាលឃុំ ក្រោមអធិបតីភាព ឯកឧត្តម **វង់ សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធ ជន និងយុវនីតិសម្បទា។<br>- បានចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសអនុវត្តកម្មវិធីអាបទីប AAPTIP លើកទី០៩។<br>- បានចូលរួមប្រជុំក្រុមការងារទេសន្តរប្រវេសន៍ដើម្បីពិនិត្យ និងពិភាក្សាលើការរៀបចំផែនការសកម្មភាពលម្អិតដែលឆ្លើយតបទៅនឹងផែនការសកម្មភាពជាតិប្រ |

| | |
|---|---|
| | យុទ្ធប្រឆាំងអំពើជួញដូរមនុស្សសម្រាប់អនុវត្តឆ្នាំ២០១៧-២០១៨។<br>- បានចូលរួមប្រជុំពិគ្រោះយោបល់ ដើម្បីប្រមូលធាតុចូលសម្រាប់រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពី ក្រុមប្រទេសបញ្ជូនកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា អំពីបញ្ហារួម និងដំណោះស្រាយដែលព្រះរាជាណាចក្រកម្ពុជាធ្វើជាម្ចាស់ផ្ទះ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បានប្រជុំរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំរបស់នាយកដ្ឋាន។<br>បានចូលរួមសិក្ខាសាលាថ្នាក់តំបន់លើកទី០៣ ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទកុមារក្នុងវិស័យដំណើរ និងទេសចរណ៍ នៅខេត្តសៀមរាប។ |
| **ក្រសួងកិច្ចការនារី** | **សម្របសម្រួលចំនួន១០លើក អ្នកចូលរួមសរុបចំនួន១៦០នាក់ (ស្រី៩៧នាក់)**<br>- បានសហការជាមួយក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ និងក្រុមការងារខមមីត រៀបចំកិច្ចប្រជុំប្រចាំខែចំនួន០១លើក ស្តីពីការពិភាក្សារៀបចំផែនការសកម្មភាព របស់ក្រុមការងារ ខមមីត ឆ្នាំ២០១៧ និងរៀបចំផែនការសកម្មភាព របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ ទិសដៅឆ្នាំ២០១៧-២០១៨ មានអ្នកចូលរួមមកពីក្រសួង-ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន៤០នាក់ មានការឧបត្ថម្ភថវិការជាតិ តាមកម្មវិធី(PB)។<br>- បានរៀបចំកិច្ចប្រជុំ ស្តីពីការពិភាក្សារៀបចំបំពេញតារាងវាយតម្លៃ ថ្នាក់តំបន់សម្រាប់ការងារ ខមមីតកម្ពុជា ផ្ញើជូនទៅអង្គការ UN-ACT ប្រចាំតំបន់ និងកិច្ចសហប្រតិបត្តិការជាមួយអង្គការដៃគូពាក់ព័ន្ធ និងកិច្ចប្រជុំ ស្តីពីការប្រមូល ពិនិត្យ កែសម្រួលលើសេចក្តីព្រាងរបាយការណ៍ឆមាសទី១ និងទិសដៅឆមាសទី២ ឆ្នាំ២០១៧ ចំនួន០៣លើក មានអ្នកចូលរួមមកពីក្រសួង-ស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន១២០នាក់ ស្រី៩៧នាក់។ មានការឧបត្ថម្ភថវិកាជាតិ តាមកម្មវិធី(PB)។<br>- រៀបចំរបាយការណ៍ ស្តីពីការប្រយុទ្ធប្រឆាំងអំពើហិង្សាលើពលករចំណាកស្រុកជាស្ត្រី នៅក្រៅប្រទេស ផ្ញើជូនទៅអគ្គលេខាធិការដ្ឋានអង្គការសហប្រជាជាតិ។<br>- បានចូលរួមប្រជុំពិគ្រោះយោបល់ ស្តីពីការវាយតម្លៃពាក់កណ្តាលអាណត្តិ នៃផែនការសកម្មភាពជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលរៀបចំដោយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឆ្នាំ២០១៤-២០១៨ មានការរៀបចំដោយគណៈកម្មាធិការជាតិ គ.ជ.ប.ជ នៅសាលប្រជុំអគារ ទ ក្រសួងមហាផ្ទៃ។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិរយៈពេល៣ឆ្នាំ សម្រាប់ការអនុវត្តច្បាប់ ស្តីពីយុត្តិធម៌អនីតិជន រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការការអនុវត្តគោលនយោបាយទេសន្តរប្រវេសន៍ រវាងកម្ពុជា និងថៃលើខ្លឹមសារការអនុវត្តល្អៗ បញ្ហាប្រឈម និងកាលានុវត្តភាព រៀបចំដោយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិរយៈពេល៣ឆ្នាំសម្រាប់អនុវត្តច្បាប់ស្តីពីយុត្តិធ៌មអនីតិជនរៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ |
| **ក្រសួងអប់រំ យុវជន និងកីឡា** | **សម្របសម្រួលចំនួន០៧លើក**<br>- ចូលរួមផ្សព្វផ្សាយបង្ហាញលទ្ធផល ស្តីពីការវាយតម្លៃពាក់កណ្តាលអាណត្តិនៃសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរយៈពេល០៥ឆ្នាំ (២០១៤-២០១៨)។<br>- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយថ្នាក់ជាតិ ស្តីពីបេកគំហើញនៃការសិក្សាទីផ្សារការងារសម្រាប់យុវជន។ |

| | |
|---|---|
| | - ចូលរួមប្រជុំជាមួយ Independent Consultant ស្តីពីការអនុវត្តផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៤-២០១៨ ក្រោមការដឹកនាំរបស់លោកជំទាវ សឿ សុជាតា នៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា។<br>- ប្រជុំដាក់ឲ្យប្រើប្រាស់ជាផ្លូវការ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រឹក្សាយោបល់ជាមូលដ្ឋានដល់ស្ត្រី និងក្មេងស្រី និងគោលនយោបាយណែនាំ ស្តីពីការបញ្ជូនស្ត្រី និងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។<br>- ប្រជុំផ្តល់យោបល់លើផែនការយុទ្ធសាស្ត្រអនុវត្តច្បាប់ ស្តីពីយុត្តិធម៌អនីតិជន។<br>- បានចូលរួមសន្និបាតបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៦ និងទិសដៅបន្តឆ្នាំ២០១៧។<br>- ចុះពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលបំពេញកិច្ចសហការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដែលអនុវត្តដោយសមាគមយុវជនខ្មែរ នៅតាមវិទ្យាល័យចំនួន១២ នៃស្រុកចំនួន០៦ និងខេត្ត៣គឺ ខេត្តសៀមរាប កំពង់ចាម និងខេត្តព្រៃវែង។ |
| **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | **សម្របសម្រួលចំនួន០១លើក អ្នកចូលរួមសរុបចំនួន៤០០នាក់**<br>- បានរៀបចំសន្និបាតបូលសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ២០១៤-២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការអញ្ជើញចូលរួមរបស់ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សាអមក្រសួង អគ្គលេខាធិការ អគ្គនាយក តំណាងក្រសួង ស្ថាប័នដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ និងមន្ត្រីរាជការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិរបស់ក្រសួងសរុបចំនួន៤០០នាក់។ |
| *សរុបការងារសម្របសម្រួលលេខាធិការដ្ឋានរាជធានី-ខេត្ត បានចំនួន១៧៧លើក អ្នកចូលរួមសរុបចំនួន៣.៦៨៣នាក់ (ស្រី.១.៤៨២នាក់)* | |
| **រាជធានីភ្នំពេញ** | **សម្របសម្រួលចំនួន០២លើក**<br>- នាយកដ្ឋានការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានចូលរួមសិក្ខាសាលាលើកទី១ ស្តីពីក្រុមអ្នកពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- នាយកដ្ឋានការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសហការជាមួយអង្គការ AAPTIP រៀបចំកិច្ចប្រជុំប្រចាំខែ ស្តីពីជំនាញស៊ើបអង្កេត និងយេនឌ័រ ក្នុងការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស។ |
| **ខេត្តក្រចេះ** | **សម្របសម្រួលចំនួន០៥លើក អ្នកចូលរួមសរុបចំនួន១៧៧នាក់ (ស្រី១០៣នាក់)**<br>- ប្រជុំក្រុមការងារលេខាធិការដ្ឋានខេត្ត អំពីការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែមករា អ្នកចូលរួមចំនួន០៧នាក់ ស្រី០២នាក់។<br>- ប្រជុំ ស្តីពីការពង្រឹងអនុវត្តតួនាទី ភារកិច្ចដល់ក្រុមការងារទាំង៦ គ.ខ.ប.ជ និងរៀបចំធ្វើផែនការសកម្មភាពការងារជួញដូរមនុស្ស អ្នកចូលរួម៤៥នាក់ ស្រី២៧នាក់។<br>- ប្រជុំផ្សព្វផ្សាយ ស្តីពីការជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដល់ក្រុមការងារថ្នាក់ស្រុក និងឃុំ អ្នកចូលរួមចំនួន៧៥នាក់ ស្រី៤៧នាក់។ |

| | |
|---|---|
| | - ប្រជុំជាមួយក្រុមការងារអន្តរមន្ទីរ ស្ថាប័ន ទាំង៦ អំពីការអនុវត្តការងាររៀបចំធ្វើរបាយការណ៍១០ខែ អ្នកចូលរួមចំនួន៥០នាក់ ស្រី២៧នាក់។<br>- ប្រជុំផ្សព្វផ្សាយសេចក្តីសម្រេច ស្តីពីការកែសម្រួលសមាសភាពគ.ខ.ប.ជ របស់ក្រុមទាំង៦។ |
| **ខេត្តបាត់ដំបង** | **សម្របសម្រួលចំនួន២០លើក អ្នកចូលរួមសរុបចំនួន៥៦០នាក់ (ស្រី២៦៧នាក់)**<br>- ប្រជុំ ស្តីពីការគ្រប់គ្រង និងការផ្សព្វផ្សាយព័ត៌មានទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព នៅវិទ្យាស្ថានបច្ចេកវិទ្យាខេត្ត ក្រោមអធិបតីភាពលោកជំទាវ អភិបាលរងខេត្តទទួលបន្ទុកគណៈកម្មាធិការ គ.ខ.ប.ជខេត្ត។<br>- ចូលរួមសិក្ខាសាលាបណ្តុះបណ្តាលកម្រិតខ្ពស់ ស្តីពីជំនាញ និងបច្ចេកទេសផ្សះផ្សាវិវាទការងារ នៅខេត្តសៀមរាប មានអ្នកចូលរួមចំនួន៤៥នាក់ ស្រី០៦នាក់។<br>- ចូលរួមសម្របសម្រួលវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព រៀបចំដោយអង្គការទស្សនៈពិភពលោក អ្នកចូលរួម៤២នាក់ ស្រី២៣នាក់។<br>- ចូលរួមផ្សព្វផ្សាយ ស្តីពីការលើកកម្ពស់សិទ្ធិមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព រៀបចំដោយអង្គការប្រតិបត្តិកុមារកម្ពុជា អ្នកចូលរួម២៧នាក់ ស្រី២០នាក់។<br>- ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព រៀបចំដោយអង្គការអន្តរជាតិសម្រាប់អន្តោប្រវេសន៍ អ្នកចូលរួម២០នាក់ ស្រី៨នាក់។<br>- ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ ដល់មន្ត្រីពាក់ព័ន្ធក្រុង/ស្រុក ឃុំ/សង្កាត់ ស្តីពីយុត្តិធម៌ អនីតិជន និងស្ត្រី រៀបចំដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅសណ្ឋាគារស្ទឹងបាត់ដំបង។<br>- ចូលរួមជាវាគ្មិន ក្នុងវេទិកាផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងឱកាសការងារនៅក្នុងប្រទេស នៅឃុំបឹងរាំង ស្រុកកំរៀង។<br>- ស្នងការដ្ឋាននគរបាលខេត្ត ចាត់តាំងមន្ត្រីជំនាញចំនួន០១នាក់ ចូលរួមរៀនវគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេតបទល្មើសអំពើជួញដូរមនុស្ស រៀបចំដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយអង្គការ AAPTIP មានសិក្ខាកាមសរុបចំនួន២៤នាក់(ស្រី)។<br>- ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត សហការជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំខួបអនុស្សាវរីយ៍លើក១៣១ នៃទិវាពលកម្មអន្តរជាតិ១ ឧសភា ឆ្នាំ២០១៧ ក្រោមប្រធានបទ ដើម្បីសន្តិភាព ការងារមុខរបរ និងអភិវឌ្ឍ ដែលមានអ្នកចូលរួមសរុប២៦៨នាក់ ស្រី១៧៨នាក់ នៅអ៊ែរ៉ូហ្វសាំមីតហ្វូតវែរ ស្រុកសំពៅលូន។<br>- រៀបចំប្រជុំពិភាក្សាជាមួយក្រុមការងារ(ILO) ស្តីពីលទ្ធផលសម្រេចបាន និងផែនការអនុវត្តបន្ត នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។<br>- រៀបចំកិច្ចប្រជុំលើការងារ ស្តីពីការ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិដូង (ស្រុកកំរៀង) ក្រោមអធិបតីភាពលោកជំទាវ ញ៉ឹក សាគន្ធ អភិបាលរង នៃគណៈអភិបាលខេត្តបាត់ដំបង។<br>- ចូលរួមប្រជុំពិភាក្សាដោះស្រាយបញ្ហាលំហូរពលករមិនស្របច្បាប់ ដែលវិលត្រឡប់ចូលមកស្រុកវិញ នៅច្រកអន្តរជាតិដូងជាមួយ ឯកឧត្តម ឧត្តមសេនីយ៍ឯក |

| | |
|---|---|
| | ខៀវ ចាន់រ៉ា អគ្គលេខាធិការរង គ.ជ.ប.ជ នៅទីស្នាក់ការច្រកអន្តរជាតិដូង។<br>- ចូលរួមប្រជុំឆ្លងផែនការសកម្មភាពជាតិរបស់ គ.ជ.ប.ជ សម្រាប់អនុវត្តបន្តឆ្នាំ២០១៧-២០១៨ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ចូលរួមអមដំណើរលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចុះជួបសំណេះសំណាលជាមួយពលករខ្មែរដែលថៃចាប់បញ្ជូនវិលត្រឡប់មកវិញ នៅត្រអន្តរជាតិដូង។<br>- ចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាបណ្តុះបណ្តាលសម្រាប់គ្រូបង្គោល ស្តីពីសិទ្ធិរបស់យុវជននៅកន្លែងធ្វើការងារ ដែលរៀបចំដោយទីភ្នាក់ងារជាតិមុខរបរ និងអង្គការ (NEA) ក្រោមកិច្ចសហការជាមួយគម្រោង (ILO/SIDA) នៅសណ្ឋាគារខេមរា ខេត្តបាត់ដំបង។<br>- ប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំឆមាសទី១ ឆ្នាំ២០១៧ និងឆ្លងផែនការសកម្មភាពប្រចាំឆ្នាំ២០១៧-២០១៨ និងពិភាក្សាអំពីបញ្ហាជួយពលករ ដែលត្រឡប់មកពីប្រទេសថៃ របស់ក្រុមជំនាញទាំង៦ នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវ អភិបាលរង នៃគណៈអភិបាលរងខេត្ត បាត់ដំបង។<br>- ចុះពិនិត្យ និងផ្សព្វផ្សាយសេចក្តីប្រកាសជូនដំណឹងរបស់គណៈកម្មការផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពង់ស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ដែលបានត្រឡប់មកវិញតាមច្រកអន្តរជាតិដូង ច្រកទ្វារតំបន់ភ្នំដី។<br>- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ការងារទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងរៀបចំផែនការជាអាទិភាព ក្រោមអធិបតីភាព ឯកឧត្តម ឧត្តមសេនីយឯក **យឹម រិះ** អគ្គលេខាធិការរង គ.ជ.ប.ជ នៅស្រុកកំរៀង ខេត្តបាត់ដំបង។<br>- បានរៀបចំកិច្ចប្រជុំ ស្តីពីការផ្សព្វផ្សាយការជ្រើសរើសពលករទេសន្តប្រវេសន៍ ឲ្យស្របតាមនីតិវិធីច្បាប់ នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត អ្នកចូលរួមចំនួន១៩នាក់ ស្រី០៨នាក់។<br>- បានចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាឆ្លុះបញ្ចាំង បទពិសោធន៍រួមគ្នាដើម្បីទប់ស្កាត់ការធ្វើចំណាកស្រុកគ្មានសុវត្ថិភាព និងការជួញដូរមនុស្ស ដែលមានអ្នកចូលរួមពីខេត្តគោលដៅចំនួន០៣ គឺខេត្តសៀមរាប បន្ទាយមានជ័យ និងខេត្ត បាត់ដំបង មានអ្នកចូលរួមចំនួន១១៥នាក់។ |
| **ខេត្តឧត្តរមានជ័យ** | **សម្របសម្រួលចំនួន១៤លើក អ្នកចូលរួមសរុបចំនួន៣៥៩នាក់ (ស្រី១១៥នាក់)**<br>- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស សរុបអ្នកចូលរួមចំនួន៤៤នាក់ ស្រី៣៨នាក់។<br>- គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត សហការជាមួយ ក្រុមលេខាធិការដ្ឋាន រៀបចំកិច្ចប្រជុំប្រចាំខែឧសភា ឆ្នាំ២០១៧ ដើម្បីត្រួតពិនិត្យការគ្រប់គ្រងអនុវត្តអំពីតួនាទី និងភារកិច្ចដល់មន្ត្រីពាក់ព័ន្ធភូមិ/ឃុំ/សង្កាត់/ក្រុង/ស្រុកការងារដឹកនាំ និងជំរុញឲ្យក្រុមការងារខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ដើម្បីគ្រប់គ្រងសភាពការណ៍បទល្មើស និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ បានចំនួន០៥ក្រុង/ស្រុក មានសមាសចូលរួមមានចំនួន៣១៥ ស្រី៧៧នាក់។ |

| | |
|---|---|
| | - ថ្នាក់ប៉ុស្តិ៍ និងថ្នាក់ប៉ុស្តិ៍ ខេត្តជាប់ព្រំដែនកម្ពុជា-ឡាវ កម្ពុជា-វៀតណាម បានប្រជុំ ស្តីពីកិច្ចសហប្រតិបត្តិការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ព្រំដែន (០៦លើក)។ |
| **ខេត្តព្រះវិហារ** | **សម្របសម្រួលចំនួន០៨លើក អ្នកចូលរួមសរុបចំនួន១៦៨នាក់ (ស្រី៧៥នាក់)**<br>- កិច្ចប្រជុំចំនួន៥លើក ស្តីអំពីពង្រឹងដល់កិច្ចសហការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត នៅក្នុងខេត្ត និងសកម្មភាពក្នុងការអនុវត្តការងារ របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារទាំ៦ គ.ខ.ប.ជ អ្នកចូលរួមចំនួន១៥៣នាក់ ស្រី៦២នាក់។<br>- កិច្ចប្រជុំរៀបចំគម្រោងផែនការចុះផ្សព្វផ្សាយ និងពង្រឹងការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពីភារកិច្ច តួនាទីដល់សមាជិកក្នុងក្រុមរបស់ខ្លួន និងធ្វើការចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងសិស្សានុសិស្ស នៅតាមវិទ្យាល័យ អនុវិទ្យាល័យ តាមស្រុក ក្នុងខេត្ត ចំនួន៣លើក អ្នកចូលរួមចំនួន១៥នាក់ ស្រី៣នាក់។ |
| **ខេត្តសៀមរាប** | **សម្របសម្រួលចំនួន២៩លើក អ្នកចូលរួមសរុបចំនួន៥៦០នាក់ (ស្រី១៥៤នាក់)**<br>- លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត សហការជាមួយក្រុមការងារបច្ចេកទេសខេត្ត (មន្ទីរកិច្ចការនារី, មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរទេសចរណ៍) ប្រជុំពិភាក្សា ស្តីពីការរៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សម្រាប់ឆ្នាំ២០១៧។<br>- ប្រជុំប្រចាំខែ ដែលមានសមាជិក និងអង្គការដៃគូជាតិអន្តរជាតិ ចូលរួមសរុបចំនួន៣៨នាក់ ស្រី១៩នាក់។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្ត ចូលរួមធ្វើជាវាគ្មិន ក្នុងវគ្គសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស និងទប់ស្កាត់អំពើហិង្សា រៀបចំដោយអង្គការព្រាបកម្ពុជា អ្នកចូលរួមចំនួន៥៥នាក់។<br>- មន្ទីរព័ត៌មានខេត្ត សហការជាមួយអង្គភាពជុំវិញខេត្ត អាជ្ញាធរ ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក និងអង្គភាពពាក់ព័ន្ធ ចូលរួមជាវាគ្មិន ដើម្បីផលិតកម្មវិធីសន្ទនាមតិ និងផ្សព្វផ្សាយច្បាប់ អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកមិនស្របច្បាប់ ជាពិសេសការស្វែងរកជំនួយពីអាជ្ញាធរ និងសង្គមស៊ីវិលនៅក្នុងខេត្ត/ស្រុក បានចំនួន០៦លើក មានអ្នកចូលរួមចំនួន១៥០នាក់ ស្រី៤៧នាក់។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមកិច្ចប្រជុំត្រីមាសទី១ ឆ្នាំ២០១៧ ដែលរៀបចំដោយក្រុមការងារទេសន្តរប្រវេសន៍ អ្នកចូលរួមចំនួន១៨នាក់ ស្រី០៩នាក់។<br>- ចូលរួមប្រជុំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងលើកទិសដៅអនុវត្តបន្តរបស់ គ.ជ.ប.ជ នៅភ្នំពេញ។<br>- ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត ប្រជុំប្រចាំខែមេសា ឆ្នាំ២០១៧ របស់ក្រុមការងារទេសន្តរប្រវេសន៍ អ្នកចូលរួមចំនួន៤០នាក់ ស្រី២១នាក់។<br>- ស្នងការដ្ឋាននគរបាលខេត្ត បានជួបប្រជុំពិភាក្សាជាមួយអង្គការម្លូហាស៊ី ស្តីពីការរំលោភបំពានលើកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលជនបរទេសបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា និងការសហការរវាងអង្គការជាមួយការិយាល័យជំនាញ មានចំនួន០៨នាក់ និងបុគ្គលិកអង្គការចំនួន០៤នាក់។ |

| | |
|---|---|
| | - ស្នងការដ្ឋាននគរបាលខេត្ត ចូលរួមប្រជុំពិភាក្សាធ្វើផែនការ៣ឆ្នាំ ស្តីពីការអនុវត្តច្បាប់យុត្តិធម៌អនីតិជន នៅរាជធានីភ្នំពេញ អ្នកចូលរួមចំនួន១០០នាក់ ស្រី៤២នាក់។<br>- ស្នងការដ្ឋាននគរបាលខេត្ត ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីជំនាញស៊ើបអង្កេត រៀបចំដោយអង្គការ AAPTIP នៅសណ្ឋាគារគ្រីបផាលែសភ្នំពេញ។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ រៀបចំកិច្ចប្រជុំប្រចាំខែកក្កដា ឆ្នាំ២០១៧ មានអ្នកចូលរួមចំនួន៣៥នាក់ ស្រី២១នាក់។<br>- បានសម្របសម្រួលជូនប្រធានក្រុមការងារទេសន្តរប្រវេន៍ និងក្រុមការងារនៃការិយាល័យប្រឆាំងការជួញដូរមនុស្ស ធ្វើជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាស្តីពីការធ្វើចំណាកស្រុកប្រកដោយសុវត្ថិភាព និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងសៀវភៅជំបូលត្រជាក់ ដល់ក្រុមគោលដៅរបស់អង្គការទស្សនពិភពលោក នៅស្រុកក្រឡាញ់ ចំនួន០២លើក ។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយក្រុមការងារទេសន្តរប្រវេន៍ ក្រុមការងារអនុវត្តច្បាប់ និងក្រុមការងារការពារជនរងគ្រោះ ចូលរួមជាវាគ្មិនសន្ទាមតិ ស្តីពីការធ្វើចំណាកស្រុកប្រកដោយសុវត្ថិភាព អំពើជួញដូរមនុស្ស នៅឃុំស្លែងស្ពាន ស្រុកស្រីស្នំដែលមានចំនួនចូលរួមសរុប១៥០នាក់ ស្រី៤៧នាក់។<br>- លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ចូលរួមកិច្ចប្រជុំ សិក្ខាសាលា និងសន្និបាតពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន០៤លើក។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានធ្វើការសម្របសម្រួលជូន ប្រធានក្រុមការងារទេសន្តរប្រវេសន៍ ចូលរួមជាវាគ្មិនក្នុងវគ្គបណ្តុះបណ្តាលស្តីពី ការកសាងសមត្ថភាពដល់ក្រុមជួយខ្លួនឯង ក្រោមប្រធានបទ **"ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពទៅក្រៅប្រទេស និងទប់ស្កាត់អំពើជួញដូរមនុស្ស"** នៅស្រុកក្រឡាញ់ ដែលរៀបចំដោយអង្គការក្រុមអ្នកស្មគ្រ័ចិត្តស៊ីវិល (GVC)។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយអង្គការ IJM ស្តីពីការរៀបចំសិក្ខាសាលា លើការប្រយុទ្ធប្រឆាំងអំពើជួញដូរកម្លាំងពលកម្ម។<br>- លោកស្រីប្រធានលេខាធិការដ្ឋាន ប្រធានក្រុមការងារទាំង៦ បានអញ្ជើញចូលរួមជាវាគ្មិន ក្នុងវេទិកាកុមារ និងយុវជនថ្នាក់ខេត្តក្រោមប្រធានបទស្តីពី យើងរួមគ្នាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសណ្ឋាគារអប្សរាអង្គរ ខេត្តសៀមរាប។<br>- លោកស្រីប្រធានលេខាធិការដ្ឋាន និងមន្ត្រី០១រូប បានចូលរួមកិច្ចប្រជុំឆ្លងផែនការសកម្មភាពឆ្នាំ២០១៧-២០១៨ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្រសួងមហាផ្ទៃ។<br>- ស្នងការដ្ឋាននគរបាលខេត្ត បានជួបពិភាក្សាការងារជាមួយអង្គការម៉ូណូហាស៊ី អំពីការរំលោភបំពានលើកុមារ ការកេងប្រវ័ញ្ចលើកុមារគ្រប់រូបភាព និងការសហការណ៍រវាងអង្គការជាមួយការិយាល័យជំនាញចំនួន០៨នាក់ និងបុគ្គលិកអង្គការចំនួនន០៤នាក់ ។<br>- ស្នងការរដ្ឋាននគរបាលខេត្ត បានចូលរួមធ្វើផែនការ៣ឆ្នាំ ក្នុងការអនុវត្តច្បាប់ ស្តីពីអនីតិជន នៅរាជធានីភ្នំពេញ អ្នកចូលរួមចំនួន១០០នាក់ ស្រី៤២នាក់។ |
| **ខេត្តកំពង់ធំ** | **សម្របសម្រួលចំនួន០៩លើក អ្នកចូលរួមសរុបចំនួន៤៣នាក់ (ស្រី១២នាក់)**<br>- ប្រជុំបូកសរុបការងារប្រចាំខែ ឆ្នាំ២០១៧ និងទិសដៅអនុវត្តបន្ត ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដោយបានពិភាក្សាក្នុងក្រុមការងារទាំង០៦ ដើម្បីអនុវត្តផ្សព្វផ្សាយបន្តជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន អ្នកចូលរួមចំនួន**៤៣**នាក់ ស្រី**១២**នាក់។ |

| | |
|---|---|
| | - ប្រជុំប្រចាំត្រីមាសទី១ និងក្រុមការងារទាំង៦។<br>- ចូលរួមសិក្ខាសាលាបណ្ដុះបណ្ដាល ស្ដីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។<br>- ចូលរៀនវគ្គបណ្ដុះបណ្ដាល ស្ដីពីការស៊ើបអង្កេតបទល្មើស តាមប្រព័ន្ធបច្ចេកវិទ្យា(នៅភ្នំពេញ)។<br>- ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត ចូលរួមសិក្ខាសាលាដើម្បីពិភាក្សា ស្ដីពីប្រសិទ្ធភាពនៃការប្រើប្រាស់ជំនាញស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស នៅសណ្ឋាគារ ហ្វ្រីនផាឡេស រាជធានីភ្នំពេញ។<br>- ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពីរបាយការណ៍កំណត់ទីតាំងសម្រាប់ថែទាំកុមារ និងសមាហរណកម្មកុមារពីមណ្ឌលចំនួន៣០% ទៅកាន់គ្រួសារប្រកបដោយសុវត្ថិភាព នៅទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំឆមាសទី១ ដើម្បីទទួលរបាយការណ៍ ស្វែងរកបញ្ហាប្រឈម និងដំណោះស្រាយ។<br>- លោកជំទាវប្រធានលេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំពិភាក្សា ដើម្បីស្វែងរកសកម្មភាព និងបញ្ហាប្រឈមដែលជាទិភាព ផ្ញើជូនថ្នាក់ជាតិ ជាមួយក្រុមការងារទាំង៦។<br>- ចូលរួមប្រជុំឆ្លងរបាយការណ៍ឆមាសទី១ និងលើកទិសដៅឆមាសទី២ ឆ្នាំ២០១៧ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ |
| **ខេត្តកំពង់ចាម** | **សម្របសម្រួលចំនួន១១លើក អ្នកចូលរួមសរុបចំនួន១៨៣នាក់ (ស្រី១៣នាក់)**<br>- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត ចូលរួមសិក្ខាសាលា ផ្សព្វផ្សាយលទ្ធផលវិភាគទិន្នន័យលម្អិត ស្ដីពីបទពិសោធន៍ស្ត្រីរងគ្រោះ ដោយអំពើជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ និងករណីផ្សេងៗទៀត នៅសណ្ឋាគារ៧មករា ទីរួមខេត្តកំពង់ចាម។<br>- លោកស្រី ស្នងការរង នៃស្នងការដ្ឋាននគរបាលទទួលបន្ទុក ចូលរៀនវគ្គបណ្ដុះបណ្ដាល ស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប នៅសាលាស្រុកជើងព្រៃ។<br>- ចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ ការអន្តរាគមន៍ និងសង្គ្រោះស្ត្រីរងគ្រោះធ្វើការនៅក្រៅប្រទេស។<br>- សន្និបាតបូលសរុបការងាររដ្ឋបាលដែនដី ការអនុវត្តគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៦ និងលើកទិសដៅការងារឆ្នាំ២០១៧។<br>- ចូលរួមវគ្គបណ្ដុះបណ្ដាល ស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប។<br>- ប្រជុំផ្សព្វផ្សាយគោលនយោបាយទេសន្តរប្រវេសន៍ ទិដ្ឋភាពទូទៅ ស្ដីពីក្របខណ្ឌគតិយុត្តិ អ្នកចូលរួម៤៨នាក់ ស្រី១៣នាក់។<br>- ចូលរួមជាវគ្មិនក្នុងកម្មវជីវិទ្យុជាតិ ទូរទស្សន៍ជាតិខេត្ត ក្រោមប្រធានបទការផ្ដល់ភាពស្របច្បាប់ដល់ពលករធ្វើការនៅប្រទេសថៃ។<br>- នាយរងការិយាល័យទទួលបន្ទុកប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន ចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ និងទូរទស្សន៍ជាតិខេត្ត ក្រោមប្រធានបទ |

| | |
|---|---|
| | ផ្សព្វផ្សាយ និងការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទ ដែលជ្រកក្រោមស្លាកខារ៉ាអូខេ និងហាងម៉ាស្សា នៅមន្ទីរព័ត៌មានខេត្ត។<br>- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយគោលនយោបាយទេសន្តរប្រវេសន៍ (អភិបាលកិច្ច ទេសន្តរប្រវេសន៍ការងារ)។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណកម្មជនរងគ្រោះ ក្នុងរឿងក្តីស៊ើបអង្កេតពីការជួញដូរមនុស្ស នៅខេត្តក្រចេះ។<br>- បានចូលរួមប្រជុំផ្សព្វផ្សាយស្តីពីការកិច្ចសហកាដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរពលកម្ម អ្នកចូលរួមចំនួន១៣៥នាក់។ |
| **ខេត្តបន្ទាយមានជ័យ** | **សម្របសម្រួលចំនួន១៣លើក អ្នកចូលរួមសរុបចំនួន១៦៣នាក់ (ស្រី៦៦នាក់)**<br>- ចូលរួមប្រជុំរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សាខេត្តអាណត្តិទី២។<br>- បញ្ជូនមន្ត្រី២រូប ចូលរួមប្រជុំត្រួតពិនិត្យការអនុវត្ត គោលការណ៍របស់អគ្គស្នងការដ្ឋាននគរបាលជាតិ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៦ ក្រោមអធិបតីភាព លោកជំទាវ ឧត្តមសេនីយ៍ឯក **យក់ សុខា** អគ្គស្នងការរង ទទួលផែននគរបាលយុត្តិធម៌ អ្នកចូលរួមចំនួន៣៥នាក់ ស្រី១៧នាក់ (នៅស្នងការដ្ឋាន ខេត្តសៀមរាប)។<br>- ស្នងការដ្ឋាននគរបាលខេត្ត ចាត់បញ្ជូនមន្ត្រីការិយាល័យជំនាញចំនួន០៣រូប ប្រចាំការនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដើម្បីសម្ភាសពលករដែលអាជ្ញាធរថៃបញ្ជូនមក និងស្រាវជ្រាវរកមុខសញ្ញាពាក់ព័ន្ធអំពើជួញដូរមនុស្ស។<br>- ស្នងការដ្ឋាននគរបាលខេត្ត ចូលរួមវេទិកា សំណួរ ចម្លើយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការយល់ដឹងអំពីអំពើជួញដូរមនុស្ស បានចំនួន០៤ឃុំ (ឃុំតាប៉ែន ឃុំទ្រាស ,ឃុំតាផូ ,ឃុំផ្គាំ )។<br>- ចូលរួមប្រជុំបូកសរុបលទ្ធផលការងារត្រីមាសទី១ និងផ្សព្វផ្សាយទិសដៅបន្តការងារក្នុងឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ។<br>- ស្នងការដ្ឋាននគរបាលខេត្ត ចូលរួមនៅ គណៈកម្មាធិការ គ.ខ.ប.ជ ថ្នាក់ខេត្ត និងការយល់ដឹងអំពីអំពើជួញដូរមនុស្ស ។<br>- ក្រុមការងារលេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រីមាសទី១ និងប្រចាំខែមេសា ឆ្នាំ២០១៧ អ្នកចូលចំនួន៦៦នាក់ (ស្រី២៤នាក់)។<br>- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីយន្តការបណ្តឹងសម្រាប់ពលករទេសន្តរប្រវេសន៍ចំនួន២ថ្ងៃ នៅសណ្ឋាគារលីហេងឆាយ ក្រុងប៉ោយប៉ែត រៀបដោយអង្គការ IOM។<br>- ក្រុមការងារលេខាធិការដ្ឋាន និងការិយាល័យប្រឆាំងការជួញដូរមនុស្ស និងមន្ទីរសង្គមកិច្ច មន្ទីរការងារ ដឹកនាំដោយ លោកជំទាវ អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានខេត្ត ចុះពិនិត្យ និងសម្ភាសន៍ពលករដែលភាគីថៃបញ្ជូនត្រឡប់។<br>- ចូលរួមសហការជាក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដឹកនាំដោយ ឯកឧត្តម ឧត្តមសេនីយ៍ឯក **យឹម រិះ** អគ្គលេខាធិការរង គ.ជ.ប.ជ ជួបសំណេះ សំណាល ជាមួយប្រធានច្រកបឹងត្រកួន, ម៉ាឡៃ, ប៉ោយប៉ែត និងវរឈរជើងការពារតាមបន្ទាត់ព្រំដែនមាន វរ៨៩១, ៩១១, ៨១៥ និង៨០៥ ដើម្បីប្រមូលព័ត៌មានអំពីស្ថានភាពពលករឆ្លងដែន និងពលករដែលភាគីថៃបញ្ជូនត្រឡប់។<br>- បានបើកកិច្ចប្រជុំពិភាក្សាលើបញ្ហាលំហូរពលករមិនប្រក្រតីដែលភាគីថៃបញ្ជូនមក ដើម្បីលើកយន្តការគ្រប់គ្រង និងមានគោលការណ៍រៀបចំមណ្ឌលសំចត |

| | |
|---|---|
| | ទទួលពលករនៅក្រុងប៉ោយប៉ែត ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ។<br>- បានរៀបចំកិច្ចប្រជុំបូកសរុបប្រចាំខែកក្កដា ឆមាសទី១ ឆ្នាំ២០១៧ និងឆ្លងផែនការសកម្មភាពសម្រាប់អនុវត្តបន្តឆ្នាំ២០១៧-២០១៨ ក្រោមអធិបតីភាព លោកជំទាវ អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋានខេត្ត មានអ្នកចូលរួមចំនួន**៦២**នាក់ ស្រី**២៥**នាក់ សាលប្រជុំ សាលាខេត្តបន្ទាយមានជ័យ។<br>- ចូលរួមវគ្គបណ្តុះបណ្តាលបន្តវគ្គបង្គោល នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។<br>- ចូលរួមប្រជុំពិគ្រោះយោបល់ គ.ក.ស.ក ប្រចាំខែ នៅសាលាខេត្តបន្ទាយមានជ័យ។ |
| **ខេត្តកំពត** | **សម្របសម្រួលចំនួន០៣លើក**<br>- ប្រជុំក្រុមការងារលេខាធិការដ្ឋាន និងក្រុមទាំង៦ ប្រចាំខែដើម្បីផ្សព្វផ្សាយអប់រំច្បាប់ ស្តីពីលិខិតបទដ្ឋាននានា ដែលពាក់នឹងជំនាញប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់គណៈអភិបាលក្រុង/ស្រុក និងក្រុមប្រឹក្សាឃុំ ឲ្យគាត់ផ្សព្វផ្សាយបន្ត ដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន តាមរយៈពិធីមង្គលការ ពិធីបុណ្យ និងពិធីកម្សាន្តផ្សេងៗ។<br>- គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត សហការជាមួយក្រុមលេខាធិការដ្ឋាន និងក្រុមការងារទាំង៦ ដើម្បីត្រួតពិនិត្យការគ្រប់គ្រងអនុវត្តការងារដឹកនាំ និងជំរុញឲ្យក្រុមការងារខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ដើម្បីគ្រប់គ្រងសភាពការណ៍បទល្មើស និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ នៅក្នុងខេត្តទាំងមូល។<br>- គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានសហការជាមួយ ក្រុមលេខាធិការដ្ឋាន និងក្រុមការងារទាំង៦ ប្រជុំប្រចាំត្រីមាស និងឆមាស ដើម្បីត្រួតពិនិត្យការគ្រប់គ្រងអនុវត្តការងារដឹកនាំ និងជំរុញឲ្យ ក្រុមការងារខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ដើម្បីគ្រប់គ្រងសភាពការណ៍បទល្មើស និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ នៅក្នុងខេត្តទាំងមូល។ |
| **ខេត្តមណ្ឌលគិរី** | **សម្របសម្រួលចំនួន០២លើក**<br>- ឯកឧត្តម អភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត បានដឹកនាំកិច្ចប្រជុំ ក្នុងសកម្មភាពត្រួតពិនិត្យលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទលើស្រ្តី និងកុមារ និងដោះស្រាយនូវរាល់បញ្ហាកើតមានឡើងទូទាំងខេត្ត។<br>- បើកកិច្ចប្រជុំរវាងសមាគមនារីខេត្តមណ្ឌលគិរី និងខេត្តដាក់ឡាក់ (វៀតណាម) ដើម្បីកិច្ចសហប្រតិបត្តិការបង្ការ ទប់ស្កាត់ប្រឆាំងអំពើជួញដូរមនុស្សឆ្លងដែនខុសច្បាប់។ |
| **ខេត្តប៉ៃលិន** | **សម្របសម្រួលចំនួន០៦លើក អ្នកចូលរួមសរុបចំនួន២៤នាក់ (ស្រី១០នាក់)**<br>- ចូលរួមប្រជុំ គ ក ស ក ផ្សព្វផ្សាយពីបញ្ហាការទប់ស្កាត់ អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។<br>- ចូលរួមប្រជុំ ជាមួយ គ ក ស ក នៅសង្កាត់ទួលល្វា អំពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាពរបស់ប្រជាពលរដ្ឋក្នុងសង្កាត់។ |

| | |
|---|---|
| | - លោកជំទាវអភិបាលរង ទទួលបន្ទុក គ.ខ.ប.ជ អញ្ជើញចូលរួមសន្និបាតបូកសរុបការងារប្រចាំឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ។<br>- គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត សហការជាមួយ ក្រុមលេខាធិការដ្ឋានថ្នាក់ក្រុង ប្រជុំប្រចាំខែឧសភា ដើម្បីផ្សព្វផ្សាយអំពីច្បាប់ ស្តីពីការបង្ក្រាទប់ ស្កាត់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់សមាជិកដែលមានចំនួន**២៤**នាក់(ស្រី**១០**នាក់)។<br>- បានចុះអធិការកិច្ច ដើម្បីបង្ក្រា ទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថាន ដែលមានការប្រើប្រាស់កម្លាំងពលកម្ម ដូចជាៈ សៃឡ កាស៊ីណូ ឡូតដូ ភោជនីដ្ឋាន និងអាហារដ្ឋាន។<br>- ចូលរួមប្រជុំផ្សងផែនការសកម្មភាពជាតិរបស់ គ.ជ.ប.ជ សម្រាប់អនុវត្តបន្តឆ្នាំ២០១៧-២០១៨ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។ |
| **ខេត្តតាកែវ** | **សម្របសម្រួលចំនួន០៣លើក**<br>- លោកជំទាវប្រធានក្រុមលេខាធិការដ្ឋានគ.ខ.ប.ជខេត្ត ដឹកនាំកិច្ចប្រជុំពិភាក្សាលើការងារបំពេញកម្រងសំណួរ លក្ខណៈវិនិច្ឆ័យ សម្រាប់ធ្វើការវាយតម្លៃលទ្ធផលការងារ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៦។<br>- លោកជំទាវអភិបាលរង ទទួលបន្ទុកគ.ខ.ប.ជ អញ្ជើញចូលរួមសន្និបាតបូកសរុបការងារប្រចាំឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ។<br>- ចូលរួមប្រជុំផ្សងរបាយការណ៍ឆមាសទី១ និងលើកទិសដៅឆមាសទី២ ឆ្នាំ២០១៧ របស់គ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ |
| **ខេត្តកណ្តាល** | **សម្របសម្រួលចំនួន២៣លើក អ្នកចូលរួមសរុបចំនួន៥៣៧នាក់ (ស្រី២៧៩នាក់)**<br>- ក្រុមការងារថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន១៨លើក អ្នកចូលរួមចំនួន៤២៤នាក់ ស្រី២២១នាក់។<br>- គណៈកម្មាធិការស្រុកលើកដែក បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសទី៣ អ្នកចូលរួមចំនួន១៧នាក់ ស្រី០២នាក់។<br>- លេខាធិការដ្ឋានខេត្ត បានរៀបចំកិច្ចប្រជុំបូកសរុបការងារប្រចាំខែសីហា អ្នកចូលរួមចំនួន៣០នាក់ ស្រី២៣នាក់។<br>- លេខាធិការដ្ឋានខេត្ត បានរៀបចំកិច្ចប្រជុំបូកសរុបការងារប្រចាំត្រីមាសទី៣ អ្នកចូលរួមចំនួន៤៥នាក់ ស្រី៣០នាក់។<br>- ស្រុកលើកដែក បានប្រជុំពង្រឹងសមត្ថភាពក្នុងការអនុវត្តតាមមុខជំនាញ អ្នកចូលរួមចំនួន២១នាក់ ស្រី០៣នាក់។<br>- ក្រុមការងារលេខាធិការដ្ឋានខេត្តចំនួន០២រូប បានចូលរួមសិក្ខាសាលា ស្តីពីការផ្សព្វផ្សាយផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៧-២០១៨ នៅទីស្តីការក្រសួងមហាផ្ទៃ។ |
| **ខេត្តព្រៃវែង** | **សម្របសម្រួលចំនួន០៧លើក អ្នកចូលរួមសរុបចំនួន៤៨នាក់ (ស្រី២៣នាក់)**<br>- ប្រជុំប្រចាំខែមករា ស្តីពីកិច្ចសហការពង្រឹងសម្ថភាពក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការ គ.ខ.ប.ជខេត្ត អ្នកចូលរួមចំនួន**៤៨**នាក់ (ស្រី**២៣**នាក់)។ |

| | |
|---|---|
| | - ប្រជុំក្រុមការងារលេខាធិការដ្ឋាន និងស្នងការដ្ឋាននគរបាលខេត្ត ប្រចាំខែដើម្បីផ្សព្វផ្សាយអប់រំច្បាប់ ស្តីពីលិខិតបទដ្ឋាននានា ដែលពាក់នឹងជំនាញប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់គណៈអភិបាលស្រុក និងក្រុមប្រឹក្សាឃុំ ឲ្យគាត់ផ្សព្វផ្សាយបន្ត ដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន។<br>- ចូលរួមជាវាគ្មិនក្នុងវេទិកា ស្តីពីសុត្ថិភាពការចំណាកស្រុក ។<br>- ចូលរួមសន្និបាតបូកសរុបការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៦ និងទិសដៅឆ្នាំ២០១៧ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- គណៈកម្មាធិការពិគ្រោះយោបល់ លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត និងស្នងការដ្ឋាននគរបាលខេត្ត ប្រជុំប្រចាំខែ ដើម្បីផ្សព្វផ្សាយអំពីច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងជំនាញប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់គណៈអភិបាលស្រុក និងក្រុមប្រឹក្សាឃុំ ឲ្យពួកគាត់ជួយផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួនតាមរយៈ ពិធីមង្គលការ ពិធីបុណ្យ និងពិធីកម្សាន្តផ្សេងៗ។<br>- ប្រជុំប្រចាំខែនៅស្នងការដ្ឋាន នៅគណៈកម្មាធការពិគ្រោះយោបល់ និងលេខាធិការដ្ឋានខេត្ត ដើម្បីផ្សព្វផ្សាយ អប់រំអំពីច្បាប់ និងលិខិតបទដ្ឋាននានា ដែល ពាក់ព័ន្ធនិងជំនាញប្រឆាំងការជួញដូរមនុស្ស ជូនដល់អង្គប្រជុំ ជាពិសេសដល់គណៈអភិបាលស្រុក និងក្រុមប្រឹក្សាឃុំ ដើម្បីធ្វើការផ្សព្វផ្សាយបន្តដល់ប្រជា ពលរដ្ឋនៅតាមមូលដ្ឋានរបស់ខ្លួន។<br>- ចូលរួមប្រជុំឆ្លងផែនការសកម្មភាពជាតិរបស់ គ.ជ.ប.ជ សម្រាប់អនុវត្តបន្តឆ្នាំ២០១៧-២០១៨ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។ |
| **ខេត្តស្ទឹងត្រែង** | **សម្របសម្រួលចំនួន០៥លើក អ្នកចូលរួមសរុបចំនួន៤០នាក់ (ស្រី១៦នាក់)**<br>- ប្រជុំក្រុមការងារជំនាញលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ខ.ប.ជ។<br>- ចាត់បញ្ជូនកម្លាំង១រូបចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេតបទល្មើសឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធឺណែត នៅភ្នំពេញ។<br>- គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត សហការជាមួយក្រុមលេខាធិការដ្ឋានថ្នាក់ក្រុង បានធ្វើការប្រជុំប្រចាំខែមេសា ដើម្បីផ្សព្វផ្សាយអំពីច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងជំនាញប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់សមាជិកដែលមានចំនួន១៥នាក់ ស្រី៧នាក់។<br>- ប្រជុំប្រចាំឆមាសទី១ ឆ្នាំ២០១៧ របស់ក្រុមការងារជំនាញលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ខ.ប.ជ ដែលមានអ្នកចូលរួមចំនួន២៥នាក់ ស្រី០៩នាក់។<br>- បានចូលរួមប្រជុំផ្សព្វផ្សាយអំពីតួនាទីភារកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ ដើម្បីពង្រឹងកិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធអំពីការងារការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកំណត់អត្តសញ្ញាណជនរងគ្រោះឲ្យបានត្រឹមត្រូវ និងជួយជនរងគ្រោះទាន់ពេលវេលា នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ |
| **ខេត្តស្វាយរៀង** | **សម្របសម្រួលចំនួន០៥លើក អ្នកចូលរួមសរុបចំនួន៣៤១នាក់ (ស្រី១២នាក់)** |

| | |
|---|---|
| | - ស្នងការដ្ឋាននគរបាលខេត្ត ចាត់បញ្ជូនមន្ត្រីការិយាល័យជំនាញចំនួន០១រូប ទៅចូលរួមវគ្គហ្វឹកហ្វឺនបន្ថែមលើកទី២ ស្តីពីជំនាញស៊ើបអង្កេត អំពីអំពើជួញដូរមនុស្ស ដល់មន្ត្រីនគរបាលជាស្ត្រី នៅសណ្ឋាគារ Green Palace រាជធានីភ្នំពេញ។<br>- ស្នងការដ្ឋាននគរបាលខេត្ត បានចាត់បញ្ជូនមន្ត្រីការិយាល័យជំនាញចំនួន០១រូប ទៅចូលរួមសិក្ខាសាលា ស្តីពីការផ្សព្វផ្សាយក្រុមប្រតិបត្តិយេនឌ័រក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសិក្ខាកាមចូលរួមចំនួន៦៤នាក់ ស្រី០៤នាក់ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ ឧបត្ថម្ភដោយអង្គការ AATIP។<br>- ប្រជុំឆ្លងផែនការសកម្មភាពការងារ គ.ខ.ប.ជ ឆមាសទី២ សម្រាប់អនុវត្តបន្តឆ្នាំ២០១៧ អ្នកចូលរួមចំនួន១៨នាក់ ស្រី០៨នាក់ នៅសាលាខេត្តស្វាយរៀង។<br>- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុក និងការទប់ស្កាត់អំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន២៥៤នាក់ (០២លើក)។ |
| **ខេត្តត្បូងឃ្មុំ** | **សម្របសម្រួលចំនួន០១លើក អ្នកចូលរួមសរុបចំនួន១១៩នាក់ (ស្រី៥១នាក់)**<br>- ប្រជុំប្រចាំត្រីមាសទី១ និងលើកទិសដៅត្រីមាសទី២ សម្រាប់ឆ្នាំ២០១៧ ក្រោមអធិបតីភាព លោកជំទាវ អភិបាលរងខេត្ត និងជាប្រធានគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានអ្នកចូលរួមចំនួន១១៩នាក់ ស្រី៥៩នាក់។ |
| **ខេត្តព្រះសីហនុ** | **សម្របសម្រួលចំនួន០៣លើក អ្នកចូលរួមសរុបចំនួន១៣៣នាក់ (ស្រី៦៥នាក់)**<br>- ចូលរៀនវគ្គបណ្តុះបណ្តាល ស្តីពីការសម្ភាសកុមារ តាមបែបកុមារមេត្រី និងការស៊ើបអង្កេតអំពើរំលោភបំពាន ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។<br>- ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត សហការជាមួយក្រុមការងារជំនាញអន្តរមន្ទីរ ប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០១៧ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានអ្នកចូលរួម៤៦នាក់ ស្រី១៦នាក់។<br>- ក្រុមការងារលេខាធិការដ្ឋាន បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការអប់រំសុខមាលភាពសង្គម ដើម្បីជួយដល់ស្ត្រី និងក្មេងស្រីរងគ្រោះដោយអំពើជួញដូរមនុស្ស ឲ្យយល់ដឹងពីសិទ្ធទទួលបានការងារ សិល្បៈក្នុងការនៅប្រកបដោយសមធម៌យេនឌ័រ មានអ្នកចូលរួមចំនួន៤១នាក់ ស្រី៣៥នាក់។<br>ប្រជុំបូកសរុបលទ្ធផលឆមាសទី១ លើកទិសដៅឆមាសទី២ ឆ្នាំ២០១៧ អ្នកចូលរួមចំនួន៤៦នាក់ ស្រី១៤នាក់។ |
| **ខេត្តកំពង់ស្ពឺ** | **សម្របសម្រួលចំនួន០៨លើក អ្នកចូលរួមសរុបចំនួន២៨៥នាក់ (ស្រី២២១នាក់)**<br>- ប្រជុំប្រចាំខែ ស្តីអំពីបណ្តាញក្រុមការងារអ្នកផ្តល់សេវាកម្មជួយដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រថ្នាក់ខេត្ត ចំនួន០៦លើក អ្នកចូលរួមចំនួន២០៣នាក់ ស្រី១៥០នាក់<br>- ចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពីសកម្មភាពថ្នាក់ភូមិដើម្បីទប់ស្កាត់ការជួញដូរមនុស្សនៅខេត្តកោះកុង ចំនួន០១លើក អ្នកចូលរួម៤២នាក់ ស្រី៣៨នាក់<br>- ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់ការ រំលោភបំពានផ្លូវភេទលើស្ត្រីនិងកុមារ នៅខេត្តកោះកុង អ្នកចូលរួមចំនួន៤០នាក់ ស្រី៣៣ នាក់ |